វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

Prek Leap National Institute Of Agriculture

# ការត្រួតពិនិត្យសត្វ និងសាច់



រៀបរៀងដោយៈ លោក ម៉ាន់ ខុធ

# ជំពូកទី ១ ដំណើរការណ៍ និងវិធីសាស្ត្រពិឃាដសត្វ

## ១.ការពិនិត្យសត្វរស់មុនពេលពិឃាដ

ការពិនិត្យសត្វរស់មុនពេលពិឃាដ គឺវាមានសារៈសំខាន់ណាស់ ព្រោះសាច់ដែលបានមកពីសត្វមិនមានសុខភាពល្អ (មានមេរោគ) វាបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់អ្នកបរិភោគ (ដូចជាជំងឺតេតាណូស និងជំងឺឆ្កួត) ជួបប្រទះតែនៅពេលពិនិត្យសត្វរស់ ចំពោះការវះកាត់ក្រោយពេលពិឃាដ គឺជួនកាលគ្មានប្រសិទ្ធិភាពក្នុងការស្រាវជ្រាវរកស្លាកស្នាមពិតប្រាកដឡើយ ហើយបសុពេទ្យមានភារកិច្ចសម្រេចដោយវិចារណញាណខ្ពស់និងផ្ដល់ជូននូវការជានាគ្រប់គ្រាន់នៅពេលដែលខ្លួនពិនិត្យសត្វរស់។

## ២.ការងាររដ្ឋបាលនៅទីសត្តឃាដ

នៅទីសត្តឃាតនីមួយៗ មានការងាររដ្ឋបាលសម្រាប់ទីសត្តឃាតត្រូវអនុវត្តជាប្រចាំថ្ងៃ បសុពេទ្យដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យសត្វ និងសាច់ត្រូវអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួននូវការងាររដ្ឋបាលដូចខាងក្រោមៈ

- ការកត់ត្រាចូលបញ្ជីសត្តឃាត
- ការធ្វើរបាយការណ៍
- ការផ្ដល់ និងទទួលលិខិតស្នាម
- ឯកសារការងាររដ្ឋបាល

## ៣.ការកត់ត្រាចូលក្នុងបញ្ជីសត្តឃាត

សត្វដែលនាំចូលមកទីសត្វត្តឃាតត្រូវបានភ្នាក់ងារត្រួតពិនិត្យ (បសុពេទ្យ) ពិនិត្យទៅលើលិខិតអនុញ្ញាតដឹកជញ្ជូន (ចំនួនសត្វពិតប្រាក និងចំនួនក្នុងលិខិតត្រូវគ្នា) មធ្យោបាយដឹកជញ្ជូនឈ្មោះអាជីវករ ចំនួនសត្វ ប្រភពដឹកនាំសត្វមក រួចកត់ត្រាចូលក្នុងបញ្ជីសត្តឃាត និងអនុញ្ញាតឱ្យទំលាក់សត្វចុះពីរថយន្ត។

**៣.១ បញ្ជីកត់ត្រាការពិឃាដ** ៖ បញ្ជីនេះមានសារៈសំខាន់ណាស់ ព្រោះវាបញ្ជាក់ពីសកម្មភាពការងាររបស់សត្តឃាត និងបញ្ជាក់ពីស្ថិតិសត្វដែលត្រូវពិឃាដ ឬជាមូលដ្ឋានសម្រាប់ធ្វើរបាយការណ៍ស្ដីពីពាណិជ្ជកម្មផលិតផលសត្វ។ ការកត់ត្រាត្រូវបានធ្វើជាប្រចាំរៀងរាល់ថ្ងៃដោយហេតុថា ការពិឃាដត្រូវបានចុះបញ្ជីតាមលេខរៀងបន្តបន្ទាប់។

ក្នុងបញ្ជីកត់ត្រាការពិឃាត ត្រូវមានការកត់ត្រាសំគាល់ដូចខាងក្រោម ៖

- ថ្ងៃ....................ខែ .............. ឆ្នាំពិឃាដ ...................................
- ឈ្មោះ ............................... អាជីវករដែលយកសត្វមកពិឃាដ
- ប្រភេទ .............................. ចំនួនសត្វបានពិឃាដ ....................

នៅចុងម៉ោងនៃថ្ងៃធ្វើការនីមួយៗ បសុពេទ្យត្រូវទទួលខុសត្រូវ ៖ ត្រូវបូកសរុបចំនួនសត្វ ដែលបានពិឃាដ ដើម្បីងាយស្រួលធ្វើស្ថិតិ។

**៣.២ បញ្ជីកត់ត្រានៃការដកហូត** ៖ បញ្ជីនេះប្រមូលផ្តុំព័ត៌មានទាំងឡាយស្តីពីការដកហូត ដូច្នេះគេត្រូវកត់ត្រារាល់មូលហេតុអ្វីៗដែលកើតឡើងជាប្រចាំក្នុងថ្ងៃ ដោយគ្មានប្រហែសបានឡើយ។

ចំនុចសំខាន់ដែលត្រូវកត់ត្រាមានរួមមាន ៖

- ថ្ងៃ ...............ខែ ............ឆ្នាំ ........... ដែលបានដកហូត
- ឈ្មោះ ........................................ អាជីវករ
- ប្រភេទសត្វ ..................................
- ប្រភេទសាច់ ................................. និងទំងន់ដែលបានដកហូត
- មូលហេតុនៃការដកហូត ........................................
- លេខវិញ្ញាបនបត្រ័ ដែលបានចេញអោយអាជីវករ។

**៣.៣ បញ្ជីកត់ត្រាអំពីការទទួលសាច់** ៖ សត្វក្រៅពីសត្តឃាត និងផលិតផលដែលមានដើមកំណើតពីសត្វផ្សេងៗទៀត ដែលត្រូវបានដឹកចូល។ ត្រូវបានទទួលពីក្នុងទីសត្តឃាត ឬក្នុងផ្សារដែលនៅទីនោះអ្នកទទួលខុសត្រូវ ត្រូវពិនិត្យសារជាថ្មី និងបន្ទាប់មកត្រូវកត់ត្រាក្នុងបញ្ជីទទួល។ ក្នុងបញ្ជីនេះគេត្រូវកត់ត្រា ៖

- ថ្ងៃ ............... ខែ ........ ឆ្នាំ ...............ទទួល
- ឈ្មោះ ...................................... អាជីវករ
- ទីកន្លែងចេញ ..........................................
- លេខវិញ្ញាបនបត្រ័ដើម បញ្ជាក់ការពិនិត្យអនាម័យរបស់មូលដ្ឋានដើម
- ប្រភេទផលិតផល .......................................
- បរិមាណ ៖ គឺទំងន់ ................និងចំនួន..........
- ការដកហូតដែលបានធ្វើ បើសិនជាមាន ៖ (ប្រភេទ ..... បរិមាណ .......មូលហេតុ .......)

## ៤.របៀបធ្វើរបាយការណ៍

រាល់លិខិតឬបញ្ជីស្នាមទាំងអស់ ដែលអ្នកទទួលខុសត្រូវនៅទីសត្តឃាតដ្ឋានបានកត់ត្រាទុកប្រចាំថ្ងៃ គឺជាឯកសារមូលដ្ឋានសំរាប់ធ្វើរបាយការណ៍ ស្ថិតិប្រចាំខែ និងស្ថិតិប្រចាំឆ្នាំ។

**៤.១ របាយការណ៍ប្រចាំខែ** ៖ ត្រូវមានចុះលេខជាបន្តបន្ទាប់ ហើយត្រូវបញ្ជូនទៅអង្គភាពដែលជាភ្នាក់ងារស្ថិតនៅក្រោមឱវាទ។ របាយការណ៍ផ្តល់សារៈសំខាន់ដល់រដ្ឋអំណាចនៃអង្គភាពផ្សេងៗទៀត ក្នុងការទារពន្ធករ និងពន្ធដារ។

**៤.២ របាយការណ៍ប្រចាំឆ្នាំ** ៖ ក្នុងរបាយការណ៍ប្រចាំឆ្នាំ ត្រូវធ្វើការបូកសរុបលទ្ធផលការងារប្រចាំខែនីមួយៗ ហើយបន្ថែមលើនោះទៅទៀត ត្រូវផ្តល់យោបល់ស្តីអំពីតំរូវការនៃការហូបចុកសាច់ ឬផលិត ផល លើកទិសដៅក្នុងការធ្វើជំនួញសាច់ ការរៀបចំកែលំអកន្លែងពិនិត្យសាច់ និងធ្វើសំណូមពរអំពីរបៀបពិនិត្យសាច់។

## ៥.ការផ្ដល់ និងទទួលលិខិតស្នាម

ភ្នាក់ងារត្រួតពិនិត្យអនាម័យត្រូវផ្ដល់ ឬទទួលឯកសារដូចខាងក្រោម ៖

**៥.១ វិញ្ញាបនបត្រ័បញ្ជាក់ការដេកហូត ៖** ម្ចាស់សាច់ និងម្ចាស់ផលិតផលសត្វ ដែលត្រូវបានគេដកហូតនូវទំនិញរបស់ខ្លួននោះ មានសិទ្ធិ សុំវិញ្ញាបនបត្រ័ស្ដីពីការដេកហូតនោះ។

ដើម្បីអាចយកជាការបាន វិញ្ញាបនបត្រ័និមួយៗត្រូវមានកត់ត្រា ៖

- ថ្ងៃ ..........ខែ.......... ឆ្នាំ ..........នៃការដេកហូត
- ឈ្មោះម្ចាស់ទំនិញ ......................................
- ប្រភេទសត្វ ..................
- ប្រភេទទំនិញនៃការដេកហូត...........ចំនួន..........
- មូលហេតុនៃការដេកហូត ................................
- ទិសដៅនៃផលិតផលក្នុងការដេកហូត ................

ក្នុងករណីដែលការដេកហូតមានទ្រង់ទ្រាយដូចជា ៖ សាច់គោក្របីទាំងមូល ឬស្បែកគេត្រូវកត់ត្រាមួយៗ ដើម្បីវិភាគអំពីទ្រង់ទ្រាយសត្វដែលគេបានពិឃាត ។

**៥.២ វិញ្ញាបនបត្រ័បញ្ជាក់ការពិនិត្យអនាម័យ ៖** ចំពោះផលិតផលដែលមានដើមកំនើតពីសត្វសម្រាប់ប្រើប្រាស់ក្នុងការហូបចុក ឬសាច់ដែលកាប់ក្រៅមូលដ្ឋាន ហើយត្រូវបានដឹកជញ្ជូនចូលទីផ្សារ ត្រូវតែភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រ័ដើមបញ្ជាក់អំពីការពិនិត្យអនាម័យ ដែលក្នុងនោះមាននិយាយអំពី ៖

- ប្រភពដើម ...............................
- ប្រភេទផលិតផល .....................
- បរិមាណចំនួនដុំ ..........ទំងន់......
- ពិនិត្យអនាម័យបានធ្វើ ...............

ភ្នាក់ងារដែលពិនិត្យអនាម័យ ជាធម្មតាគឺជាអ្នកដែលបានធ្វើសច្ចា។ ត្រូវធ្វើកំណត់ហេតុស្ដីពីបទល្មើស,ការបំពានច្បាប់ដែលបានប្រព្រឹត្តផ្ទុយខ្លឹមសារស្ដីពីការត្រួតពិនិត្យអនាម័យទីសត្តឃាត។

**៥.៣ ឯកសារផ្សេងៗ** ៖ ដែលទទួលយក និងរក្សាទុកនៅទីសត្តឃាតមាន

- វិញ្ញាបនបត្រ័ពិនិត្យសុខភាព ដើម្បីដឹកជញ្ជូនចូលទីសត្តឃាត។
- វិញ្ញាបនបត្រ័ដើមបញ្ជាក់អនាម័យសាច់ ឬផលិតផលសត្វ។

## ៦.ឯកសារការងាររដ្ឋបាល ៖

### ៦.១ បញ្ជីកត់ត្រាការពិឃាត

| ថ្ងៃខែឆ្នាំ | ឈ្មោះ អាជីវករ | គោគ្រៀវ | គោបា | គោមេ | កូនគោ | ជ្រូក សាច់ | ជ្រូកមេ | ចៀម | ពពែ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

### ៦.២ បញ្ជីកត់ត្រាការដកហូត

| ថ្ងៃខែឆ្នាំ | ឈ្មោះអាជីវករ | លេខរៀង | ប្រភេទជំងឺឆ្លង | ភិនភាគសត្វ | ប្រភេទនិងទំងន់នៃចំណែកក្នុង ការដកហូត | មូលហេតុ | មូលដ្ឋានដើមរបស់សត្វ | លេខលិខិតនៃការដកហូត |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

### ៦.៣ បញ្ជីកត់ត្រាការទទួលសាច់ និងផលិផលសត្វ ៖

| ថ្ងៃ.ខែ.ឆ្នាំ | ឈ្មោះអាជីវករ | ទីកន្លែងដឹកចេញ | លេខវិ.ពិនិត្យអនាម័យរបស់មូលដ្ឋានដើម | ប្រភេទផលិតផល | បរិមាណទទួល | មូលហេតុ |
|---|---|---|---|---|---|---|
| | | | | | | |

### ៦.៤ វិញ្ញាបនបត្រ័បញ្ជាក់ការដកហូតផលិតផលសត្វ ៖

- ទីសត្តឃាត ............................................
- វិញ្ញាបនបត្រ័បញ្ជាក់ការដកហូតផ/ផសត្វ
- យើងចុះហត្ថលេខាខាងក្រោមឈ្មោះ..........បសុពេទ្យពិនិត្យអនាម័យនៅទីសត្តឃាត។
- បញ្ជាក់ការដកហូតនៅថ្ងៃទី......................នូវផលិតផលដូចខាងក្រោម ដែលមានលក្ខណៈមិនសមស្របអោយប្រើប្រាស់ក្នុងការធ្វើម្ហូប។ ដោយមូលហេតុ.......................។
- ផលិតផលដកហូតមាន ........ទំងន់ពិត .....គ.ក្រ នៃសត្វ..........(ប្រភេទសត្វ).........ដែលមានភិនភាគ.......ហើយដែលត្រូវបានពិឃាតនៅថ្ងៃទី..... ដោយឈ្មោះ.......(អាជីវករ )។
- អាជីវករឈ្មោះ........ដូចខាងលើបានប្រកាសថា ខ្លួនបានទិញសាច់នេះពីឈ្មោះ ......ទីលំនៅ ...... សាច់ និងគ្រឿងក្នុងដែលបានដកហូត ត្រូវបានបង្វែរទិសប្រើប្រាស់ ឬបំផ្លាញចោល។

វិញ្ញាបនបត្រ័ត្រូវបានចេញជូនឈ្មោះ ............ តាមសំណើរបស់សាមីខ្លួន។

ធ្វើនៅថ្ងៃទី .......ខែ .......ឆ្នាំ ...........

ហត្ថលេខា ៖ បសុពេទ្យពិនិត្យអនាម័យ និងត្រារបស់អង្គភាព

### ៦.៥ វិញ្ញាបនបត្រ័បញ្ជាក់ការពិនិត្យអនាម័យ ៖

- ទីសត្តឃាត ....................
- វិញ្ញាបនបត្រ័បញ្ជាក់ការពិនិត្យអនាម័យផលិតផល យើងចុះហត្ថលេខាខាងក្រោមឈ្មោះ.......បសុពេទ្យពិនិត្យអនាម័យ នៅទីសត្តឃាត.............បញ្ជាក់ថាបានពិនិត្យសព្វគ្រប់ ៖
- គោឈ្មោល..........ឬមេ .............. ទំងន់ពិត ............................
- កូនគោ.................................... ទំងន់ពិត ............................

- ជ្រូក....................................... ទំងន់ពិត ............................
- ចៀម និងពពែ .......................... ទំងន់ពិត ............................
- គ្រឿង ....................................... ទំងន់ពិត ............................

ផលិតផលទាំងអស់ខាងលើនេះ បានមកពីសត្តឃាតឈ្មោះ ......... ជាឈ្មួញកាប់សាច់ ដែលបានមកប្រកាសប្រាប់ថា៖ ទើបតែបានដឹកនាំមកដល់ក្នុងពេលនេះ ហើយមានភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រ័បញ្ជាក់អនាម័យចេញដោយឈ្មោះ ....... ទីលំនៅ ......។ ផលិតផលទាំងអស់ត្រូវបានទទួលស្គាល់ថា មានគុណភាពល្អសំរាប់ប្រើប្រាស់ជាម្ហូបអាហារ ហើយត្រូវបានកត់ត្រាសំគាល់ដូចមានគំរូបោះត្រាជូនជ្រាបស្រាប់ នូវទំព័រខាងខ្នងនៃវិញ្ញាបនបត្រ័នេះ។ វិញ្ញាបនបត្រ័នេះត្រូវបានចេញឱ្យឈ្មោះ ...........ជាឈ្មួញកាប់សាច់ដើម្បីផ្តល់ ជូនទីស្តីការបេសុពេទ្យពិនិត្យអនាម័យ។

ធ្វើនៅថ្ងៃ ..........ទី .............ឆ្នាំ ..........

ហត្ថលេខ

## ៧.វិធានការអនុវត្តន៍នៅពេលពិនិត្យសត្វរស់

ជាទូទៅគ្រប់សត្វរស់សម្រាប់ពិឃាដ ត្រូវតែបង្ហាញនូវសញ្ញាធម្មតារបស់សុខភាព (ល្អ) នៃដំណើរការល្អរបស់សរីរាង្គសត្វ គ្រប់សញ្ញាខុសប្លែកពីធម្មតា ទាមទារចាំបាច់ដាក់ការមន្ទិលសង្ស័យ។ ដើម្បីឱ្យការពិនិត្យសត្វរស់ប្រព្រឹត្តទៅសព្វគ្រប់យើងត្រូវបំពេញការងារពិនិត្យដូចតទៅ ៖

- ទិដ្ឋភាពខាងក្រៅទូទៅ (ជំងឺសើស្បែក)
- ជំហរ ,រូបរាង ,អាកប្បកិរិយា
- ចង្វាក់ដង្ហើមរបស់សត្វ (សត្វគ្រុន )
- មាត់ (ជំងឺប៉េស្ត )
- ភ្នែក (ក្រហម មានហៀរទឹកភ្នែក)
- ប្រហោងផ្លូវរំលាយ (រលាកពោះវៀន) និងប្រហោងផ្លូវបន្តពូជ (រលាកស្បូន )
- ចំពោះជ្រូករស់ គេត្រូវពិនិត្យមើលបើមានស្នាមជាំ ឬអុជក្រហមលើខ្លួនជាទូទៅ គឺជាសញ្ញាគួរឱ្យសង្ស័យនៃជំងឺដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស។
- ការពិនិត្យកូនកណ្តុរផ្នែកខាងក្រៅ គឺគេមើលទំហំរបស់វា បើកាលណាកូនកណ្តុរ ទាំងនោះមានទំហំខុសពីធម្មតា គឺជាសញ្ញាដែលសង្ស័យថាមានជំងឺផ្សេងៗ និងត្រូវតែយកចិត្តទុកដាក់នៅពេលពិនិត្យសាច់។ ប៉ុន្តែកាលណាសត្វស្គមពេក កូនកណ្តុរក៏ រីកធំដែរ។

ក្រោយពេលពិនិត្យឃើញថា សត្វមានសុខភាព ក៏នៅមានករណីផ្សេងទៀតដែលតែងជួបប្រទះ ៖

**៧.១ ករណីសត្វមានរបួស ឬគ្រោះថ្នាក់** ៖ សត្វមានរបួស ឬគ្រោះថ្នាក់ (ដូចជាបាក់ឆ្អឹង ចេញឈាមបណ្តាលមកពីការទង្គិចរថយន្ត) អាចអនុញ្ញាតឱ្យពិឃាដភ្លាម។ ក្រោយពីការពិនិត្យភ្លាមដោយយកកំដៅ (សីតុណ្ហភាពនៅក្នុងខ្លួនសត្វ ) សត្វនឹងត្រូវបញ្ជូនទៅទីសត្តឃាតជាបន្ទាន់។ ការពិនិត្យសាច់ត្រូវអនុវត្តរយៈពេល២ទៅ៣ម៉ោងក្រោយពីការពិឃាដ ដើម្បីធ្វើឱ្យរោគសញ្ញាកាន់តែលេចចេញច្បាស់លាស់លើផ្ទាំងសាច់។

**៧.២ ករណីសត្វហេវហត់ ៖** បណ្តាលមកពីការដឹកជញ្ជូនតាមផ្លូវឆ្ងាយ ឬបណ្តាលមកពីអាកាសធាតុក្តៅពេក រឺមកពីសត្វគរលើគ្នាក្នុងពេលដឹកជញ្ជូន។ ចាំបាច់ត្រូវឱ្យសត្វសម្រាកក្នុងរយៈពេល១ - ២ថ្ងៃដោយ ផ្តល់ទឹក និងចំណីឱ្យបានល្អមុនពេលពិឃាដ ដើម្បីទទួលបានសាច់មានគុណភាពល្អ។

**៧.៣ ករណីសត្វឈឺជំងឺឆ្លង និងមិនឆ្លង ៖** សត្វឈឺត្រូវពិឃាដភ្លាមៗ ក្រោយពេលពិឃាដរួចគេត្រូវទុកសាច់មួយរយៈពេលសិនគឺ២-៣ ម៉ោងមុនពេលពិនិត្យ។ ក្នុងការពិនិត្យផ្ទាំងសាច់ ភ្នាក់ងារត្រួតពិនិត្យ ត្រូវពិនិត្យឱ្យបានហ្មត់ចត់។ ករណីសង្កេតឃើញសាច់មានកើតជំងឺឆ្លង ៖ ដូចជាជំងឺរាគឈាម ឈាមខ្មៅ អុតក្តាម និងជំងឺសារទឹក ត្រូវប្រកាសភាពអាសន្ន ដើម្បីមានវិធានការជួយធ្វើអន្តរាគមន៍ដល់កន្លែងកើតជំងឺ។

**៧.៤ ករណីសត្វសង្ស័យថាកើតជំងឺ ៖** ចំពោះសត្វសង្ស័យថាកើតជំងឺ តែមិនទាន់បង្ហាញច្បាស់លាស់នូវរោគសញ្ញាយើងត្រូវបង្ខាំងវាទុកមួយកន្លែងសិន ឱ្យឆ្ងាយដាច់ពីគេ។ ត្រូវជៀសវាងការបញ្ចេញសត្វនោះទៅវិញខ្លាចពួកឈ្មួញលួចលក់ ឬយកទៅពិឃាដកន្លែងផ្សេងទៀត។ ប៉ុន្តែនៅថ្ងៃក្រោយមកសត្វមានភាពប្រក្រតីឡើងវិញនោះ យើងកំនត់ថាសត្វមានសុខភាពល្អ តែផ្ទុយទៅវិញ បើជំងឺឆ្លងកើតមានឡើងយើងត្រូវអនុវត្តដូចករណីសត្វឈឺ។ ករណីម្ចាស់សត្វលួចកាប់ក្រៅពីកន្លែងសត្តឃាតដោយមិនបានពិនិត្យសត្វរស់ ភ្នាក់ងារត្រួតពិនិត្យត្រូវបញ្ជាឱ្យយកសាច់មកបង្ហាញទាំងអស់។ ក្នុងករណីបើគ្រឿងក្នុងមិនបានយកមកបង្ហាញទេនោះ ត្រូវរឹបអូសយកទាំងអស់។

## ៨.បច្ចេកទេសពិនិត្យសត្វរស់

ការពិនិត្យសត្វរស់មុនពេលពិឃាដ គឺជាការចាំបាច់បំផុត ពីព្រោះវាអាចឱ្យយើងជៀសផុតនូវផលវិបាក ឬគ្រោះថ្នាក់ដែលនឹងអាចកើតមានឡើង ប្រសិនបើរយៈកាល២៤ម៉ោងមុនពិឃាដ សត្វបានបង្ហាញនូវសញ្ញាសុខភាពល្អ ម៉្យាងទៀតយើងត្រូវពិនិត្យ បើសិនជាភិនភាគសត្វដែលបានបង្ហាញវាសមស្របទៅនឹងប័ណ្ណសំគាល់ភិនសត្វ។ ការពិឃាដសត្វនៅទីសត្តឃាតមិនអាចអនុញ្ញាតឡើយ ចំពោះសត្វដែលលួចឬមកពីប្រភពសង្ស័យ ក្នុងករណីមានជំងឺឆ្លងរាតត្បាតយើងត្រូវដឹងច្បាស់លាស់នូវឈ្មោះម្ចាស់សត្វនិងប្រភពសត្វ។

- ការចាំបាច់ គឺគេត្រូវតែយកសត្វដែលវាដេកឱ្យងើបឈរ និងសត្វបាក់ជើងឱ្យវាដើរ ដើម្បីពិនិត្យនិងវិនិច្ឆ័យទៅលើស្ថានភាពសុខភាពរបស់វា។ គេត្រូវយកចិត្តទុកដាក់លើជំហរ រូបរាង អាកប្បកិរិយាពេលវាឈរ ឬដើរ ពិនិត្យលើផ្ទៃដងខ្លួន ស្បែក រោម កំដៅខាងក្រៅ សរីរាង្គសម្រាប់ដកដង្ហើមច្រមុះ ចលនាដង្ហើម សរីរាង្គសម្រាប់រំលាយអាហារបបូរមាត់ មាត់ ការទំពាអៀងលាមក និងសរីរាង្គបន្តពូជ។ ទន្ទឹមនេះ គេពិនិត្យលើភេទសត្វ ពីព្រោះការពិឃាដសត្វញី គោក្របី ត្រូវហាមឃាត់ដាច់ខាតនៅកន្លែងពិឃាដសត្វតាមជនបទ ដោយមិនគិតពីអាយុឡើយ។
- គេត្រូវប្រុងប្រយ័ត្នដោយលក្ខណៈប្លែកៗពីគ្នា ទៅតាមប្រភេទសត្វ និងផ្នែកដងខ្លួន ដែលញឹកញាប់កើតជំងឺធម្មតា ពិសេសជំងឺឆ្លង។ ដើម្បីធ្វើការវិនិច្ឆ័យឱ្យបានល្អចំពោះសត្វរស់ គេត្រូវដើរក្រឡឹងមើលជុំវិញខ្លួនសត្វ មើលផ្ទៃមុខវាធ្វើឱ្យវាឈរ និងដើរ។

- តាមធម្មតាសត្វមានសុខភាពល្អ គឺមានជើងរឹងប៉ឹង ទឹកមុខស្រៀមស្ងាត់ ឬស្រស់បស់ ភ្នែកភ្លឺថ្លា មាត់សើមជានិច្ច ស្នែង ឬស្លឹកត្រចៀកមានសភាពក្តៅ ស្បែកទន់ រោមរលោងភ្លឺថ្លា ដកដង្ហើមធម្មតាទៀងទាត់ គ្មានក្អក ជុះអាចម៍ស្រួល មិនរឹងពេកមិនទន់ពេក។
- សត្វមានជំងឺ គឺរំដើបរំដួល មានសភាពព្រួយស្រងូតស្រងាត់ វង្វេង មានការឈឺចាប់ ពិបាកដើរ (ដំណើរទ្រេតទ្រោត) ខ្វិនជើង ឬបាក់ជើង មិនអាចងើបឈរបាន ច្រមុះស្ងួត ស្លឹកត្រចៀក ឬស្នែងក្តៅខ្លាំង ឬជួនកាលត្រជាក់ស្រើត ក្អកញ៉ឹកញាប់ ស្បែកជាប់ឆ្អឹងជំនីស្ងួតរឹង រោមបាស់ជ្រោង ស្គាំងស្គម ហៀរទឹកមាត់ច្រើន រាគអាចម៍ ទល់លាមក លាមកមានសភាពស្ងួត ពិបាកជុះ ពេលជុះសត្វមានការឈឺចាប់។
- ចំពោះគោក្របី គេត្រូវប្រុងប្រយ័ត្នចំពោះជំងឺប៉េស្តគោ ជំងឺសារទឹក ជំងឺឈាមខ្មៅ ជំងឺបូសខ្យល់ និងជំងឺផ្សេងៗទៀតដែលមានគ្រុនក្តៅ ជំងឺដោះ ជំងឺផ្លូវរន្ធគូទ ជំងឺពោះវៀន ជំងឺសន្លាក់។
- ចំពោះកូនគោ គេត្រូវគិតទៅដល់ជំងឺរាគរូស ជំងឺទងផ្ចិត ឬបណ្តាជំងឺទូទៅផ្សេងៗទៀតដែលមានគ្រុនក្តៅ។
- ចំពោះជ្រូក គេត្រូវប្រុងប្រយ័ត្នលើប្រភេទជំងឺក្រហម ជំងឺកញ្ជ្រិល ជំងឺប៉េស្ត ជំងឺហើមស្ងួត ជំងឺរលាកពោះវៀន ជំងឺសាម៉ូណែឡូស និងជំងឺរបេង។

## ៩.វិធានការក្រោយពេលពិនិត្យសត្វរស់

**៩.១ ការហាមឃាត់ពិឃាដ ៖** ត្រូវហាមឃាត់ក្នុងករណី ជំងឺប៉េស្តគោ ជំងឺសារទឹក ជំងឺបូសខ្យល់ ជំងឺឈាមខ្មៅ ជំងឺធ្លូត និងជំងឺកញ្ជ្រិល លុះត្រាតែមានការសង្ស័យលើជំងឺណាមួយក្នុងចំណោមជំងឺទាំងនេះ។ ការពិឃាដគោក្របីញីត្រូវហាមឃាត់ដោយមិនគិតពីអាយុឡើយ គឺក្នុងគោលបំណងថែរក្សា ហ្វូងសត្វឱ្យបានគង់វង្ស និងរីកចំរើនតទៅមុខ។ ម៉្យាងទៀតការពិឃាដត្រូវហាមឃាត់ លុះត្រាតែសត្វស្ថិតក្នុងសភាពស្គាំងស្គមខ្លាំង ពីព្រោះសត្វគ្របដណ្តប់នៅសល់តែស្បែក និងឆ្អឹងប៉ុណ្ណោះ ដែលមិនអាចយកសាច់ហូបបាន។ ជួនកាលបើសិនជាភាពស្គាំងស្គមមិនខ្លាំងប៉ុន្មានទេ ហើយមិនបណ្តាលឱ្យ សភាពជំងឺមានលក្ខណៈធ្ងន់ធ្ងរ ឬសត្វមិនមានមេរោគឆ្លង គឺយើងអនុញ្ញាត្តឱ្យពិឃាដ។

**៩.២ ការពិឃាតជាបន្ទាន់ ៖** ការពិឃាតអាចអនុញ្ញាត្តជាបន្ទាន់ នៅពេលសង្កេតឃើញជំងឺ ឬគ្រោះថ្នាក់មិនដឹងមុន លុះត្រាតែយើងសម្រេចចុងក្រោយទៅលើស្ថានភាពសុខភាព ឬសាច់ដែលអាចហូបបានក្រោយពីការពិចារណាដ៏ហ្មត់ចត់បំផុត។ ហេតុដូច្នេះ ជាទូទៅគេត្រូវគិតគូរសម្របសម្រួលថ្លឹងថ្លែងរវាងផលប្រយោជន៍ផ្នែកអនាម័យរបស់អ្នកហូបចុក និងផលប្រយោជន៍ផ្នែកពាណិជ្ជកម្មរបស់ម្ចាស់សត្វ។ ការពិឃាតជាបន្ទាន់នេះនឹងអនុញ្ញាត្តក្នុងករណីសត្វបាក់ឆ្អឹង ឬរបួសធ្ងន់ធ្ងរ ហើមពោះ ថប់ដង្ហើម និងក្នុងករណីពិបាកកើត ឬក៏គ្រោះថ្នាក់កើតមានឡើងមិនហួសពី៦ម៉ោង។ ទន្ទឹមនឹងនេះ គេអនុញ្ញាត្តអឱ្យពិឃាដជ្រូកជាបន្ទាន់ នៅពេលសត្វរងគ្រោះដោយសារការដឹកជញ្ជូនមិនសមស្រប និងដោយសារធាតុអាកាសក្តៅខ្លាំង ឬមានខ្យល់ព្យុះខ្លាំង។

## ១០.ការរៀបចំសត្វសម្រាប់ពិឃាដនៅទីសត្តឃាត និងលទ្ធផល

ដើម្បីបានផលិតផលសាច់ដែលមានគុណភាពខ្ពស់ និងធ្វើឱ្យសត្វបង្កើតឡើងនូវគ្លីកូសែន នៅក្នុងសាច់ដុំរបស់វា ដោយធានាបាននូវគុណភាពសាច់សម្រាប់បរិភោគ។ ជាចាំបាច់អ្នកពិឃាដសត្វត្រូវយល់ដឹងអំពីវិធីសាស្ត្រក្នុងការពិឃាដសត្វ។

**១០.១ គោលការណ៍ ៖** មុនពេលសំលាប់សត្វត្រូវសំអាងលើគោលការណ៍

- បង្អត់ចំណីតែឱ្យសត្វផឹកទឹកដោយសេរី
- ធ្វើអនាម័យចំពោះអ្នកសំលាប់ សំភារៈសំរាប់ប្រើប្រាស់ ទីកន្លែងសំលាប់ដើម្បីកុំឱ្យមានមេរោគ ពីខាងក្រៅឆ្លងចូលទៅក្នុងផលិតផលសាច់សត្វ។
- ចាក់ករបង្ហូរឈាម កាត់ក្បាល កោសរឺបោចរោម ចៀយកស្បែក
- វះយកគ្រឿងក្នុងចេញ ពុះសាច់កាកាសជាពីរ

**១០.២ វិធីសាស្ត្រពិឃាដសត្វស្លាប ៖** ចំពោះសត្វស្លាបមុន និងពិឃាដយើងត្រូវបង្អត់ចំណីអាហារវាពី៦ទៅ៨ម៉ោង ដើម្បីសំអាតប្រព័ន្ធអាហាររបស់សត្វ ម៉្យាងកុំឱ្យនៅពេលពិឃាដ វាធ្វើឱ្យមានភាពក្រខ្វក់ ប៉ុន្តែអាចឱ្យផឹកទឹកដោយសេរី។ ការពិឃាដសត្វធ្វើឡើងដោយប្រព័ន្ធច្រវ៉ាក់ដែលអាចពិឃាដសត្វបានច្រើនក្បាល ក្នុងរយៈពេលខ្លី។ សត្វស្លាបដែលយើងយកវាទៅពិឃាដជាដំបូងយើងត្រូវចាប់ព្យួរវានឹងប្រព័ន្ធច្រវ៉ាក់ដោយដាក់ក្បាលចុះក្រោម ឯជើងឡើងលើ ហើយប្រព័ន្ធច្រវ៉ាក់វិលទៅមុខដោយនាំសត្វឆ្លងកាត់ចរន្តអគ្គីសនីធ្វើឱ្យ សត្វសន្លប់បន្ទាប់មកត្រូវអាកបង្ហូរឈាម ប្រព័ន្ធច្រវ៉ាក់វិលជុំវិញអាងស្តុកឈាមក្នុងរយៈពេល១,៣-២នាទី។ ក្រោយពីសំរក់ឈាមសត្វត្រូវឆ្លងកាត់អាងទឹកក្តៅដែលមានសីតុណ្ហភាពអាស្រ័យទៅតាមប្រភេទសត្វ អាយុ ទំហំ និងទំងន់របស់សត្វ។ សំរាប់សត្វមាន់មានអាយុចាប់ពីជាង២ខែទៅទឹកក្នុងអាងត្រូវមានសីតុណ្ហភាពពី៥១-៥៤ អង្សារ ហើយសត្វត្រូវឆ្លងកាត់អាងទឹកក្តៅនេះរយៈពេល ៣០វិនាទីទៅ៨០វិនាទីឡើង ពីអាងទឹកក្តៅសត្វត្រូវឆ្លងកាត់ជាបន្តទៅដល់ឧបករណ៍បោចរោមដោយស្វ័យប្រវត្តិដែលជាដុំវិលធ្វើអំពីកៅស៊ូក្រោយពីបោចរោមរួចស្អាតគេត្រូវវះសាច់បារយកគ្រឿងក្នុងចេញ និងកាត់ក្បាលសត្វចេញជាការស្រេច។

**១០.៣ វិធីសាស្ត្រពិឃាដសត្វជ្រូក ៖** នៅមុនពេលពិឃាដសត្វជ្រូកមួយថ្ងៃ គេត្រូវបង្អត់ចំណីអាហារដើម្បីសំអាតប្រព័ន្ធរំលាយអាហារធ្វើឱ្យមានភាពស្អាតនៅពេលពិឃាដ ប៉ុន្តែគេឱ្យផឹកទឹកដោយគ្មានកំណត់ ជាបន្ទាប់មកគេត្រូវដេញឱ្យសត្វឡើងលើបន្ទះដែកដែលមានតភ្ជាប់ដោយចរន្តអគ្គីសនីសំរាប់ធក់ ធ្វើឱ្យសត្វសន្លប់រួចហើយគេចាប់ជ្រូកព្យួរជើងក្រោយទាំងពីរឡើងលើសំយុងក្បាលចុះក្រោមដើម្បីចាក់ករបង្ហូរឈាមធ្វើយ៉ាងណាឱ្យឈាមហូរចេញអស់ពីខ្លួនសត្វ គឺដើម្បីឱ្យសាច់មានគុណភាពល្អ។ ជាបន្តគេជ្រលក់ទៅក្នុងអាង ទឹកក្តៅដែលដែលជាការលាយរវាងទឹកដាំពុះ និងទឹកត្រជាក់ឱ្យល្មមដើម្បីងាយស្រួលក្នុងការកោសរោមសត្វចេញអស់រួចហើយកាត់ក្បាលចេញពីដងខ្លួន និងវះយកគ្រឿងក្នុងចេញព្រមទាំងពុះសាច់កាកាសជាពីរ។

**១០.៤ វិធីសាស្ត្រសំលាប់គោក្របី ៖** នៅមុនពេលសំលាប់គោក្របីយើងត្រូវបង្អត់ចំណីអាហារ

រយៈពេល២៤ម៉ោងជាមុនសិនប៉ុន្តែអាចឱ្យសត្វផឹកទឹកបានដោយសេរីរហូតដល់ពេលពិឃាដ។ ក្រោយមកគេដេញសត្វឱ្យឡើងលើបន្ទះដែកអគ្គីសនីវាឆក់ ធ្វើឱ្យសត្វសន្លប់។ ពេលសត្វសន្លប់ហើយគេព្យួរជើងក្រោយសត្វឡើងលើ ហើយចាក់ករសត្វបង្ហូរឈាមរហូតដល់អស់ ទើបកាត់ក្បាលសត្វចេញហើយពន្លាត់ចៀរយកស្បែកចេញពីខ្លួនសត្វ ជាបន្តត្រូវវះយកគ្រឿងក្នុងចេញ ហើយពុះសាច់កាកាសជាពីរ។

**១០.៥ ការរៀបចំសត្វសម្រាប់ពិឃាតនៅទីសត្តឃាត ៖** សត្វនៅទីសត្តឃាតមុនពេលពិឃាដត្រូវបានភ្នាក់ងារបសុពេទ្យត្រួតពិនិត្យសុខភាព និងរៀបចំសត្វសម្រាកឱ្យបានសមស្រប ព្រោះសត្វដែលហេវហត់បាក់កំលាំង ផ្តល់សាច់មានគុណភាពអន់ថយ គឺសាច់ពណ៌ខ្មៅ ឆាប់ស្អុយរលួយ។ ការពិឃាដសត្វសម្រាប់យកសាច់មានចំនុនសំខាន់ៗបីគឺ ៖

- ការបង្ហូរឈាម ៖ ការបង្ហូរឈាមត្រូវធ្វើឱ្យបានឆាប់រហ័សភ្លាមៗ និងទាន់ពេលវេលា ដើម្បីសម្រួលដល់ការថែរក្សាគុណភាពសាច់ឱ្យបានល្អ។
- ធ្វើយ៉ាងណាឱ្យសត្វនៅស្ងៀម ក្នុងគោលបំណងធានាការពារដល់បុគ្គលិកកម្មករបំរើការនៅទីសត្តឃាត និងជៀសវាងកុំឱ្យមានគ្រោះថ្នាក់ដល់មនុស្សព្រមទាំងសត្វផ្សេងៗទៀត។
- បន្ថយការឈឺចាប់ និងការភ័យខ្លាចដល់សត្វ ដើម្បីកុំឱ្យសត្វដឹងខ្លួននៅមុនពេលពិឃាដ។

**១០.៦ ប្រតិបត្តិការនៃការពិឃាដរួមមានច្រើនតំណាក់កាល ៖**

**ក.ការធ្វើអោយសន្លប់ ឬវង្វេងបាត់ស្មារតី** គឺជាកិច្ចការមួយសំដៅធានាកុំឱ្យសត្វមានការឈឺចាប់ ពីព្រោះការពិឃាដដោយអារកសត្វរស់ គឺជាគ្រោះថ្នាក់សម្រាប់អ្នកពិឃាដ ហើយការងារចាំបាច់ទាម ទារនូវមនុស្សធម៌ សន្តិសុខ និងសេដ្ឋកិច្ច មុនពេលអារក ឬចាក់ក គេអនុវត្តធ្វើឱ្យសត្វសន្លប់ដោយប្រើ ៖

- ខ្សែភ្លើងឆក់ ៖ គឺលទ្ធផលល្អ បើយើងរៀបចំចរន្តភ្លើងបានល្អ ហើយចាក់បានយ៉ាងរហ័ស បើមិនដូច្នោះទេ គេសង្កេតឃើញមានអុជជាំកន្ទួល និងចេញឈាមខាងក្នុងដោយសារដាច់សរសៃកាពីលែ ដែលធ្វើអោយសាច់មានការខូចខាតគុណភាពយ៉ាងធ្ងន់ធ្ងរ ហើយក្លាយទៅជាកន្លែងដែលឆ្លងមេរោគ។
- ញញួរឬពូថៅ ៖ សត្វបំរះននៀលយ៉ាងត្រដាបត្រដួស ហើយអស់ជាតិបំរុងគ្លីកូសែន។
- អាវុធខ្លី ៖ គេប្រើប្រាស់អាវុធខ្លីសម្រាប់ពិឃាដ។

**ខ.ការពិឃាតដោយចាក់ក** (ចាក់សរសៃបញ្ចេញឈាម) គឺជាការងារសំដៅទៅលើការផ្តាច់សរសៃឈាមបំពង់ក ដើម្បីធ្វើឱ្យឈាមហូរអស់ពីក្នុងខ្លួន។ ការពិឃាដដោយចាក់បំពង់កនេះ ជួបប្រទះការលំបាកមិនអាចធ្វើបានល្អនោះទេ ដោយសារការអារស្បែក ឬពន្លាត់ស្បែកនឹងកាំបិតមានការបំពុលរួចហើយ (Pollution) និងមានបាក់តេរីយ៉ាងច្រើនដែលបានបញ្ចូលទៅក្នុងដំណើរឈាមរត់។ ហេតុដូច្នេះហើយស្បែកសត្វត្រូវមានការចំលងរោគដោយបាក់តេរី មេតំបែ និងពពួកផ្សិត ដែលគេឃើញមាននៅក្នុងចំបើង,ដី និងក្នុងលាមក។ មុនពិឃាតគេត្រូវលាងខ្លួនសត្វ ប៉ុន្តែជាតិសើមនៃស្បែកប

ណ្តាលឱ្យបាក់តេរីលូតលាស់ឡើងនៅពាសពេញស្បែក បើសិនជាការលាងទឹកប្រព្រឹត្តទៅច្រើនម៉ោង មុនពេលពិឃាដ។ ក្រោយពីធ្វើឱ្យសត្វស្លាប់នៅពេលចាក់ក បេះដូងសត្វនៅដំណើរការរហូតដល់៩នាទី។ តាមការពិត ទោះបីជាការចាក់កអនុវត្តល្អឥតខ្ចោះក៏ដោយ ក៏គេមិនអាចធ្វើឱ្យឈាមហូរចេញអស់ពីក្នុង ខ្លួនសត្វដែរ។ ជានិច្ចកាលឈាមនៅសល់មួយចំនួនក្នុងសរសៃឈាម ដែលបង្កឡើងនូវផ្លូវជ្រៀតចូលសម្រាប់ការចំលងមីក្រុប។

# ជំពូកទី២ ការត្រួតពិនិត្យអនាម័យគ្រឿងឧបភោគ-បរិភោគ

## ១.សេចក្តីផ្តើម

អ្វីទៅដែលហៅថាសាច់ សាច់ គឺជាម្ហូបអាហារដែលមានសារៈសំខាន់បំផុតសម្រាប់មនុស្ស ដោយវាផ្តល់នូវប្រូតេអ៊ីន ជីវជាតិ និងវីតាមីនមេ។ យើងអាចកែច្នៃសាច់ឲ្យទៅជាគ្រឿងម្ហូបអាហារសម្រាប់បរិភោគផ្សេងៗទៀតជាច្រើន។ ការត្រួតពិនិត្យម្ហូបអាហារដែលមានដើមកំណើតពីសត្វ គឺជាការរួមចំណែកមួយ ដើម្បីទប់ទល់នឹងជំងឺឆ្លងរាតត្បាតផ្សេងៗកុំឲ្យឆ្លងរាលដាលទៅមនុស្សតាមរយៈផលិតផលទាំងនោះ ការត្រួតពិនិត្យអនាម័យម្ហូបអាហារទាំងនោះរួមមាន ៖

- ការត្រួតពិនិត្យសាច់
- ការត្រួតពិនិត្យផលិតផលទឹកដោះ
- ការត្រួតពិនិត្យផលិតផលដែលមានដើមកំណើតពីសត្វ
- ការត្រួតពិនិត្យផលិតផលសមុទ្រ និងមច្ឆាជាតិ
- ការត្រួតពិនិត្យគ្រឿងឧបភោគបរិភោគកែច្នៃនៃផលិតផលខាងលើ

## ២.គោលបំណង

ការត្រួតពិនិត្យអនាម័យសាច់មានគោលបំណង ៣ចំណុចដែលត្រូវចងចាំ ៖

- ការពារសុខភាពសាធារណៈ អ្នកបរិភោគឲ្យបានល្អ ដោយរាំងស្កាត់មិនឲ្យបរិភោគផលិតផលដែលមានគ្រោះថ្នាក់។ មិនអនុញ្ញាតដាច់ខាតនូវផលិតផលទាំងឡាយណា ដែលក្លាយជាបុព្វហេតុចំលងជំងឺដល់មនុស្ស ឬប្រភពរីកសាយភាយនៃជំងឺឆ្លង។
- ការពារសុខភាពសត្វ និងមនុស្ស ដោយស្រាវជ្រាវរកឃើញនូវជំងឺឆ្លងផ្សេងៗ នៅតាមទីសត្តឃាតបានបង្ហាញបញ្ជាក់ពីតំបន់ដែលសត្វទាំងនោះបានដឹកជញ្ជូនមកកាន់ទីសត្តឃាតដ្ឋាន។
- ធានាភាពសុចរិតត្រឹមត្រូវរបស់អ្នកលក់សាច់ ចំពោះអ្នកបរិភោគ ធានាផលិតផលម្ហូបអាហារមានគុណភាពខ្ពស់ ដែលមិនមានកើតជំងឺឆ្លង និងជំងឺផ្សេងៗ។

## ៣.សំភារៈប្រើប្រាស់សំរាប់ពិនិត្យអនាម័យសាច់

សំភារៈប្រើប្រាស់សំរាប់ពិនិត្យសាច់រួមមាន ៖

**៣.១ អាវប្លូស្សពណ៌ស** ដែលភ្នាក់ងារត្រួតពិនិត្យត្រូវពាក់សំរាប់ការពារការប្រឡាក់ ដែលមិនអាចជៀសផុតនៅពេលត្រួតពិនិត្យ ឬគេអាចប្រើអៀមក៏បានដែរបើគ្មានអាវប្លូស្ស។ សំលៀកបំពាក់ទាំងនេះត្រូវស្អាតជានិច្ច និងត្រូវផ្លាស់ប្តូរឲ្យបានញឹកញាប់។

**៣.២ ស្បែកជើងកវែង និងស្រោមដៃ** ប្រើជាតិកៅស៊ូដើម្បីងាយស្រួលក្នុងការលាងសំអាត ។

**៣.៣ ប្រដាប់ស្ទង់កំដៅ** គឺប្រើសំរាប់ពិនិត្យសត្វរស់ ដូចជាសត្វមានគ្រោះថ្នាក់.ឈឺឬសង្ស័យថាមានជំងឺមុនពេលពិឃាតភ្លាមៗ។

**៣.៤ កាំបិតសំរាប់ពិនិត្យសាច់** គឺគេត្រូវប្រើកាំបិតដែលមានមុខវែង.ស្រួចហើយមុត ជាការចាំបាច់បំផុតកាំបិតត្រូវលាងឲ្យបានស្អាតនឹងសាប៊ូរួចសំលាប់មេរោគដោយប្រើអាល់កុល៧០ដឺក្រេក្រោយការវះកាត់រួច។

**៣.៥ ពិលឬហ្វា** គឺប្រើនៅពេលពិនិត្យផ្ទាំងសាច់ គ្រឿងក្នុង និងគ្រឿងបន្ទាប់បន្សំ ព្រោះការពិនិត្យត្រូវការពន្លឺភ្លឺច្បាស់។

**៣.៦ ប្រដាប់បោះត្រា** ប្រដាប់បោះត្រា ជាទូទៅគេប្រើត្រាបោះ និងត្រាអូស។ ត្រាបោះត្រូវ ធ្វើពីស្ពាន់ មិនត្រូវប្រើប្រាស់ត្រាធ្វើពីកៅស៊ូឡើយ ព្រោះខ្លាញ់សត្វអាចធ្វើអោយកៅស៊ូរលាយបាន។ ត្រាអូសធ្វើពីស្ពាន់មានឆ្លាក់អក្សរថាសាច់ស្អាត ត្រាអូសនេះអាចអូសបានរហ័ស ប៉ុន្តែទាមទារការថែទាំឲ្យបានល្អ។ ចំពោះទឹកខ្មៅសំរាប់ប្រើប្រាស់បោះត្រា គឺធ្វើឡើងពីវត្ថុជាតុពិសេស ហើយមើលបានច្បាស់ និងជាប់បានយូរ គ្មានជាតិពុល។ គប្បីប្រើទឹកខ្មៅដូចខាងក្រោម ៖

រូបមន្តទឹកខ្មៅពណ៌ខៀវ

- ប៊្លូមេទីឡែន ៧ក្រាម

រូបមន្តទឹកខ្មៅពណ៌ក្រហម

- ថ្នាំក្រហម Fuchsine ៧ក្រាម
- អាល់កុល ៩០$^0$ ១០០ក្រាម
- glycerin ៥០ក្រាម
- ទឹក $H_2O$ ៥០០ក្រាម

**៣.៧ ប្រដាប់លាង ឬចានដែក** ជាការចាំបាច់បំផុតដែលត្រូវលាងដៃ និងសំភារៈក្រោយពេលពិនិត្យរួច។ ចំពោះដៃដែលប៉ះពាល់សាច់ ឬវត្ថុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ យើងត្រូវរំងាប់មេរោគឲ្យបានស្អាតដោយប្រើអាល់កុល១០០%។

**៣.៨ សំភារះប្រើប្រាស់បន្ទាប់បន្សំ**

- សំភារៈសំរាប់យកវត្ថុវិភាគ និងចាំបាច់សំរាប់ក្នុងការវះកាត់ដូចជា ៖ ដប,កែវ,កញ្ចប់,រណា,កាំបិតចៀរក្រចកជើង...។ល។
- សំភារៈប្រើប្រាស់សំរាប់រំងាប់មេរោគមាន ៖ អូតូក្លាវ,ឆ្នាំងស្ងោរ ,សតរេលិសាតរ៉ែ ។
- សំភារៈប្រើប្រាស់ក្នុងមន្ទីរពិសោធន៍មាន ៖ កែវ,ទូរទឹកកក,ជញ្ជីង និងមីក្រូស្កូប។
- សំភារៈការិយាល័យ ៖ បញ្ជីកត់ត្រា,សៀវភៅចុះចំនួនសត្វពិឃាត និងបញ្ជីពន្ធដារ...។

## ៤.ការត្រួតពិនិត្យសាច់

ការត្រួតពិនិត្យ គឺជាបច្ចេកទេសមួយដែលមានបទបញ្ញាចាំបាច់ត្រូវតែពិនិត្យដោយមានអង្គភាពត្រួតពិនិត្យសុខភាពសត្វ និងត្រួតពិនិត្យសាច់ដើម្បីធានាសុខភាពដល់អ្នកហូបចុក។ ការអនុវត្តន៍

កិច្ចការទាំងនោះ ត្រូវទាមទារឲ្យមានការយល់ដឹងច្បាស់អំពី ៖

- ការពិនិត្យសត្វរស់សំរាប់ពិឃាដយកសាច់
- ការពិនិត្យផ្ទាំងសាច់.គ្រឿងបន្ទាប់បន្សំ.សំណល់ចេញពីសត្វ និងផលិតផលដែលបានមកពីវត្ថុធាតុដើមទាំងនេះ។
- ការស្រាវជ្រាវ និងប្រកាសពីជំងឺនានា ដែលចាត់ទុកថាជាជំងឺឆ្លងរាតត្បាត។
- ដកហូតចេញមិនឲ្យបរិភោគនូវម្ហូបអាហារ សាច់សត្វណាដែលមានគ្រោះថ្នាក់ដល់អ្នកហូបចុក
- បោះត្រាលើសាច់សត្វដែលយើងទទួលស្គាល់ថា ជាសាច់ល្អបរិភោគបានសំរាប់អ្នកហូបចុក។

## ៥.ទីកន្លែងត្រួតពិនិត្យ

ការត្រួតពិនិត្យត្រូវតែអនុវត្តន៍ទៅលើគ្រប់សត្វសម្រាប់ពិឃាដយកសាច់ទៅលើម្ហូបអាហារ និងផលិតផលដែលមានដើមកំណើតពីសត្វ ដែលរៀបចំឡើងសម្រាប់ហូបចុក និងសម្រាប់លក់ដូរជាសាធារណៈ ដូច្នេះទីកន្លែងដែលត្រូវត្រួតពិនិត្យរួមមាន ៖

- កន្លែងប្រមូលផ្តុំសត្វ
- ទីសត្តឃាត
- កន្លែងស្តុកសាច់ រោងចក្រត្លាសេ
- រោងចក្រផលិតម្ហូបអាហារមានដើមកំនើតពីសត្វ ដូចជាកន្លែងផលិតម្ហូបកំប៉ុង.ប្រឡាក់ ងៀតជាដើម
- ព្រំប្រទល់ដែនទឹក គោក និងព្រលានយន្តហោះ
- គ្រប់ទីកន្លែងតាំងលក់
- តាមភោជនីយដ្ឋាន និងសណ្ឋាគារ។

## ៦.ម្ហូបអាហារដែលត្រូវត្រួតពិនិត្យ

ការត្រួតពិនិត្យត្រូវអនុវត្តពីះ

- សត្វរស់ (សំរាប់ពិឃាដ)
- សាច់សត្វ.គ្រឿងបន្ទាប់បន្សំ (គ្រឿងក្នុង) និងគ្រឿងសំណល់
- ម្ហូបកែច្នៃពីសាច់ (ដោយមិនគិតថាបរិមាណសាច់តិច ឬច្រើនឡើយ)
- ម្ហូបអាហារផ្សេងៗទៀត ដែលមានដើមកំណើតពីសត្វ (សាច់ក្រក .ប្រហិត .ប៉ាតេ...)
- ទឹកដោះគោ (នៅកន្លែងផលិត និងកន្លែងលក់)
- ស៊ុត (កន្លែងលក់)
- បក្សីស្រុក (ទា.មាន់) ទីសត្តឃាតដ្ឋានមាន់.ទា។

# ជំពូកទី៣ របៀបពិនិត្យសាច់ជ្រូក និងគោ-ក្របី

## ១.សេចក្តីផ្តើម

ជម្ងឺដែលតែងតែជួបប្រទះលើសត្វជ្រូក ដូចជាជម្ងឺសួត របេងប្រដាប់រំលាយអាហារ និងបណ្តាលជម្ងឺក្រហម។

## ២.គោលបំណង

ក្រោយពីរៀនចប់និស្សិត នឹងអាចរៀបរាប់បានពីះ

- ការពិនិត្យសត្វរស់
- ការពិនិត្យសាច់

## ៣.ការពិនិត្យសត្វរស់

នៅពេលពិនិត្យសត្វរស់ត្រូវពិនិត្យមើល

- លិខិតស្នាមផ្សេងៗដែលពាក់ពន្ធ័
- ពណ៌ស្បែក ស្នាមដាំ រឺចេញឈាម ជម្ងឺក្រហម
- ស្ថានភាពនៃប្រដាប់ដកដង្ហើម (ដង្ហក់ខ្លាំង )
- ស្ថានភាពជើង (រលាកសន្លាក់ឆ្អឹងដោយរោគកញ្ជ្រិល)
- គេកត់សំគាល់ភេទសត្វញី រឺឈ្មោល ទំងន់ (បើអាចកំណត់អាយុបើសិនយើងដឹងច្បាស់)

បញ្ជាក់ ៖ ចំពោះជ្រូកបាមិនត្រូវអនុញ្ញាតឱ្យពិឃាដទេ ពីព្រោះសាច់ធំក្លិនអាក្រក់គួរឱ្យខ្ពើមរអើម។

## ៤.ការពិនិត្យសាច់

**៤.១ ការពិនិត្យសួត** ៖ គេពិនិត្យសាច់សួត និងកូនកណ្តុរដើម្បីរកមើលស្នាមដាំ របេងក៏ដូចជាក្នុងករណីមើលជម្ងឺ របេងគេ ពិនិត្យពិច្ច័យលើកូនកណ្តុរទងសួត។

**៤.២ ពិនិត្យបេះដូង** ៖ នៅលើបេះដូងគេពិនិត្យរកមើល ស្នាមដាំ ស្នាមចេញឈាមនៃជម្ងឺក្រហម និងចុងអង្ករ។

**៤.៣ ការពិនិត្យថ្លើម** ៖ គេតែងតែជួបប្រទះនៅក្នុងថ្លើមជ្រូក នូវបរាសិត បូស ស្នាមរបេង និងភាពខូចផ្សេងៗ ដូចជា (ពណ៌មិនធម្មតា ពងតូចល្អិត ពករឹង)។

**៤.៤ ពិនិត្យសន្ទះទ្រូង** ៖ ដើម្បីរកមើលចុងអង្ករ

**៤.៥ ពិនិត្យផាល** ៖ ដើម្បីរកមើលជម្ងឺឈាមខ្មៅ និងរបេង

**៤.៦ ពិនិត្យក្រពះ** ៖ គេពិនិត្យភាគខាងក្រៅនៃក្រពះ និងពិនិត្យកូនកណ្តុរក្រពះ (ត្រង់កន្លែងកោងនៃក្រពះ )ដើម្បីពិនិត្យ មើល ជម្ងឺរបេង ។

**៤.៧ ពិនិត្យពោះវៀន** ៖ ពិនិត្យរកមើលស្នាមរលាកពោះវៀន និងស្នាមដាំដូច្នោះគេត្រូវពិនិត្យកូនកណ្តុរនៃស្រទាប់ស្តើងជាប់ ពោះវៀន(Ganglion mésentérique) ដើម្បីរកមើលជម្ងឺរបេង គួរ

យកចិត្តទុកដាក់ក្នុងករណីរលាកពោះវៀនដែលបណ្ដាលមកពីរ Salmonella អាចបង្ករគ្រោះថ្នាក់ដល់ការហូបចុករបស់មនុស្ស។

**៤.៨ ពិនិត្យក្បាល ៖** គេពិនិត្យកូនកណ្ដុរក្បាលដើម្បី រកមើលរបេង និង ពិនិត្យអណ្ដាតដើម្បីរកមើលចុងអង្ករ។

**៤.៩ ពិនិត្យផ្ទាំងសាច់ ៖** នៅលើស្បែកអាចមានស្នាមជម្ងឺកញ្ជ្រិល

- សាច់ដុំភ្លៅ ចំឡក សាច់ដុំពោះ សន្ទះទ្រូង និងសាច់ដុំស្មាដើម្បីរកមើលចុងអង្ករ។
- ឆ្អឹងជំនី ឆ្អឹងរបាំងទ្រូង និងឆ្អឹងកងដើម្បីរកមើលរបេងឆ្អឹង។

## ៥.ការរៀបចំសាច់ក្រោយពេលពិឃាដរួច(គោ)

គោលការណ៍ក្រោយពីពិឃាដហើយសំដៅទៅលើការវះយកសាច់ ចេញពីគ្រឿងបន្ទាប់បន្សំ និងគ្រឿងសំណល់ ត្រូវបានរៀបចំឱ្យបសុពេទ្យពិនិត្យតាមរបៀបដូចតទៅ ៖

- ក្បាលត្រូវដាក់ផ្ងារឡើងលើ
- ជើងដាក់លើគុ
- ផ្ទាំងសាច់ត្រូវក្អួរកាត់ជា ២ ចំហៀង ឬជាបួនកំណាត់
- គ្រឿងក្នុងផ្នែកទ្រូងរួមទាំងថ្លើម និងផាលត្រូវតែក្អួរ និងទំពក់
- គ្រឿងក្នុងផ្នែកត្រង់ពោះ (ក្រពះ ,ពោះវៀនដាក់ក្នុងធុង)
- ស្បែកទុកដោយឡែក
- ការពន្លាត់ស្បែក (ចំពោះគោ)

## ៦. ផ្ទាំងសាច់ ( carcass )

អ្វីទៅដែលហៅថាផ្ទាំងសាច់ ?

- ចំពោះជ្រូក ផ្ទាំងសាច់ គឺជាសត្វទាំងមូលដែលបានពិឃាដរួច និងកោសរោមរួចហើយ ឬមិនទាន់កោស ដោយមិនបញ្ចូលគ្រឿងក្នុងពោះ គ្រឿងក្នុងប្រអប់ទ្រូង ក្បាល និងជើង ដែលយើងចាត់ទុកថាជាសាច់សុទ្ធសាធ។
- ចំពោះគោ សេះ សត្វទំពាអៀងតូច ផ្ទាំងសាច់មាន២ចំហៀងនៃសត្វដែលបានពន្លាត់ ស្បែករួច ដោយមិនគិតក្បាល ជើង គ្រឿងក្នុងពោះ និងគ្រឿងក្នុងប្រអប់ទ្រូង (ក្នុងនោះក៏មាន តំរងម្ងូត្រដែរ)។

## ៧. ចំណែក ឬផ្នែកទី៥

អ្វីទៅដែលហៅថាផ្នែកទី៥? ផ្នែកទី៥ គឺជាគ្រឿងបន្ទាប់បន្សំ និងគ្រឿងសំណល់ រួមមាន គ្រឿងក្នុងប្រអប់ទ្រូង គ្រឿងក្នុងពោះ អណ្ដាត ក្បាល ស្បែក ឈាម ផ្លោកនោម រោម ស្នែង និងក្រចក។

- ផ្នែកទី៥មានន័យថា ៖ គ្រឿងផលិតផលក្រៅពី២ចំហៀង ចំណែកសាច់នៅទីសត្តឃាត ពេលពិឃាដ និងវះយកសាច់ចេញ ដែលមានគ្រឿងបន្ទាប់បន្សំមួយផ្នែក (ហូបបាន) និងមួយផ្នែកទៀតសំណល់ (ហូបមិនបាន) សំរាប់បម្រើឱ្យវិស័យសិប្បកម្ម និងឧស្សាហកម្ម។ វាមានសារៈ

សំខាន់លើផ្នែកអនាម័យ ការត្រួតពិនិត្យចំណែកទី៥ គឺមានសារៈសំខាន់ណាស់ ពីព្រោះស្លាកស្នាមជំងឺ ផ្ទាំងសាច់មួយចំនួន ស្ថិតនៅញឹកញាប់នឹងចំណែកទី៥នេះ។ វត្ថុធាតុទាំងអស់នៅផ្នែកទី៥ គឺមានការប្រឡាក់ប្រឡូកដូចជាស្បែក ពោះវៀនទាំងមូល ត្រូវតែបំបែកចេញយ៉ាងឆាប់រហ័សបំផុតពីផ្ទាំងសាច់ ហើយត្រូវធ្វើការសំអាតឱ្យបានល្អ។ ចំពោះពាណិជ្ជកម្មវិញ វាមានតួនាទីក្នុងការបង្កើតនូវតំលៃគុណភាពសាច់ មានន័យថា វាមានឥទ្ធិពលលើតំលៃលក់សាច់។ ហេតុដូច្នេះហើយបានជាគេខិតខំផ្សេងៗគ្រប់ផលិតផលទាំងនោះឡើងវិញ ដែលញឹកញាប់គេចាក់ចោលទៅក្នុងលូ ប្រឡាយ ដូចជាឈាម និងក្រពេញ។

- គ្រឿងបន្ទាប់បន្សំ៖ និយមន័យ គឺគ្រប់ចំណែកហូបបានទាំងអស់របស់សត្វ ដែលដាក់លក់នៅតាមតូបលក់សាច់នៅតាមទីផ្សារនានា។ គេបែងចែកគ្រឿងបន្ទាប់បន្សំជា២ផ្នែកគឺ៖ គ្រឿងបន្ទាប់បន្សំក្រហម និងគ្រឿងបន្ទាប់បន្សំស។

+ គ្រឿងបន្ទាប់បន្សំក្រហម ៖ គឺគ្រឿងបន្ទាប់បន្សំសម្រាប់ការហូបចុក ដូចជាអណ្តាត ថ្លើម បេះដូង ស្រោមខួរ សួត ផាល និងតំរងនោម។

+ គ្រឿងបន្ទាប់បន្សំស៖ ត្រូវតែធ្វើការរៀបចំសំអាត ដូចជាដុសលាងជ្រលក់ទឹកក្តៅ រួមមាន ៖ បំពង់រំលាយអាហារ ក្រពះ ពោះវៀន មាត់ ត្រចៀក ដោះ ជើង និងប្លោកនោម។

- សំណល់ គឺជាចំណែកនៃសត្វសម្រាប់បម្រើឱ្យវិស័យសិប្បកម្ម ឧស្សាហកម្ម ទំងន់សំណល់សឹងតែស្មើនឹង១/២នៃទំងន់សាច់សុទ្ធសាធ វាមាន៤០% នៃតម្លៃចំណែកទី៥ ដែលមាន ស្បែក ឈាម ស្នែង ខ្លាញ់ ក្រចក រោម ឆ្អឹង សរីរាង្គបន្តពូជ និងសំណល់ផ្សេងៗទៀត។

+ ស្បែកសំលាប់ ៖ គឺផលិតផលបានមកពីការពន្លាត់ស្បែកបំរើឱ្យវិស័យឧស្សាហកម្ម។

+ ខ្លាញ់ គឺមានខ្លាញ់រាវ និងខ្លាញ់ចំហៀរ ខ្លាញ់គឺមានពីរប្រភេទគឺ៖ ខ្លាញ់សម្រាប់ធ្វើចំណីអាហារ និងខ្លាញ់សម្រាប់ឧស្សាហកម្ម (សាប៊ូ ទៀន ឈើគូស វាយនភ័ណ្ឌ)

+ ឆ្អឹងសម្រាប់ធ្វើម្សៅឆ្អឹងស្រស់

+ ឈាម ៖ គឺជាប្រភពប្រូតេអ៊ីន ជាតិដែក និងអំបិលខនិជ

+ រោមក្រចកស្នែង។

## ៨.ការពិនិត្យ

**៨.១ ការពិនិត្យផ្ទាំងសាច់ ៖** គឺយើងត្រូវធ្វើការវិនិច្ឆ័យលើរូបរាង ទំហំ ប្រភេទ ពណ៌ទូទៅ សភាពសាច់ដុំ សភាពខ្លាញ់ និងស្នាមប្រួសផ្សេងៗ ការពិនិត្យផ្ទាំងសាច់គឺដើម្បី ៖

- រកមើលជម្ងឺរលាកសន្លាក់នៅជង្គង់
- រកមើលក្រែងមានហើម រឺ មានពណ៌លឿងក្នុងករណីមានជម្ងឺលឿង
- សាច់ខូចដែលស្លេកខ្លាំង ក្នុងករណីរោគខ្វះឈាម ករណីឈាមក្រហមក្រម៉ៅ ឬខ្មៅ (ជំងឺឈាមខ្មៅ) មានឈាមកកដោយពេលចាក់បង្ហូរឈាម សត្វជិតងាប់ រឺងាប់ហើយ
- ពណ៌លឿងក្នុងករណីជម្ងឺលឿង គ្មានពណ៌ ជួនកាលពណ៌ប្រផះ ក្នុងករណីស្គាំងស្គមពេក ដំបៅផ្សេងៗនៅក្នុងសួត រលាកទងសួត និងរបេង

- ទិដ្ឋភាពពណ៌ខៀវត្រង់ពោះក្នុងករណីឃើតយ៉ាវ ក្នុងការវះពោះក្នុងករណីនេះវា និងជះក្លិនអាក្រក់
- ទិដ្ឋភាពត្រង់ស្នាមអារ បង្ហូរឈាមបើសិនជាវាមានពណ៌ខ្មៅ រឺមានកំណកឈាមដុំៗត្រូវគិតថាសត្វបានពិឃាដនៅពេលជិតងាប់រឺ មានការបន្លំបង្ហូរឈាមក្រោយពេលសត្វងាប់ហើយ មានដំបៅ និងរបួស។

**៨.២ ពិនិត្យក្បាល និង អណ្តាត ៖**

- ដើម្បីរកមើលចុងអង្គរ ដោយវះកាត់ត្រង់សាច់ដុំថ្គាល់
- ពិនិត្យរកមើលអញ្ចាញធ្មេញ និងមាត់ដើម្បីរកមើលជម្ងឺប៉េស្ត និងអុតក្តាម
- វះមើលកូនកណ្តុរដើមក និងកូនកណ្តុរនៅក្រោមក.ដើម្បីរកមើលជម្ងឺរបេង
- ការពិនិត្យអណ្តាត ដំបូង ពិនិត្យមើលរួចស្ទាប រឺបូតដើម្បី រិះរកមើលនូវជម្ងឺ ចុងអង្គរ រឺដំបៅ នៅកន្លែងខ្លះគេតំរូវឱ្យវះតាមបណ្តោយផ្នែកក្រោម នៃអណ្តាតដើម្បីរកចុងអង្គរ។

**៨.៣ ការពិនិត្យផាល ៖** វាជាការសំខាន់ក្នុងការពិនិត្យផាលដើម្បីស្រាវជ្រាវរកជំងឺឈាមខ្មៅដែលតែងតែជួបប្រទះជារឿយៗ នៅបណ្តាលប្រទេសតំបន់ត្រូពិច។ ដាច់ខាតមិនត្រូវបោះត្រាលើផ្ទាំងសាច់ បើម្ចាស់សាច់មិនបានបង្ហាញឱ្យពិនិត្យទេ។ ស្ទាបផាលដោយដៃទាំងពី ដើម្បីពិនិត្យមើលទ្រង់ទ្រាយទំហំ និងពណ៌សំបុរក្នុងករណីមានកើតជម្ងឺឈាមខ្មៅ ផាលរីកធំហើយមានសភាពស្រួយបើសិនជាផាលយើងវះវានឹងមានទឹកពណ៌ខ្មៅដូចកក់ហូរចេញមក ក្នុងករណីសង្ស័យត្រូវយករូបសំណាកផ្ញើរទៅមន្ទីរពិសោធន៍ ម៉្យាងទៀតជម្ងឺឈាមខ្មៅអាចឆ្លងដល់មនុស្ស។ បើសិនសាច់សត្វកើតជម្ងឺឈាមខ្មៅត្រូវរឹបអូស និងបំផ្លាញចោលបើមានស្លាកស្នាមរបេងនៅផាលត្រូវរឹបអូសទាំងអស់ ក្នុងករណីផាលស្រួយខ្លាំង ប៉ុន្តែគ្មានទឹកពណ៌ខ្មៅហូរចេញដូចករណីជម្ងឺឈាមខ្មៅទេ ត្រូវគិតដល់ជម្ងឺឆ្លងផ្សេងៗ។

**៨.៤ ពិនិត្យសួត ៖**

- សួតត្រូវព្យួរ និងទំពក់ត្រង់បំពង់ខ្យល់ ហើយបែរមុកមករកភ្នាក់ងារត្រួតពិនិត្យ
- ជាដំបូងគេត្រូវពិនិត្យ និងសង្កេតទៅលើផ្ទៃខាងក្រៅគេអាចរកឃើញស្នាមរលាកទងសួតដើម្បី សង្កេតសភាពរួមនៃសួត (ទំហំ.រាងរៅ) ដោយស្ទាប នឹងដៃទាំងពីរ បន្ទាប់មកទៀតគេវះមើលខាងក្នុងបើ សិនជាចាំបាច់
- ដើម្បីរកមើលបូស.គិស្ត ហើមសួត ហើយគេវះកូនកណ្តុរទងសួតដើម្បីរកមើលជម្ងឺរបេង

**៨.៥ ពិនត្យបេះដូង ៖** ជាដំបូងគេពិនិត្យសភាពខាងក្រៅដើម្បីរកមើលជម្ងឺរលាកស្រោមបេះដូង រឺអុចឈាមដែលជាពេគ សញ្ញានៃជម្ងឺឆ្លងមួយចំនួន។

**៨.៦ ពិនិត្យថ្លើម ៖** ក្នុងការពិនិត្យថ្លើមគេដាក់ថ្លើមនៅលើតុ ដោយត្រូវដាក់ផ្នែកខាងក្រោយឡើងលើ ជាដំបូងគេត្រូវពិនិត្យមើលនូវសភាពទូទៅ ពណ៌ រាង សភាពរឹង រឺជ្រាយ រឺផុយ ជាពិសេស ពិនិត្យរកមើលបូស ស្នាមដង្កូវថ្លើម។ ការពិនិត្យលើពណ៌ដើម្បីរកមើល ៖

- ពណ៌លឿងដែលជម្ងឺឆ្លង / ពណ៌ក្រម៉ៅ បណ្តាលមកពីកកឈាម បន្ទាប់មកគេស្ទាប

ដើម្បីពិនិត្យមើលសភាពរបស់វាជួនកាលរឹងមិនអាចហូបបានជួនកាលស្រួយ ជួនកាលជ្រាយផុយបណ្ដាល មកពីជម្ងឺផ្លូងផ្សេងៗ

- ជាទីបញ្ចប់គេវះមើលផ្នែកខាងក្រោយតាមបណ្ដោយរកមើលដង្កូវ នៅក្នុងវន្ទប្រម៉ាត់ ក្រៅពីនេះគេវះពិនិត្យមើលកន្លែងមានសភាពខុសប្រក្រតី(ពណ៌ ពក ហើម និងពករឹង)(គេវះរកមើលស្នាមរបេង ដោយវះកូនកណ្ដុរថ្លើម )

៨.៧ **ពិនិត្យគ្រឿងរំលាយអាហារ ៖** ពិនិត្យទាំងផ្នែកខាងក្នុង និងខាងក្រៅ ដើម្បីរកមើលបរាសិត នៃសត្វទំពាអៀងតូចៗ។ វះកូនកណ្ដុរក្រពះដើម្បីរកមើលស្នាមរបេងក្នុងករណីសង្ស័យគេវះមើលផ្នែកខាងក្នុងនៃពោះវៀន និងលៀងសំអាតដោយបាញ់ទឹក គេអាចរកឃើញភាពហើមដាំដំបៅរលាករឺស្នាមចេញឈាមនៃជម្ងឺ ប៉េស្តគោ ជម្ងឺរបេង រឺបូសពណ៌លឿងមានទំហំប៉ុនគ្រាប់សណ្ដែក។

៨.៨ **ពិនិត្យសាច់ចំឡក ៖** បង្វិលផ្ទាំងសាច់ និងពិនិត្យចំឡកដើម្បីរកមើលចុងអង្ករ នៅកន្លែងខ្លះគេវះតាមបណ្ដោយចំឡកដើម្បី រកមើលបរាសិត ប៉ុន្តែធ្វើយ៉ាងនេះនាំឱ្យខូចគុណភាពសាច់។

៨.៩ **ពិនិត្យក្រលៀន ៖** ក្រលៀនមិនមែនជាចំណែកទី៥ទេ ព្រោះវានៅភ្ជាប់នឹងផ្ទាំងសាច់ដំបូង គេពិនិត្យកន្លែងរបស់វា ក្រោយមកគេបកខ្លាញ់ដែលពទ្ធ័ជុំវិញចេញ ដើម្បីរកមើលចុងអង្ករ បើកាលណាក្រលៀនមានពណ៌ ទំហំ និងសភាពមិនធម្មតាគេត្រូវវះ ដើម្បីពិនិត្យមើលភាគខាងក្នុងគេអាចរកឃើញបូស គ្រោះ និងស្នាមរបេង។

៨.១០ **ពិនិត្យសាច់ភ្លៅ និងស្មារ ៖** វះសាច់ជុំភ្លៅ ក្បែរឆ្អឹងត្រគៀក និងសាច់ជុំស្មារត្រង់សាច់ជុំប៉ោង ដើម្បីរកមើលចុងអង្ករ វាយតំលៃពណ៌សាច់ អាត្រាសំងួត និងក្លិន។

៨.១១ **វះកូនកណ្ដុរ ៖** កូនកណ្ដុរដើមដោះ ដើម្បីឱ្យដឹងពីភាពស្អាតល្អនៃសាច់កន្លែងដោះ ដែលមិនកើតជំងឺរបេង និងកូនកណ្ដុរគុម្ពត្រចៀក ៖ ដើម្បីឱ្យដឹងពីជម្ងឺរបេង។

## ៩.ការបោះត្រា

ការបោះត្រា គឺជាការងារមួយចាំបាច់ ដែលត្រូវអនុវត្តដោយបោះ ឬអូសត្រាលើផ្ទាំងសាច់សំរាប់បញ្ជាក់ ឬអះអាងថាសាច់ល្អ (អាចបរិភោគបាន)។ ហាមដាច់ខាតការធ្វើចរាចរ.ការតាំងពិពណ៌.ការលក់ និងការប្រើប្រាស់ដោយផ្ទាល់ ឬប្រយោលសម្រាប់ការហូបចុករបស់មនុស្សនូវសាច់ស្រស់ ឬសាច់ក្លាសេណាដែលគ្មានការបោះត្រាបសុពេទ្យជាសំគាល់។

កន្លែងដែលបសុពេទ្យត្រូវអូសត្រាលើផ្ទាំងសាច់ គឺមានច្រើនចំណុច ឬកន្លែងដែលអាចមើលឃើញ ដូចជាភ្លៅ.ស្មា... ។

# ជំពូកទី៤ ការត្រួតពិនិត្យសាច់សត្វកើតជំងឺឆ្លងមួយចំនួន

## ១.សាច់មិនអនុញ្ញាតឱ្យបរិភោគ

សាច់សត្វងាប់នឹងជំងឺឆ្លង (មុនឬពេលពិឃាត) ដូចជាជងឺប៉េស្ត ជំងឺសារទឹក ជំងឺឈាមខ្មៅ ជំងឺបូសខ្យល់ ជំងឺកញ្ច្រិល និងជំងឺឆ្កួត គឺមិនមែនសាច់ល្អសំរាប់ការបរិភោគទេ។

**១.១ ជំងឺប៉េស្តគោ** ជំងឺនេះធ្វើឱ្យហ្វូងសត្វទទួលនូវការវិនាសអន្តរាយយ៉ាងខ្លាំង និងរាតត្បាតជាអចិន្ត្រៃយ៍

- ពេលពិនិត្យសត្វរស់ ៖ សត្វក្តៅខ្លាំង រាគលាយឈាម មានទុព្វលភាព ចេញទឹកភ្នែក ហៀរសំបោរ និងមានហៀរទឹកមាត់យ៉ាងច្រើន។
- ពេលពិនិត្យផ្ទាំសាច់ ៖ មានស្នាមដាំឈាមរលួយ និងឈាមហូរតាមភ្នាសខាងក្រៅ ៖ប្រមុះ បបូរមាត់ ប្រដាប់បន្តពូជ។

**១.២ ជំងឺសារទឹក** ជាជំងឺឆ្លងរាតត្បាតដោយសារមេរោគឈ្មោះ Pasteurella multocida។ ច្រើនកើតមាន ឡើងនៅលើគោ និងក្របី។

- ពេលពិនិត្យសត្វរស់ ៖ សត្វគ្រុនខ្លាំង ហើមបំពង់ក និងកហើមមានសភាពក្តៅពិបាកក្នុងដកដង្ហើម,អណ្តាតមានទំហំរីកធំ,សត្វថប់ដង្ហើមបណ្តាលមកពីហើមបំពង់កបំពង់ខ្យល់
- ពិនិត្យផ្ទាំងសាច់ ៖ស្លាកស្នាមសំខាន់ គឺហើមយ៉ាងធំនៅកូនកណ្តុរ និងមានហូរឈាម។

**១.៣ ជំងឺឈាមខ្មៅ** ជាជំងឺឆ្លងរាតត្បាតដ៏កាចសាហាវ និងស្រួចស្រាវ ដែលបណ្តាលមកពី ៖ បាក់តេរី មួយប្រភេទឈ្មោះ Bacillus Anthracis ហើយដែលកើតមានឡើងនៅលើសត្វគ្រប់ប្រភេទ ដូចជា ៖ គោក្របី ចៀម ពពែ ជ្រូក សេះ ព្រមទាំងមនុស្សផងដែរ។ លក្ខណៈពិសេសនៃជំងឺនេះ គឺរាលដាល ពាសពេញក្នុងខ្លួន និងពុលយ៉ាងធ្ងន់ធ្ងរ ហើយជួនកាលមានបូសនៅលើផ្នែកនៃក្បាល ទ្រូង ស្មា និងនៅផ្នែកពោះ។

- ពេលពិនិត្យសត្វរស់ **៖** (គោ) សាច់ដុំញាក់ទទ្រើក គ្រុនខ្លាំង ញាក់ញ័រ ចេញញើស ឈឺពោះ និងរាគឈាម។ ចំពោះជ្រូកជំងឺស្តែងឡើង ដោយលេចចេញនូវការស្ទះពាសពេញម្តុំបំពង់ក និងកូនកណ្តុរ។ ស្បែកមានពណ៌ ពកហើម ក្តៅឈឺចាប់ ពិបាកក្នុងការទំពារ និងលេបចំណី ហើយកំដៅឡើងដល់ ៤១ អង្សាសេ។
- ពិនិត្យផ្ទាំងសាច់៖ឈាមស្រក់ដូចទឹកមាត់ និងមានពណ៌ខ្មៅរាវ,មិនកក,ប៉ះខ្យល់ក៏មិនក្រហមផ្ទាំងសាច់មានឈាមហូរស្រក់និងសាច់ដុំហាក់ដូចជាឆ្អិន។ នៅម្តុំពោះគេឃើញមានជាតិទឹករងៃពណ៌ក្រហមព្រឿង មានឈាមនៅពោះកន្សែង និងតាមបណ្តោយពោះវៀន(ពិសេសជ្រូក)។ ស្លាកស្នាមសំខាន់ៗ គេច្រើនឃើញមាននៅផ្លោកនោម ផាល ពោះវៀន,បេះដូង...។

- ផាល ៖មានទំហំពី៤ -៥ដង ធំជាងធម្មតា ពេលវះកាត់ឃើញឈាមមានពណ៌ដូចភក់ ហូរចេញមក(មានសភាពទន់ព្រួកៗ)។
- ផ្លោកនោម ៖ គេសង្កេតឃើញមានឈាមនៅក្នុងប្លោកនោម ពោះវៀនៈ ពោះវៀនជាប់នឹងក្រពះ មានសភាពជាំឈាម ហូរឈាម ភ្នាសហើមមានពណ៌ក្រហម និងរុំដោយឈាម។
- បេះដូង ៖ មានស្នាមកន្ទួលឈាម និងនៅពីក្រោមបេះដូងមានស្នាមរលាក
- ថ្លើម ៖ ជាំឈាម (ធ្វិន)។

**ចំណាំ ៖** ខ្លួនសត្វដែលងាប់ដោយជំងឺនេះ មិនរឹងក្រញង់ដូចសត្វដែលងាប់នឹងជំងឺដ៏ទៃទៀយ។

**១.៤ ជំងឺបូសខ្យល់** ជាជំងឺឆ្លងរាតត្បាត ដែលតែងតែជួបប្រទះនៅលើគោ

- ពិនិត្យផ្ទាំងសាច់ ៖ ដុំពកហើមមានជាតិឧស្ម័ន និងចុចឮសូរប្រេះៗ មានក្លិនដូចប៊ឺធំខា នៅក្នុងសាច់ដុំត្រចៀក នៅចំកណ្តាលសាច់ដុំមានដំបៅរលួយពណ៌ខ្មៅ មានក្លិនដូចប៊ឺធំខា ផាលជានិច្ចកាល គឺមានសភាពធម្មតា។ ផ្ទាំងសាច់បង្ហាញនូវទិដ្ឋភាពសាច់បាក់កំលាំង ហើយញ៉ឹកញាប់មានក្លិនដូចប៊ឺរធំខានៅម្ដុំពោះ ពេលយើងស្ទាបដុំពកលាន់លឺសូរប្រេះៗ។

**១.៥ ជំងឺកញ្ជ្រិលជ្រូក** ជាជំងឺឆ្លងដែលច្រើនកើតនៅលើសត្វជ្រូក

- ពិនិត្យសត្វរស់ ៖ គេសង្កេតឃើញមានកំដៅខ្ពស់ ល្វិតល្វៃ អស់កំលាំង ជួនកាលមានឈាមច្រមុះ និងក្អួត។ ភ្នាសពណ៌ក្រហមស្វាយ សត្វរាគយ៉ាងរហ័ស ស្បែកមានសភាពខ្លោច(ដូចឆេះ)ដោយមានស្នាមពណ៌កុលាប ឬក្រហមឆ្អៅ ឬក្រហមស្វាយ ពិសេសនៅលើស្លឹកត្រចៀក ក ពោះ និងនៅផ្នែកខាងក្នុងនៃភ្លៅ។
- ពិនិត្យផ្ទាំងសាច់៖ ក្នុងសណ្ឋានស្រួចស្រាវ គេឃើញមានស្នាមនៃការរាតត្បាតរបស់មេរោគចូលទៅក្នុងឈាម សាច់ស្រក់ឈាម ជាលិកាសន្ទាន និងខ្លាញ់ជាំឈាមមានពណ៌កុលាប កូនកណ្ដុរទឹករងៃមានសភាពហើមជាំឈាម និងហូរឈាម។
- ប្រតិកម្មផាល ៖ ផាលរីកឡើងធំ និង មានដំនើរយារនៃផាល។
- ថ្លើម ៖ ជាំកកឈាម ប្លោកនោមជាំឈាម និងភ្នាសក្រពះពោះវៀន ជាំឈាមក្រាស់ឃ្មឹក។
- សួត ៖ ជាំឈាម។
- សណ្ឋានរ៉ាំរ៉ៃ ៖ គេសង្កេតឃើញមានលក្ខណៈសំគាល់ចំនួន ៣គឺ ៖
    - ❖ សណ្ឋានស្បែក មានរលួយស្បែក ជាំឈាម ដំបៅរលួយ ដោយមានធ្លាក់រលេះរលួយស្រ ទាប់ស្បែកក្នុង។
    - ❖ រលាកសាច់ដុំក្នុងបេះដូង (មានលក្ខណៈរ៉ាំរ៉ៃ ) ដែលតែងជួបប្រទះនៅត្រង់រន្ធបែកជា ៣ និងតាមការកកើតជាថ្មី ដែលអាចក្លាយជាដំបៅរលួយ។
    - ❖ រលាកសន្លាក់ឆ្អឹង ៖ អាចច្រឡំជាមួយនឹងជំងឺរលាកក្នុងបេះដូង។

**១.៦ ជំងឺឆ្កួត**

ជំងឺនេះកើតមាននៅលើសត្វស្រុក សត្វព្រៃ និងមនុស្សផងដែរ។ វាមិនបញ្ចេញសញ្ញាគួរ

ឱ្យកត់សំគាល់ណាមួយឡើយ នៅពេលវះកាត់ គឺយើងអាចពិនិត្យឃើញនៅលើសត្វរស់។ ប្រការគួរអោយប្រុងប្រយ័ត្ន គឺគេត្រូវជៀសវាងមិនសំឡាប់គ្រប់សត្វណា ដែលមានរោគ សញ្ញាសរសៃប្រសាទ ខ្វិនជើង ឬមានភាពធាប់កន្ទ្រាក់ខ្លាំងគួរអោយខ្លាច។

## ២.សាច់រឹបអូសមិនចាំបាច់ ប៉ុន្តែត្រូវតែត្រួតពិនិត្យតាមបទបញ្ជា

សាច់បានមកពីសត្វពិឃាដ ដែលមានជំងឺហើមសួតឆ្លងគោក្របី ជំងឺប៉េស្តជ្រូក ជំងឺសាម៉ូណែលឡូជ្រូក ជំងឺសារទឹកជ្រូកអាចអនុញ្ញាត្តអោយបរិភោគបាន លុះត្រាតែមានយោបល់ និងការសំរេចរបស់បសុពេទ្យ សួត និងគ្រឿងបន្ទាប់បន្សំត្រូវរឹបអូស និងបំផ្លាញចោលទាំងស្រុង។

**២.១ ជំងឺហើមសួតឆ្លង** (គោក្របី) ជាជំងឺឆ្លងពិសេសចំពោះគោ

- ពិនិត្យសត្វរស់ (រោគសញ្ញាទូលំទូលាយ)៖បេះដូងដើរញាប់,កំដៅឡើងខ្ពស់,ដកដង្ហើមញាប់(ដាច់ៗ),ដើបចរញាប់ និងក្អក ...។
- **ពិនិត្យផ្ទាំងសាច់ ៖**
  - ❖ សណ្ឋានស្រួចស្រាវ ៖ គឺជាស្លាកស្នាមហើមសួត ដោយមានលក្ខណៈពិសេស សួតមានក្រឡាដូចថ្មកែវ ជាញឹកញាប់ គឺសួតតែមួយទេដែលមានទិដ្ឋភាពដូចនេះ (ខាងឆ្វេង)។ ស្លាកស្នាមសួតមានសភាពហើម និងមានលក្ខណៈជាសរសៃ(មានស្លាកស្នាមលើស្រោមសួត ហើយ ឡើងក្រាសមានភាពជាសរសៃ)។
  - ❖ សណ្ឋានរាំរ៉ៃ ៖ រួមផ្សំជាមួយសណ្ឋានស្រួចស្រាវ សណ្ឋានរាំរ៉ៃមានលក្ខណៈបន្ថែមដូចជាមានទឹកនៅចន្លោះសន្ទះទ្រូង និងស្រោមសួតឡើងរឹង ហើយសាច់សួតឡើងរួញ។
- **វិធានការ** ៖ រឹបអូសគ្រឿងបន្ទាប់បន្សំ (គ្រឿងក្នុង)
  - ❖ ផ្ទាំងសាច់ស្គម ជាទូទៅមានសភាពអាក្រក់ ៖ ត្រូវរឹបអូសទាំងអស់។
  - ❖ ផ្ទាំងសាច់មានលក្ខណៈល្អជាទូទៅពិនិត្យបាក់តេរីសាស្រ្ត (នៅមន្ទីរពិសោធន៍)។

**២.២ ជំងឺប៉េស្តជ្រូក** ជាជំងឺមួយដែលកើតនៅលើសត្វ ពិសេសលើសត្វជ្រូក

- **ពិនិត្យផ្ទាំងសាច់**
  - ❖ សណ្ឋានស្រួចស្រាវ ៖ មានលក្ខណៈស្រក់ឈាម និងស្នាមហូរចេញឈាម។
  - • ស្លាកស្នាមមានលក្ខណៈចេញឈាម ៖ លើស្បែក ជាលិកាសន្ទាននៃក្នាសសួត បំពង់រំលាយអាហារ ក្រលៀន ផាល។
  - • កូនកណ្តុរទឹករងៃ ៖ ហើមមានពណ៌ក្រហម ជួនកាលចេញឈាម ផាលរីក ផ្លោកនោមគ្របដណ្តប់ទៅដោយចំណុចឈាម។
  - ❖ សណ្ឋានរាំរ៉ៃ៖ មានដំបៅរលួយនៅលើស្បែក បំពង់រំលាយអាហារ និងនៅប្រដាប់ដង្ហើម
- **វិធានការ**
  - ❖ សណ្ឋានស្រួចស្រាវ ត្រូវរឹបអូសទាំងអស់។
  - ❖ សណ្ឋានរាំរ៉ៃ ៖ សភាពទូទៅអាក្រក់ ត្រូវរឹបអូសទាំងអស់។

- សភាពទូទៅល្អ ៖ ពិនិត្យនៅមន្ទីរពិសោធន៍ លទ្ធផលល្អ លក់ដូរបរិភោគបាន។

**២.៣ ជំងឺសាម៉ូណែឡូជ្រូក** ៖ ជាជំងឺឆ្លង ដែលបណ្ដាលឱ្យរលាកក្រពះ ពោះវៀន និងមានដំបៅរលួយនៅពោះវៀន។

- **ពិនិត្យសត្វរស់** ៖ រោគសញ្ញាប្រភេទជំងឺក្រហម មានគ្រុនញាក់ញ័រខ្លាំង និងមានការលេចចេញឡើងនូវផ្ទាំងក្រហម ឬពណ៌ស្វាយជុំៗ។ សត្វស៊ីចំណីមិនឆ្ងាញ់ ដកដង្ហើមញាប់ លាមករាគ មានពណ៌លឿងព្រឿងៗ ឬជួនកាលមានឈាម។
- **ពិនិត្យផ្ទាំងសាច់** ៖ ស្លាកស្នាមដំបៅក្នុងគ្រប់សណ្ឋាន ដែលលេចចេញច្បាស់លាស់ជាងគេគឺពោះវៀន។
  - ❖ សណ្ឋានស្រួចស្រាវ ៖ មានស្លាកស្នាមជាំឈាម និងរលាកក្រពះពោះវៀន ជួនកាលចេញឈាម ផាលរីកធំមានពណ៌ខៀវ និងថ្លើមមានស្លាកស្នាមជាំឈាម។
  - ❖ សណ្ឋានរ៉ាំរ៉ៃ៖ គឺជាស្លាកស្នាមដំបៅរលួយសឹងតែគ្រប់សរីរាង្គ ផាល ថ្លើម បំពង់រំលាយអាហារ
- **វិធានការ**
  - ❖ សណ្ឋានស្រួចស្រាវ ៖ រឹបអូសទាំងអស់។
  - ❖ សណ្ឋានរ៉ាំរ៉ៃ ៖ សភាពទូទៅអាក្រក់ រឹបអូសទាំងអស់។
    - សភាពទូទៅល្អ ពិនិត្យនៅមន្ទីរពិសោធន៍។
    - គ្មានមេរោគ បោះត្រា ។
    - មានមេរោគ រឹបអូសទាំងអស់។

**២.៤ ជំងឺសារទឹកជ្រូក**

គឺជាជំងឺឆ្លងមួយដែលមានលក្ខណៈពិសេស ដោយរលាកស្រោមសួត និងហើមសួត។

- **ពិនិត្យសត្វរស់** ៖ សត្វមានកំដៅឡើងខ្ពស់ និងមានរោគសញ្ញាទូទៅ (ធ្ងន់ធ្ងរ) ក្អួត រួចចេញនូវផ្ទាំងក្រហមស្វាយនៅក្រោមត្រចៀក ក ពោះផ្នែកខាងមុខ និងផ្នែកខាងក្នុងនៃភ្លៅ។ ចំពោះរោគសញ្ញាសួត ៖ មានក្អកតិចៗ ដកដង្ហើមខ្លីជាច់ៗ រួចញាប់ និងមានក្អកខេះៗជាបន្តជាប់ កំហាកមានស្លេស (ជំក្លិនស្អុយ)។
- **ពិនិត្យផ្ទាំងសាច់** ៖
  - ❖ សណ្ឋានស្រួចស្រាវ ៖ ប្រភេទជំងឺក្រហម ដែលស្លាមស្នាមនៃការរាតត្បាតគឺមេរោគក្នុងឈាម គ្រឿងក្នុងទាំងអស់ជាំឈាម សាច់ស្រក់ឈាម(មានអុជជាំកន្ទួល) និងឈាមកកតាមសរសៃឈាមតូចៗ។
  - ❖ សណ្ឋានរ៉ាំរ៉ៃ៖ មានប្រភពដើមជំងឺរលាកទងសួត ហើមសួត អាប់សៃសួត និងជួនកាលឡើងរឹងជាសរសៃៗ ស្រោមសួតឡើងក្រាស់ ហើយអាចជាប់ទៅនឹងឆ្អឹងជំនីគេអាចឃើញមានអាប់សៃឡើងរឹងជាសរសៃៗនៅក្នុងថ្លើម និងផាល។

- **វិធានការ** ៖ រឹបអូសគ្រឿងបន្ទាប់បន្សំទាំងអស់។
  - ❖ សណ្ឋានស្រួចស្រាវ រឹបអូសទាំងអស់
  - ❖ សណ្ឋានរ៉ាំរ៉ៃ សភាពទូទៅអាក្រក់ រឹបអូសទាំងអស់
- សភាពទូទៅល្អ អនុញ្ញាត្តអោយហូប។

## ៣.សាច់សត្វកើតជំងឺឆ្លងមួយចំនួនទៀត

### ៣.១ សាច់សត្វកើតជំងឺអុតក្ដាម

ជំងឺអុតក្ដាម គឺជាជំងឺឆ្លង និងរាតត្បាតជាទីបំផុត ទៅលើពពួកសត្វគោក្របី និងពពួកសត្វដែលមានក្រចកជើងមានប្រវែកដូចជាជ្រូកជាដើម។ ជំងឺនេះមានលក្ខណៈជាដំបូង គឺសត្វគ្រុនក្ដៅ បន្ទាប់មកមានលេចចេញពងដោរ ឬដំបៅនៅមាត់ ច្រមុះ និងក្រចកជើង។

- **ការពិនិត្យផ្ទាំងសាច់** (កាកាស )
  - ❖ នៅតាមបណ្ដោយបំពង់រំលាយអាហារ មានដុំពក (ដំបៅពក )។
  - ❖ មានរលាកនៅបំពង់ក ជាំសួត រលាកទងសួត និងមានដំបៅរលួយនៅលើសួត។
  - ❖ សាច់ដុំបេះដូងទន់ជ្រាយ និងមានស្នាមប្រផេះ ឬលឿង។
  - ❖ ផាលរីកធំ និងមានពណ៌ខ្មៅ។
- **វិធានការ**
  - ❖ ក្នុងសណ្ឋានធ្ងន់ធ្ងរ ៖ ត្រូវរឹបអូសទាំងអស់។
  - ❖ ក្នុងសណ្ឋានរ៉ាំរ៉ៃ ៖ អាចយកទៅធ្វើជាផលិតផលកែច្នៃបាន។

**៣.២ ជំងឺតេតាណូស** គឺជាជំងឺឆ្លងដ៏ស្រួចស្រាវមួយ ដែលកើតឡើងនៅលើមនុស្ស និងសត្វគ្រប់ប្រភេទទាំងអស់។ លក្ខណៈពិសេសរបស់វា គឺធ្វើឱ្យមានការកន្ត្រាក់សាច់ដុំ មានអំពើទៅលើប្រព័ន្ធសរសៃប្រសាទ។

- ការពិនិត្យសត្វរស់ ៖ សត្វមានដំនើរទ្រេតទ្រោត និងយឺតៗ បន្ទាប់មកក្នុងរយៈពេលពី ១ - ២ថ្ងៃក្រោយមក ការកន្ត្រាក់សាច់ដុំក៏កើតមានឡើង។ វាបណ្ដាលអោយញាក់មុខ ច្រមុះរីកចុងច្រមុះទាញទៅមុខ បបូរមាត់ទាញចុះក្រោម ស្លឹកត្រចៀកឈរត្រង់ ភ្នែកក្រឡាប់ចុះក្រោម និងចូលជ្រៅទៅក្នុងភ្នែក។
- ការពិនិត្យផ្ទាំងសាច់ ៖ មានការពិបាកក្នុងការពិនិត្យឱ្យបានច្បាស់លាស់នៅលើផ្ទាំងសាច់ ហេតុដូចនេះការដែលចាំបាច់យើងត្រូវពិនិត្យសត្វរស់ទើបឃើញមានរោគសញ្ញាច្បាស់។
- វិធានការ ៖ លក្ខណៈសាច់ស្រក់ឈាមខ្លាំង ឬបាក់កំលាំងខ្លាំងត្រូវរឹបអូសទាំងអស់។

**៣.៣ សាច់សត្វកើតជំងឺរលូតកូន** គឺជាជំងឺឆ្លងរាតត្បាតចំលងទៅមនុស្ស (ធ្វើឱ្យរលូតកូន) ក្នុងករណីជម្ងឺរលូតកូន មនុស្សមានញឹកញាប់ បន្ទាប់ពីការចំលងរោគតាមម្ហូបអាហារ សាច់សត្វ តាមការប៉ះពាល់ តាមការលេបចូលដូចជាទឹកដោះ សាច់ប៊ីរ ហ្រូម៉ា។ មេរោគធាប់ទទួលកំដៅថ្ងៃណាស់ បើគេចំអិនវានៅសីតុណ្ហភាព ៦៥ °ជ មេរោគនឹងស្លាប់ក្នុងរយៈពេល ១នាទី។

- **ការពិនិត្យផ្ទាំងសាច់**

❖ ជំងឺនេះបង្ហាញស្លាកស្នាមហើមសាច់ ក្រោយពេលលូតកូន។

❖ មានលក្ខណៈលូតកូន និងរលាកស្បូន ហើយបំផ្លាញនូវសមត្ថភាពនៃការបន្តពូជសត្វ។

**ចំពោះសត្វគោ ៖** ជំងឺមានស្លាកស្នាមដំបៅរលួយកូទីលេដុង បន្ទាប់ពីលូត រលាកស្បូន និងរលាកដោះស្រួចស្រាវ។

- **វិធានការ**

❖ ក្នុងសណ្ឋានស្រួចស្រាវ ៖

- ក្នុងករណីសភាពទូទៅអាក្រក់ ត្រូវរឹបអូសទាំងអស់។
- ក្នុងករណីដែលសភាពទូទៅល្អ អាចអោយបរិភោគបាន។

❖ ក្នុងសណ្ឋានរាំរ៉ៃ ៖

- អាចអោយធ្វើផលិតផលកែច្នៃ។

**៣.៤ សាច់សត្វមាន Leptospirosis** គឺជាជំងឺឆ្លងមួយដែលបណ្តាលមកពីជាតិពុល ឬបណ្តាលមកពីករណីផ្សេងៗទៀត ដែលធ្វើឱ្យថ្លើមរងរបួស និងធ្វើឱ្យស្វះបំពង់ទឹកប្រមាត់ ហើយផាលរីកធំ។ លក្ខណៈពិសេសគឺខ្លាញ់សាច់ និងជាលិកាក្រោមស្បែកមានពណ៌លឿង។

- ពិនិត្យផ្ទាំងសាច់ ៖ សាច់មានពណ៌លឿង និងមានហើមសាច់។
- វិធានការ ៖ បើសាច់លឿង គឺយើងត្រូវទុកសាច់ក្នុងរយៈពេល ១២ម៉ោង ពេលនោះបើពណ៌លឿងមិនរលប់បាត់ទេ គឺសាច់ និងគ្រឿងក្នុងអាចយកទៅធ្វើជាផលិតផលកែច្នៃបាន ប៉ុន្តែបើក្នុងរយៈពេល១២ម៉ោងពណ៌លឿងវាបានរលប់បាត់ទៅវិញ ពេលនោះសាច់ និងគ្រឿងក្នុងអាចយកទៅបរិភោគបាន។

**៣.៥ សាច់សត្វកើតជំងឺរបេង** ជំងឺរបេងគឺជាជំងឺឆ្លងរួមទាំងមនុស្ស និងសត្វគ្រប់ប្រភេទ ដែលបណ្តាលមកពីមេរោគ BK នៅលើសរីរាង្គផ្សេងៗ និងបង្កើតនូវស្លាកស្នាមតាមលក្ខណៈពិសេសរបស់វា។ គេសង្កេតឃើញជំងឺ របេងកើតមានភាគតិចចំពោះសត្វគោក្របី ប៉ុន្តែគេឃើញកើតមានភាគច្រើននៅលើសត្វជ្រូក ពីព្រោះសត្វជ្រូកដែលចិញ្ចឹមលែងពាសវាលពាសកាល ស៊ីប៉ះកំហាកមនុស្សដែលកើតជំងឺរបេង និងកាកសំណល់បាយទឹកដែលយកមកពីមន្ទីរពេទ្យ។ ការស្រាវជ្រាវជំងឺរបេងលើសត្វសំរាប់ពិឃាដ គឺមាទំរង់ពីរយ៉ាង ៖

- ដើម្បីឱ្យឃើញប្រភពចំលងជំងឺ គឺបណ្តាលមកពីបញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ច។
- ដើម្បីកំចាត់ចោលសាច់ដែលកើតជំងឺរបេង និងបញ្ចៀសមនុស្សឱ្យឆ្លងផុតពីជំងឺនេះ គឺបញ្ហាអនាម័យ។

**ក.ការសិក្សាបាក់តេរីសាស្ត្រ ៖** មេរោគរបេងវាមាន៣ប្រភេទ ៖

- គោ ៖ Bacillus Bovis
- សត្វស្លាប ៖ Bacillus Avium

- មនុស្ស ៖ Bacillus Homminis

ប្រភេទទាំងបីនេះ អាចសំរបខ្លួនរស់នៅក្នុងខ្លួន និងនៅក្នុងខួរនៃសត្វប្រភេទខុសៗគ្នាវាសុទ្ធតែមានឥទ្ធិពលចំលងរោគ ចំពោះគ្រប់ប្រភេទសត្វ។ ឧទាហរណ៍ ៖ Bacillus លើមនុស្សអាចបណ្តាលឱ្យកើតជំងឺចំពោះគ្រប់សត្វទាំងអស់។

**ខ.រោគវិនិច្ឆ័យនៃជំងឺរបេងកូនកណ្តុរ ៖** ការស្រាវជ្រាវរកជំងឺរបេង គឺស្ថិតនៅលើការពិនិត្យត្រឹមត្រូវលើកូនកណ្តុរទឹករងៃជាការចាំបាច់។ ចំពោះកូនកណ្តុរ មុនដំបូងគេត្រូវពិនិត្យអំពីទំហំ រូបរាង និងសភាពរបស់វា។

- ករណីទី១ កូនកណ្តុររីកធំយ៉ាងច្បាស់។ ដូចនេះគេត្រូវសង្ស័យលើស្លាកស្នាមដែលមានទិដ្ឋភាពដូចទឹកដោះគោកក។
- ករណីទី២ កូនកណ្តុររីកធំតិចតួច ឬមិនរីកធំ គេវះកាត់ពិនិត្យមើលឱ្យបានច្រើន (កាត់ទទឹង កាត់បណ្តោយ) ជាបន្ទះស្តើងបើអាចធ្វើបាន ដើម្បីបញ្ជាក់ឱ្យឃើញជាក់ស្តែងនូវរោគរបេង។

**គ.ការស្រាវជ្រាវតាមវិធីនៃការបោះទីតាំងរបស់កូនកណ្តុរ ៖** តាមស្ថិតិជាច្រើនបានបង្ហាញថា សួតរបស់គោពេញវ័យច្រើនកើតជំងឺរបេងសឹងតែ១០០%។ ដូច្នេះហើយគេត្រូវចាប់ផ្តើមពិនិត្យមើលកូនកណ្តុរទងសួតខាងឆ្វេង ពីព្រោះវាកើតញឹកញាប់ជាងគេ រួចពិនិត្យកូនកណ្តុរទងសួត ខាងស្តាំ និងកូនកណ្តុរបំពង់ក។

**ឃ.វិធានការរើបអូសមួយចំនួន ៖** ការរើបអូសទាំងអស់មាន ៣ករណី

- ជំងឺរបេងស្រួចស្រាវ ៖ មានពងតូចៗនៅក្នុងសាច់ មាននៅច្រើនកន្លែង។ ជំងឺរបេង "មានទិដ្ឋភាពដូចទឹកដោះគោកក" ជាមួយនឹងចំណុចសំខាន់នៃជំងឺដែលមាន ទំហំតូចទៅៗ ឬរាលដាលទៅដល់សរីរាង្គជាច្រើនទៀត។ ជំងឺរបេងរាលដាល រួមជាមួយស្លាកស្នាមកូនកណ្តុរដែលមានទិដ្ឋភាពដូចទឹកដោះគោកក (ទិដ្ឋភាពអាក្រក់)។

ដូចនេះការរើបអូស និងការកំទេចចោលមួយចំនួនត្រូវគិតសរុបក្នុងករណីផ្សេងៗទៀតវាអាស្រ័យទៅលើការរីករាលដាល និងទំហំស្លាកស្នាមជំងឺ។ គេត្រូវរើបអូសឬបំប្លែងកុំឱ្យបរិភោគបាន និងកំទេចចោលទាំងអស់នូវគ្រប់សរីរាង្គដែលមានស្លាកស្នាមជំងឺរបេងណាមួយដែលកំណត់បានច្បាស់លាស់។

- ការរើបអូសជាភាគ ឬ ជាចំណែក ការរើបអូសជាភាគរួមមាន ៖
  - ❖ លើគ្រប់សរីរាង្គដែលមានស្លាកស្នាមរបេងណាមួយដែលអាចសំគាល់បានច្បាស់។
  - ❖ លើគ្រប់កន្លែងដែលមានស្លាកស្នាមរបេងជាភាគ។
  - ❖ លើគ្រប់សរីរាង្គ ឬ គ្រប់កន្លែងទាំងអស់ដែលមានស្លាកស្នាមកូនកណ្តុរ។
- ការរើបអូសជាភាគ ឬ ជាចំណែកត្រូវអនុវត្តដូចតទៅ ៖

| **ទីកន្លែងមានស្លាកស្នាម** | **កន្លែងត្រូវរើបអូស** |
|---|---|
| • កូនកណ្តុរនៅភ្លៅ | - សាច់ជុំភ្លៅ |

- កូនកណ្ដុរនៅគ្រលៀន - សាច់ដុំកំប៉េះគូទ
- កូនកណ្ដុរដើមក - ក្បាល
- កូនកណ្ដុរបណ្ដោយឆ្អ.ខ្នងខាងក្រោយ - សាច់ចំលកក្នុង
- កូនកណ្ដុរក្រលៀតជើងមុខ - ជើងមុខ
- កូនកណ្ដុរក្រោមខ្នង - ឆ្អឹងជំនី
- កូនកណ្ដុរក្រោមថ្គាម - អណ្ដាត

- ការរឹបអូសឈាម ៖ ឈាមដែលបានមកពីសត្វមានជំងឺរបេង ត្រូវរឹបអូស និងបំផ្លាញចោល ទោះជាសត្វប្រភេទណាក៏ដោយ។
- ការសំលាប់មេរោគ ៖ សាច់ត្រូវសំអាត ហើយកាត់ជាដុំៗប្រមាណ ១កង និងឆ្អឹងត្រូវកាត់ជាកង់ៗ។ ការសំលាប់មេរោគ ត្រូវធ្វើឡើងក្នុងអូតូក្លាវ ក្រោមសីតុណ្ហភាព ត = ១០៥⁰ជ , ២ ហ ឬដួនកាលគេដាក់ស្ងោរក្នុងថ្លាង។ នៅពេលស្ងោរគឺគេដាក់បន្ថែមគ្រឿងទេសតាម ទំលាប់នៃតំបន់នីមួយៗ។ ចំពោះកិច្ចការទាំងអស់នេះត្រូវធ្វើបាននៅទីសត្តឃាតតែប៉ុណ្ណោះ និង ក្រោមភ្នាក់ងារត្រួតពិនិត្យសាច់។

ចំពោះសាច់ដែលបានសំអាតហើយ អាចបញ្ចោញអោយលក់សំរាប់ហូបចុកបាន។ ក្រោយពេលធ្វើការសំលាប់មេរោគរួច សាច់ទាំងនោះមានឈ្មោះថា សាច់សំអាតដោយកំដៅ។ ចំពោះសាច់ដែលបានសំលាប់មេរោគរួចហើយ មិនអោយយកទៅប្រើប្រាស់ ៖ដូចជាយកទៅធ្វើជាសាច់កំប៉ុង ឬកែច្នៃជាផលិតផលផ្សេងៗទៀតបានទេ ( ខូចគុណភាព )។

# ជំពូកទី៥ ៖ ការពិនិត្យបណ្តាសាច់មានបរាសិត

## ១.សេចក្តីផ្តើម

សាច់មានបរាសិត គឺជាសាច់ដែលបានមកពីសត្វមានដក់ជាប់នូវជំងឺបរាសិតក្នុងជីវិតរបស់វា។ ការចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យបរាសិតបង្កជំងឺ គឺយើងត្រូវកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទបរាសិតនីមួយៗដែលបណ្តាលឱ្យឆ្លងទៅមនុស្សដោយផ្ទាល់ និងមិនផ្ទាល់។

## ២.គោលបំណង

ក្រោយពីរៀនចប់និស្សិត នឹងអាចរៀបរាប់ពី

- ប្រភេទសាច់មាន បរាសិត
- ប្រភេទសាច់មាន បរាសិតមិនឆ្លងទៅមនុស្សដោយផ្ទាល់
- ប្រភេទសាច់មាន បរាសិតអាចឆ្លងទៅមនុស្សដោយផ្ទាល់
- ប្រភេទសាច់គួរអោយខ្ពើម
- ប្រភេទសាច់ខ្វះគុណភាព
- ប្រភេទសាច់សត្វគ្រុន
- ប្រភេទសាច់សត្វបាក់កំលាំង

## ៣.សាច់មានបរាសិតមិនអាចឆ្លងទៅមនុស្សដោយផ្ទាល់

**៣.១ ដង្កូវថ្លើម ៖** គឺជាពពួក បរាសិតដែលតែងតែជួបប្រទះនៅក្នុងថ្លើមពពួកគោ-ក្របី រោគវិនិច្ឆ័យនៃជំងឺដង្កូវថ្លើមមានភាពងាយស្រួលណាស់គេអាចរកឃើញនៅក្រោយពេលពិនិត្យថ្លើមរឺក្រោយពេលស្ទាបសរីរាង្គនោះ (មុខខាងក្នុង) ជួនកាលក្រោយពេលវះរន្ធទឹកប្រម៉ាត់។ ជួនកាលទីតាំងបរាសិតអាចមាននៅក្នុងសួត និងសាច់ដុំដែលមានពណ៌ត្នោតទុំ។ ជាទូទៅគេប្រទះឃើញនៅប្រទេសយើងមានជំម្ងឺនេះជិតដល់ ៨០% ដែលមាននៅលើសត្វគោ-ក្របី។ ពេលដែលជម្ងឺស្ថិតក្នុងសភាពរ៉ាំរ៉ៃ ធ្វើអោយបំពង់ប្រម៉ាត់ រីកធំហើយក្រាស់។

- **សម្រេច ៖** ការរឹបអូសធ្វើចំពោះតែសេរីរាង្គណាដែលមានកើតជំងឺ ការរឹបអូសជាភាគ រឺទាំងអស់ អាស្រ័យទៅលើទំហំនៃស្លាកស្នាមជំងឺ ជំងឺនេះមិនអាចឆ្លងទៅមនុស្សទេ។

**៣.២ ស្តាហ្វាណូយរ៉ូស្ស ៖** គឺជាដង្កូវមានរាងជាស៊ីឡាំង ទន់ពណ៌ក្រម៉ៅរូបរាងតូច(ឈ្មោលមានទំហំ ២,៥ ស.ម និងញីមាន ទំហំ ២,៨ ស.ម)។ ស្លាកស្នាមភាគច្រើនស្ថិតនៅក្នុងស្រទាប់ជ្រៅនៃជាលិកាខ្លាញ់នៅរុំពទ្ធ័ក្រលៀន និងបំពង់ទឹកនោម។ នៅពេលវះកាត់សាច់សត្វអ្វីដែលទាក់ទាញអារម្មណ៏ជាដំបូងនោះគឺខ្លាញ់ព័ទ្ធជុំវិញក្រលៀន និងបំពង់ទឹកនោមមានសភាពក្រាស់ជាពិសេសនៅចំហៀងខាងឆ្វេង និងមានស្នាមដង្កូវពណ៌ខៀវក្រម៉ៅហើយគេ និងឃើញភ្លាមនូវ បរាសិតនេះ។ នៅពេលណាមានកើតដង្កូវច្រើនមួយភាគបី គឺភាគខាងលើនៃបំពង់ទឹកនោម ក្រលៀន និងកន្សោមភាគខាងក្រៅលើក្រលៀន ទៅជាដុំពកមានខ្លាញ់ (ដូចគ្រាប់ត្រសក់ស្រូវ)។ ពេលណាគេវះដុំពកនោះគេនឹងឃើញដង្កូវ

មួយគូរញីមួយ ឈ្មោលមួយស្ថិតនៅក្នុងនោះហើយមានទឹកពណ៌បៃតងខ្ចីដង្កូវ ញីមានសុទ្ធតែពង។ នៅក្នុងទឹកនោម ប្លោកនោម ពោពេញទៅដោយពងបរាសិត ជួនការមានអំព្រើយ៉ុងញាស់ សួត ផាល និងជាពិសេសថ្លើមអាចត្រូវរាតត្បាតផងដែរ។ ក្នុងករណីគេសង្កេតឃើញស្លាកស្នាមដូចតទៅ ៖ ថ្លើមហើមជាំ និងមានទំងន់២ដងបើប្រៀបធៀបទៅ និងទម្ងន់ធម្មតា។ នៅលើផ្ទៃមានគ្រាប់តូចៗពណ៌សជួនកាលមានទំហំប៉ុនគ្រាប់សណ្តែកខៀវ។ ពេលវះជាលិកានេះគេ និងឃើញ បរាសិតចេញមក បរាសិតទាំងនោះមានតែមួយៗទេ។

- ❖ **សំរេច ៖** ផ្អែកលើការស្រាវជ្រាវ និងស្លាកស្នាមរបស់បរាសិត ត្រូវរឹបអូសទាំងអស់រួមទាំងផ្ទាំងសាច់ និងគ្រឿងក្នុង នៅពេលណាការរាតត្បាតរបស់បរាសិតដល់ជំរៅកំណត់ សត្វស្គាំងស្គមភាគច្រើនគេសង្កេតឃើញនៅក្នុងថ្លើម បើសិនជាការរាតត្បាតមានត្រឹមកន្លែងជុំវិញបំពង់ទឹកនោម និងស្ថានភាពសុខភាពសត្វមិនសូវធ្ងន់ធ្ងរទេនោះ គេកំទេចចោលតែសរីរាង្គដែលត្រូវរាតត្បាត និងគ្រឿងក្នុងប៉ុណ្ណោះ។

**៣.៣ ស៊ីលស្ទីសែគីស្ត តេនីកូលីល៍ ៖** ពពួកបរាសិតប្រភេទនេះ គេតែងតែជួបប្រទះ នៅក្នុងស្រទាប់ស្តើងពទ្ធ័ជុំវិញពោះខាងក្នុង ជារួមបរាសិតច្រើនជាប់នៅក្នុងថ្នក់ដែលមានទឹករំអិលនៃស្រទាប់ស្តើងនោះថង់នៃគីស្តមានទំហំធំដែលអាចច្រឡំជាមួយអេគីណូកូកូស៍ ប៉ុន្តែតាមធម្មតាវាតែងតូចជាង។

- ❖ **សំរេច ៖** ពេលរកឃើញ បរាសិតមិនត្រូវរឹបអូសទាំងអស់ទេ គេគ្រាន់តែកាត់កន្លែងដែលរាតត្បាតនោះ ចេញ និងជៀសវាងកុំឱ្យផ្អៃស៊ីសាច់ដែលមានបរាសិតនោះ។

**៣.៤ អេគីណូកុកកូស៍ ៖** ពពួកគីសរបស់ព្រូននេះច្រើនស្ថិតនៅក្នុងជាលិកាស្ពោត ថ្លើម ផាល ក្រលៀន សួត ហើយគេក៏តែងជួបប្រទះដែរនៅក្នុងជាលិកាសណ្ឋានសាច់ជុំឆ្អឹងប្រសាទ។ល។ គីសមានកូនព្រូន តាមធម្មតាមានពណ៌សស្លាំង ញ័រតិចៗ មានទំហំធំល្មមមានរាងមូលដូចស៊ុត រាងស៊ីឡាំងនៅពេលយកចេញមកក្រៅគ្មានរាងពិតប្រាកដទេ។ ផ្ទៃក្នុងរួមមានសន្ទះស្បែកស្តើងត្រួតគ្នា ពីខាងក្រៅមកសារជាតិស៊ីទីន (សារជាតិនៃសំបកក្តាម) ក្រាសត្រួតលើគ្នាជាសន្ទះហៅថាស្រទាប់ខាងក្រៅ។ ខាងក្នុងជាលិកាស្ពោត ស្តើងមានសណ្ឋានដូចជាជាលិកាសន្ទាន នៅលើផ្ទៃរបស់វាមានពោរពេញទៅដោយថង់ គឺជាថង់កូនមានរាងជាចុងអង្ករ។ ពេលណាយើងកាត់វាទឹកឥតពណ៌ចេញមកជួនកាលមានពណ៌លឿង ជួនកាលមានពណ៌ក្រហមដោយ មានឈាមតិចៗលាយជាមួយផង។ យូរៗទៅអេគីណូកូកកូស៍ ត្រូវចុះថយកម្លាំង ជាដំបូងត្រូវក្លាយជាសភាពក្រែមបន្ទាប់មកឡើងខាប់ជាដុំដូចទឹកដោះគោករ៉ឹដូចធរៀមាងេ។ និងបន្តិចម្តងៗទៅជាគ្រាប់ខ្សាច់ ១ជាលចារិបេ ដែលមានទំហំធំនៅជំ ណាក់កាលចុងក្រោយនេះ អាចមានការច្រឡំជាមួយរោគរបេង ប៉ុន្តែយើងអាចវិនិច្ឆ័យដោយងាយថា វាជាគីសដោយសារការពិនិត្យរួមផ្សំលើកូនកណ្តុរថែមទៀត។

- ❖ **សំរេច ៖** គេរកឃើញនូវអេគីណូកូកកូស៍ ត្រូវរឹមអូសកន្លែងមានគីស ក្រោយពីបានពិនិត្យពិច្ឆ័យច្បាស់លាស់ហើយ។
  - ចំពោះក្រពះពោះវៀន សួត បេះដូង ផាល និងថ្លើមវាអាចបំផ្លែងសរីរាង្គនីមួយៗជា

ភាគ រឺបំផ្លែងទាំងអស់។

- វត្តមាននៃគីសមានកកូននៅក្នុងនាំឱ្យសាច់ និងគ្រឿងក្នុងផ្សេងៗទៀត ធ្វើឱ្យមានគ្រោះថ្នាក់ណាស់ មិនមែនតែចំពោះមនុស្សទេ គឺធ្វើឱ្យឆ្លងចំពោះសត្វដ៏ទៃទៀត ជម្ងឺនេះឆ្លងទៅមនុស្សតាមរយៈសត្វឆ្កែ។
- ចំពោះចំណីសត្វធ្លា ឆ្កែអាចអនុគ្រោះឱ្យប្រើបានក្រោយពីការរំងាប់មេរោគក្រោមការត្រួតពិនិត្យ ដ៏ត្រឹមត្រូវរបស់បសុពេទ្យ ទីសត្វឃាដ គឺជាកន្លែងបាចសាចនៃជម្ងឺ។
- ចំណុចសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងគីសមានកកូន គឺហាមឃាត់ដាច់ខាតការចេញចូលនៃសត្វឆ្កែក្នុងទីសត្វឃាដ។
- ការដុតបំផ្លាញរឺការសំលាប់មេរោគនៅលើសរីរាង្គណាដែលមានគីសកកូន។
- មិនត្រូវកប់ចោលទេចំពោះគីសកកូនទាំងនោះក្លាចឆ្កែ ធ្លាស៊ី។

**៣.៥ អុងកូសែ៊ក រឺអុងកូសែ៊កកូស់ ៖** អុងកូសែ៊កច្រើនកើតនៅលើសត្វគោ-ក្របី ក្នុងនោះសត្វធំមានរហូតដល់៧០%។ អុងកូសែ៊ក ជាពពួកបរាសិតដែលរស់នៅក្នុងជាលិកាសរសៃ។ ចំពោះសត្វគោ-ក្របី គេច្រើនប្រទះឃើញនៅក្នុងសរសៃសន្លាក់ឆ្អឹង។ សរសៃដែលមាន បរាសិតដំបូងឃើញឡើងក្រាស់ និងមានភាពរីកធំ ក្រោយមកមានស្នាមចេញឈាម ស្នាមនោះមានពណ៌លឿងស្អាប់ដូចកំបោរ រឺគ្រាប់ខ្សាច់ (ដូចស្លាក់ស្នាម ជម្ងឺរបេងដែរ)។ នៅដំណាក់កាលដំបូងគេមិនអាចឃើញ បរាសិតទេ វាជាកំបោរទាំងអស់ដែលស្ថិតនៅកណ្តាលដុំពក ជាសរសៃមានពណ៌លឿងស្អាប់ អាចមានទំហំប៉ុនពងព្រាប បើសិនគេយកដុំពកនោះមកវះគេនឹងឃើញដុំកំបោរនៅចំកណ្តាល។

- **សំរេច ៖** វាមានសារៈសំខាន់ត្រង់វាមានស្លាកស្នាមជាសកម្មភាពថ្មកំបោរ ដែលអាចច្រឡំជាមួយជម្ងឺរបេង។ ទីតាំងពិសេសសភាពស្លាកស្នាមនៃជាតិសរសៃ និងការរកឃើញកំណាត់នៃបរាសិតដែលមានសកម្មភាពមុន សកម្មភាពនៃអាស៊ីត ដើម្បីធ្វើឱ្យបានជាតិកំបោរ ធ្វើឱ្យគេកំណត់បានច្បាស់ថាមិនមែនជម្ងឺរបេងទេ គេគ្រាន់តែកាត់ស្លាកស្នាមអុងកូសែ៊ក ជាការស្រេចត្រូវរឺបអូសជាភាគៗ បើសិនជាការរាលដាលមិនពាសពេញនោះទេ។

**៣.៦ សារកូស្តូរឺឌីយ៉ូស៍ ៖** ជាបរាសិតប្រភេទនេះស្ថិតនៅក្នុងជាលិកាសាច់ដុំ ចែកជាពីរក្រុម៖

**ក.បរាសិតក្នុងកោសិកា** ៖ ជារួមមានបណ្តាបរាសិតលូតលាស់ជាដំបូងនៅក្នុងសរសៃសាច់ដុំដើម្បី ចេញទៅរស់នៅដោយសេរីជាបន្តបន្ទាប់នៅក្នុងជាលិកាសន្ធានចន្លោះសាច់ដុំ។

**ខ.បរាសិតក្រៅកោសិកា** ៖ ជារួមមានបណ្តាបរាសិតដែលវិវត្តនៅក្នុងជាលិកាសន្ធានចន្លោះសាច់ដុំ។ ជម្ងឺនេះបណ្តាលមកអំពី បរាសិតដែលមានឈ្មោះថាសារកូស្តីឌីយ៉ូស៍ដែលជាបរាសិតមាននៅលើសត្វគោក្របី ជ្រូក (ជាពិសេសច្រើនមានកើតនៅលើសត្វគោ)។ស្លាកស្នាមនៃសារកូស្តីឌីយ៉ូស៍នៃពពួកសត្វជ្រូកគេពិបាក និងមើលឃើញដោយភ្នែកផ្ទាល់ណាស់។ ពេលណាវាអន់ថយកំលាំង

វាក្លាយទៅជាកកដូចថ្មកំបោរហើយមានពណ៌លឿងស្លាំង និងទំហំឡើងធំបើគេយកដៃស្ទាបសាច់គេនឹងឃើញហាក់ដូចជាគ្រាប់ខ្សាច់ម៉ត់ ។

**គ.កន្លែងត្រូវពិនិត្យ ៖** ពពួកបរាសិតច្រើនស្ថិតនៅក្នុងបេះដូង បំពង់អាហារ សន្ទះទ្រូង នៅលើផ្ទៃនៃសាច់ដុំ សាច់ចំឡក នៅក្នុងប្រអប់ទ្រូង ប្រអប់ពោះ និងនៅក្នុងសាច់ដុំធំៗទៀតផង។ ស្លាកស្នាមមានរូបរាងជាខ្សែឆ្នូតពណ៌ស រឺមានរាងផ្លូចមូល មានពណ៌ដូចគ្នា មានរាងជាបូសតូចៗ នៅចន្លោះបណ្តោយសាច់ដុំដែលមានទំហំធំតូចប្រហែលប៉ុនគ្រាប់ល្ហុងទៅគ្រាប់សណ្តែកខៀវ។

**ឃ.សម្រេច**

- ក្នុងករណីសារកូស្ពីរីឌីយ៉ូស៍ក្លាយទៅជាដូចទឹកដោះគោកក រឺថ្មកំបោរមានសភាពដូចដុំដីខ្សាច់ពាស់ពេញធ្វើឱ្យខូចគុណភាពសាច់ គេត្រូវហាមឃាត់មិនឱ្យយកសាច់ទាំងនោះទៅបរិភោគឡើយត្រូវរឹបអូសទាំងអស់។
- គេរឹបអូសទាំងអស់លុះត្រាណាការរាតត្បាតមានទំហំធំរឺច្រើនកន្លែងរឺ ច្រើនក្រុមនៅក្នុងសាច់ដុំផ្សេងៗ
- គេអាចអនុញ្ញាតឱ្យស្ងោរក្នុងរយៈពេល១ម៉ោង ប្រសិនណាស្លាកស្នាមមើលមិនឃើញ នោះជម្ងឺនេះក៏មិនអាចឆ្លងទៅមនុស្សដែរ។
- ចំពោះគ្រឿងក្នុងត្រូវរឹបអូសទាំងអស់ក្នុងករណីស្រាលគេអាចកាត់ចោលត្រង់កន្លែងកើតជម្ងឺ។

៣.៧ Trichinosis (**សាច់មានព្រូន** Trichinosis ) ៖ គឺជាព្រូនមូលតូចៗដែលអាចរស់នៅក្នុងសាច់ដុំជាច្រើន ក្នុងចំណោមនៃចំណែកសត្វនីមួយៗ និងរួមទាំងមនុស្សផងដែរ។ Trichinosis គឺជាបរាសិតមួយយ៉ាងកាចសាហាវហើយឆ្លងទៅមនុស្ស ប៉ុន្តែវាមានតិចតួចបំផុតនៅប្រទេសយើង។ បរាសិតនេះ វារស់នៅក្នុងភាពពេញរូបរាងក្នុងពោះវៀនដាប់ក្រពះ រួចហើយវាបំបែកខ្លួនទៅតាមកោសិកា និងដាលិកាផ្សេងៗទៀត។

**ក.លក្ខណៈ និងស្លាកស្នាម ៖** ស្លាកស្នាមមានរូបរាងជាគីស្ត ឬដុំពកដែលមានទំហំ ៣០០-១០០០មីក្រូម៉ែត្រ ហើយក្លាយទៅជាជាតិសរសៃសាច់ដុំមានពណ៌លឿងស្លាប់ដែលនៅក្នុងនោះមានព្រូនស្ថិតនៅចំនួន២-៣នៃគីស្តនីមួយៗ។ លុះយូរទៅគីស្តនេះក៏ថយចុះទៅៗប្រែពីជាតិកំបោរទៅជាដូចទឹកដោះគោកក។ ជួនកាលបរាសិតអាចមើលឃើញនឹងភ្នែកទទេបាន កាលណាការរាតត្បាតមានសភាពខ្លាំងក្លា ហើយគីស្តពីរស្ថិតនៅចាក់ស្រេះជាប់គ្នា។

**ខ.កន្លែងត្រួតពិនិត្យ ៖** គេឃើញមានស្លាកស្នាមនៃ Trichinosis នៅក្នុងសាច់ដុំ ដែលធ្វើ ការយ៉ាងសកម្ម ៖ ដូចជាសរសៃចុងសាច់ដុំ សាច់ដុំសន្ទះទ្រូង អណ្តាត បំពង់អាហារ ថ្គាល់ សាច់ដុំភ្លៅ ប៉ុន្តែក្នុងបេះដូងគ្មានទេ។

**គ.វិធានការ ៖** សាច់សត្វដែលកើតជំងឺ Trichinosis ត្រូវរំបែអូសទាំងអស់គ្មានលើកលែង ដោយមូលហេតុណាមួយទេ ព្រោះវានឹងឆ្លងដល់មនុស្ស។ តែបើក្នុងករណីស្រាល គេអាចសំលាប់មេរោគដោយបង្កកនៅសីតុណ្ហភាព-១៥អង្សាសេ រយៈពេល៨ម៉ោង ឬដាក់ស្ងោរក្នុងរយៈពេល១-២ម៉ោង អាចហូបបាន។

**៣.៨ សាច់មានជំងឺដង្កូវថ្លើម** 9 ធាសចិលៀសៀ៌ រៀ ឱសតៀមាតិសេ ប គឺជាពពួកបរាសិតមួយ ដែលតែងតែជួបប្រទះនៅក្នុងថ្លើមពពួកសត្វគោក្របី។ វាកើតឡើងដោយបរាសិតម៉្យាងឈ្មោះហ្វាស៊ីយ៉ូឡាអេប៉ាទីកា (Fasciola hepatica)។

**ក.រោគវិនិច្ឆ័យ 9ជិងានៀសិស ប ៖** ជំងឺដង្កូវក្នុងថ្លើមមានសភាពងាយស្រួលបំផុតគឺ គេអាចរកឃើញក្រោយពេលពិនិត្យថ្លើម ឬក្រោយពេលស្ទាបសរីរាង្គនោះ ឬជួនកាលក្រោយពេលវះរន្ធទឹកប្រមាត់។ ជួនកាលទីតាំងរបស់បារ៉ាស៊ីតអាចមាននៅក្នុងសួត ឬនៅក្នុងសាច់ដុំដែលមានពណ៌ ត្នោតទុំ។ នៅប្រទេសយើង គេប្រទះឃើញមានជំងឺនេះជិតដល់ ៨០% ដែលកើតមាននៅលើសត្វគោក្របីពេលដែលជំងឺស្ថិតក្នុងសភាពរាំរ៉ៃ ធ្វើអោយបំពង់ទឹកប្រមាត់រីកធំ ហើយមានសភាពក្រាស។

**ខ.សំរេច ៖** ការរំបែអូសធ្វើចំពោះតែសរីរាង្គណាដែលកើតជំងឺ ដូចជា ៖ ការរំបែអូសជាភាគ ការរំបែអូសទាំងអស់ ឬទាំងមូលវាអាស្រ័យទៅលើទំហំនៃមេរោគ (ជំងឺនេះវាមិនអាចឆ្លងទៅមនុស្សទេ)។

**៣.៩ សាច់មានជំងឺ (ត្បាផហានុរៀសេ )** គឺជាដង្កូវមានរាងស៊ីឡាំង ហើយទន់ ពណ៌ក្រម៉ៅ និងមានរូបរាងតូច (ចំពោះឈ្មោលមាន ទំហំ ៖ ២,៥ស.ម និងញីមានទំហំ ៖ ២,៨ស.ម)។ លក្ខណៈស្លាកស្នាម ច្រើនស្ថិតនៅក្នុងស្រទាប់ជ្រៅនៃជាលិកាខ្លាញ់ដូចជា នៅរុំព័ទ្ធក្រលៀន បំពង់នោម និងកន្លែងទាំងនោះមានសភាពក្រាស់។ នៅពេលដែលមានកើតដង្កូវច្រើនគឺគេឃើញ នៅខាងលើបំពង់នោម ក្រលៀន និងកន្សោមភាគខាងលើនៃក្រលៀនទៅជាដុំពកគ្មានខ្លាញ់។ ពេលណាយើងវះដុំពកនោះ យើងនឹងឃើញដង្កូវញី ឈ្មោលដែលស្ថិតនៅក្នុងនោះ ហើយមានទឹកពណ៌ បៃតងខ្ចី និងដង្កូវញីមានសុទ្ធតែពង។ ហេតុដូចនេះនៅក្នុងទឹកនោម ឬប្លោកនោមពោរពេញទៅ ដោយប៉ារ៉ាស៊ីត និងជួនកាលមានអំប្រ៊ីយ៉ុងញាស់ ហើយក៏មានការរាតត្បាតទៅដល់សួត ផាល និងថ្លើមផងដែរ។

**ក.លក្ខណៈស្លាកស្នាមមានដូចតទៅ ៖** ថ្លើមហើមជាំ និងមានទំហំធំលើសពីរដងបើប្រៀបធៀប ទៅនឹងទំងន់ធម្មតា។ នៅលើផ្ទៃថ្លើមមានគ្រាប់តូចៗពណ៌ស ដែលនៅពេលវះជាលិកានេះយើងនឹង ឃើញបរាសិត ចេញមក។

**ខ.សំរេច ៖** ចំពោះសាច់សត្វដែលមានបរាសិតត្រូវរំបែអូសទាំងអស់ដោយរួមទាំងផ្ទាំងសាច់ និងគ្រឿងក្នុង។ នៅពេលណាមានការរាតត្បាតរបស់បរាសិតមានសភាពខ្លាំងក្លាពេលនោះ យើងឃើញសត្វមានលក្ខណៈស្គមស្គាំង និងស្លេកស្លាំង។ បើសិនជាការរាតត្បាតមានតែនៅជុំវិញបំពង់ទឹក

នោម និងស្ថានភាពសុខភាពសត្វមិនសូវធ្ងន់ធ្ងរទេនោះ ដូច្នេះយើងគ្រាន់តែកំទេចចោលតែសរីរាង្គណាដែលមានបរាសិត និងគ្រឿងក្នុងតែប៉ុណ្ណោះ។

**៣.១០សាច់មាន ឡើចហៀចរបៀសេ ៖** គឺជាប៉ារ៉ាស៊ីតមួយប្រភេទ ដែលច្រើនកើតមាននៅលើកូនសត្វដូចជា ៖ គោក្របីមានរហូតទៅដល់ ៧០%។ ៀនចហៀចរបៀសេ គឺជាប៉ារ៉ាស៊ីតដែលរស់នៅក្នុងជាលិកាសរសៃ ចំពោះសត្វគោក្របីគេប្រ ទះឃើញនៅក្នុងសៃសៃសន្លាក់ឆ្អឹង។ សរសៃដែលមានប៉ារ៉ាស៊ីតរស់នៅ គឺលើងក្រាស់និងមានសភាព រីកធំក្រោយមកមានស្នាមចេញឈាម ឬស្នាមលឿងស្អាប់ គឺវាមានស្លាកស្នាមដូចជំងឺរបេងដែរ។ នៅក្នុងតំណាក់កាលដំបូង គេមិនអាចមើលឃើញប៉ារ៉ាស៊ីតទេ វាជាកំបោរទាំងអស់ដែលស្ថិត នៅកណ្តាលដុំពក ជាសរសៃពណ៌លឿងស្អាប់ ហើយបើយើងយកដុំពកនោះមកវះគេនឹង ឃើញដុំកំបោរនៅចំកណ្តាល។

ចំណាំ ៖វាមានសារៈសំខាន់ត្រង់មានស្លាកស្នាម និងសភាពជាថ្មកំបោរ ក៏ប៉ុន្តែវាអាចច្រ ឡំទៅនឹងជំងឺរបេងដែរ។ ទីតាំងពិសេស,សភាពស្លាកស្នាមនៃជាលិកាសរសៃ និងការរកឃើញនៃ ប៉ារ៉ាស៊ីតមានសកម្មភាពមុននៃសកម្មភាពអាស៊ីត គឺដោយសារអត្រានៃកំបោរដែលធ្វើអោយយើងកំ ណត់បានច្បាស់លាស់ថា ៖មិនមែនជាជំងឺរបេង។ ដូច្នេះត្រូវរឹបអូសជាភាគៗនៅកន្លែងដែលមានស្លាកស្នាម។

## ៤.សាច់មានបរាសិតអាចឆ្លងទៅមនុស្សដោយផ្ទាល់

**៤.១ សាច់មានព្រូនទ្រីគីន ៖** គឺជាព្រូនមូលតូចដែលអាចរស់នៅក្នុងសត្វ ជាច្រើនក្នុងចំណោមថនិកសត្វ រួមទាំងមនុស្សទៀតផង។ បរាសិតនេះ វាវិវត្តជីវិតរបស់វានៅក្នុងកន្លែងតែមួយ និងក្នុងសារពាង្គកាយសត្វមានជីវិតតែមួយ។ ទ្រីគីនជាបរាសិតម៉្យាងកាចសាហាវហើយឆ្លងទៅមនុស្ស (ប៉ុន្តែមានតិចតួចបំផុតនៅប្រទេសយើង) ទ្រីគីននេះ វារស់នៅក្នុងសភាពពេញវូបពេញរាងក្នុងពោះវៀនជាប់ក្រពះរបស់បក្សី និងថនិកសត្វមួយចំនួន។

**ក.លក្ខណៈនៃស្លាកស្នាម ៖** នៅពីក្រៅផ្ទាំងសាច់គ្មានសញ្ញាអ្វីគួរឱ្យចាប់អារម្មណ៍ឡើយ ស្លាកស្នាមរលាកច្រើនមាននៅលើផ្ទៃឆ្អឹង។ ហេតុនេះធ្វើការស្រាវជ្រាវដោយមីក្រូទស្សន៍ គឺជាវិធីមួយក្នុងការរកឱ្យឃើញជម្ងឺទ្រីគីន។ នៅក្នុងសាច់ដុំដែលរាតត្បាតដោយបរាសិតនេះស្ថិតក្នុងគីសនៅចន្លោះសរសៃសាច់ដុំ (រន្ធគឺលទ្ធផល នៃប្រតិកម្មនៃការរលាកជាលិកាសន្ទាននៃសាច់ដុំ) ជាទូទៅមានរាងជាអូវ៉ុលពងសត្វនៅស្រោប និងសរសៃសាច់ដុំ ទំហំជាមធ្យម (បណ្តោយមាន៤០០µ និងទទឹង៥០µ)។

នៅក្នុងសាច់ដែលរាតត្បាតខ្លាំងគេឃើញមាន គីស២-៣គ្រាប់រួមគ្នា។ ជួនកាលវាមានទំនាក់ទំនងជាមួយគ្នាជួនកាលវាឃ្លាតពីគ្នាដោយសារជាលិការនៃគីស។ នៅកណ្តាលគីសគេឃើញនូវបរាសិត ដែលវារុំខ្លួនវាជាច្រើនជុំ។

**ខ.កន្លែងត្រួតពិនិត្យ ៖** គេច្រើនរកឃើញស្លាកស្នាមនៃបរាសិតប្រភេទទ្រីគីននេះ នៅក្នុងសាច់ដុំដែលធ្វើការយ៉ាងសកម្ម ដូចជាសរសៃនៅចុងសាច់ដុំ សាច់ដុំសន្ទះទ្រូង អណ្តាត ថ្គាល់បំពង់អាហារ សាច់ចន្លោះឆ្អឹងជំនី សាច់ភ្លៅ ប៉ុន្តែនៅប៉េះដូងគ្មានទេ។ ក្នុងការពិនិត្យគេសង្កេតរក

ស្លាកស្នាមនៅក្នុងសាច់ដុំសន្ទះទ្រូង ចន្លោះឆ្អឹងជំនី និងដើមបំពង់ក។

**គ.ការពិនិត្យលើបដិរូបនៅក្នុងមន្ទីរពិសោធន៍ ៖**

- សាច់កើតជំងឺទ្រីគីនី ត្រូវរឹបអូសទាំងអស់ គ្មានលើកលែងទេ ដោយមូលហេតុ វាជាជម្ងឺឆ្លងទៅមនុស្ស។
- ក្នុងករណីស្រាលគេអាចសំលាប់មេរោគដោយធ្វើការបង្កកក្នុងសីតុណ្ហភាព-១៥ អង្សាសេ ក្នុងរយៈពេល៨ ថ្ងៃ រឺ ស្ងោរក្នុងរយៈពេលពី១-២ម៉ោង។

**៤.១ ចុងអង្ករក្នុងសាច់ជ្រូក ៖** បរាសិតតែងតែជួបប្រទះ ជាពិសេសលើជ្រូកដែលចិញ្ចឹមលែងក្នុងប្រទេសយើង វាបណ្តាលមកពីចុងអង្ករនៃ តេញ៉ាសូរ្យមដែលជាដង្កូវព្រូនទោលរបស់មនុស្ស ពេលណាមនុស្សហូបសាច់មិនឆ្អឹងល្អគេ និងកើតតេញ៉ា។ សាច់ជ្រូកកើតចុងអង្ករគ្មានលក្ខណៈអ្វីមួយគួរឱ្យពិនិត្យឃើញពិសេសនោះទេ ទោះប្បីការរាតត្បាតខ្លាំងយ៉ាងណាក៏ដោយគេគ្រាន់តែសង្កេតឃើញពណ៌របស់សាច់មានពណ៌ប្រផេះ ស្លាំង (មួយផ្នែករួមជាមួយ ការជ្រាតចូលនៃជាលិការ) សាច់សើមស្រក់ទឹក.ត្រជាក់ពេលយើងស្ទាបដោយសារការរាតត្បាតនៃបរាសិត មានដំណើរយឺតគេត្រូវពិនិត្យសាច់ទាំងអស់តាមបែបបទដូចតទៅ ៖

**ក.ចំពោះផ្ទាំងសាច់ទាំងមូល** ៖ ដំបូងគេពិនិត្យផ្ទៃសាច់ភ្លៅបន្ទាប់មកនៅចន្លោះឆ្អឹងសន្ទះទ្រូង និងពោះទី បញ្ចប់គឺកន្លែងប្រជុំក បន្ទាប់មកទៀតគេបើកមើលខាងក្នុងប្រអប់ទ្រូង និងពោះ (ដើម្បីពិនិត្យមើលត្រីកោណ នៃឆ្អឹងសន្ទះទ្រូងខាងក្នុងពោះ និងផ្នែកខាងក្រោមចង្កេះ)។ ឆ្លងកាត់ការពិនិត្យដោយយកចិត្តទុកដាក់ គ្រាប់អង្ករវាស្តែងឡើងក្រោមរូបភាពជាថង់តូចៗ ស្ថិតនៅតាមបណ្តោយសរសៃសាច់ដុំមានពណ៌ប្រផេះពេញ ទៅដោយទឹកគ្មានពណ៌គ្រាប់នេះថ្លាៗ ដែលក្នុងនោះមានចំណុចមួយតូច។

**ខ.វិធានការ ៖** សាច់ចុងអង្ករត្រូវរឹបអូសទាំងអស់រួមទាំងគ្រឿងក្នុងពេលណាមានការាតត្បាតខ្លាំងខ្លា បានន័យថាពេលនោះចំនួនចុងអង្ករលើសពីរ ៣០គ្រាប់/គីឡូសាច់។ ប៉ុន្តែបើសិនការរាតត្បាតបន្តិចបន្តួច ដែលសន្មត់ថាសាច់រាតត្បាតបន្តិចបន្តួចនោះនៅពេលគេជួបប្រទះចុងអង្ករ ចំនួន ២គ្រាប់យ៉ាងច្រើនក្នុងផ្ទៃសាច់១ដម៣ គេអាចអនុញ្ញាតឱ្យយកទៅស្ងោរក្នុងរយៈពេល២ម៉ោង យ៉ាងតិចក្រោយមកគេកាត់សាច់ជាដុំៗក្នុង១ដុំមានទំងន់ពី០,៥-១គីឡូក្រាម។ សាច់ត្រូវតែឆ្អិនគឺបានន័យថាពេលគេកាត់សាច់មានពណ៌ស។ តាមធម្មតាចុងអង្ករត្រូវបានសំលាប់ក្នុងសីតុណ្ហភាព៦០អង្សាសេ។ ក្រៅពីស្ងោរគេអាចអនុញ្ញាតឱ្យរក្សាទុកក្នុងភាពត្រជាក់-១៥អង្សាសេ(បង្កក) និងត្រាំទឹកអំបិល ហើយកំរិតសីតុណ្ហភាព-១៥ អង្សាសេ ចំនួន ៥៤ម៉ោង។ ត្រាំទឹកអំបិល៣២គីឡូ និងលាយទឹក១០០លិត្ររយៈពេល២១ថ្ងៃ ហើយទឹកអំបិលនេះ ប្រើបានតែម្តងទេ។ ចុងអង្ករអាចរស់បានតែប៉ុន្មានខែប៉ុណ្ណោះក្រោយមកចុងអង្ករងាប់នៅក្នុងសាច់ហើយក្លាយជាកករឹង រឺជាថ្មកំបោរគេឱ្យឈ្មោះថា(ចុងអង្ករស្ងួត)។ គេជួបប្រទះចុងអង្ករស្ងួតនេះម្តងម្កាលទេ ជួនកាលវាលាយឡំ ជាមួយចុងអង្ករថ្លារឺចុងអង្កររស់។ កាលណាចុងអង្ករស្ងួតមានចំនួនច្រើន វាបណ្តោលឱ្យសាច់មានភាពគួរឱ្យខ្ពើម គឺមិនអនុញ្ញាតឱ្យលក់ដូរ

បានទេ ត្រូវរើបអូសទាំងស្រុង។

**៤.២ ចុងអង្ករក្នុងសាច់គោ ៖** ចុងអង្ករក្នុងសាច់គោពិបាកពិនិត្យជាងចុងអង្ករក្នុងសាច់ជ្រូក។ គេអាចនិយាយថាការរាតត្បាតមានច្រើន តែគ្មានលក្ខណៈអ្វីដែលទាក់ទាញឱ្យមានការប្រុងប្រយ័ត្នទេ តែគេអាចរកឃើញចុងអង្ករនៅពេលវះសាច់ គេត្រូវពិនិត្យមើលលើចំនុចមួយចំនួនដូចជា សាច់ដុំថ្គាម ថ្ពាល់ បេះដូង អណ្តាត សន្ទះទ្រូង។ល។ ចុងអង្ករនៅក្នុងសាច់គោច្រើនស្រួយ ជាងចុងអង្ករនៅក្នុងសាច់ជ្រូក ដែលនាំឱ្យវាបាត់រូបយ៉ាងរហ័សនៅពេលណាទឹកក្នុងថង់របស់វាត្រូវវិឆ្លាយហើយ ការរកមើលក៏ពិបាក។ ពណ៌ក្នុងថង់របស់ចុងអង្ករមានពណ៌ផ្កាឈូក រឺសុខកូទ្យាដែលមានតិចបំផុតក្នុងសាច់ជ្រូក ចុងអង្ករអាចថយកំលាំងហើយក្លាយជាកំបោរ រឺចុងអង្ករស្ងួត (ចំពោះសត្វគោអាចប្រឡំគ្នា និងជម្ងឺរបេង)។ ការពិនិត្យលំអិតលើបណ្តាកន្លែងដែលត្រូវពិនិត្យមាន៖

**ក.ពិនិត្យសាច់ថ្ពាល់ ៖** គេពិនិត្យបន្តបន្ទាប់សាច់ថ្ពាល់ទាំងខាងក្នុង និងផ្ទៃកខាងក្រៅជួនកាលគ្រាន់តែពិនិត្យធម្មតាគេអាចរកឃើញចុងអង្ករនៅលើផ្ទៃសាច់ គេស្ទាប់មើលគ្រាប់អង្ករមានភាពដូចជាគ្រាប់សំណរវាស្ថិតនៅក្នុងជំរៅនៃសរសៃសាច់ដុំ។ គ្រប់ករណីវះពិនិត្យមើលជាការខានមិនបាន គឺវះជាឆ្នូត២ស្របគ្នា និងឆ្អឹងថ្គាមខាងក្រោម នៅក្នុងសាចដុំ ហើយត្រូវមានការប្រុងប្រយ័ត្នក្នុងការងារនេះ ។

**ខ.ពិនិត្យអណ្តាត ៖** ជួនកាលនៅជាប់ជាមួយក្បាលជួនកាលព្យួរនៅនឹងទំពក់គេត្រូវពិនិត្យជាដំបូងពីខាងក្រោមបន្ទាប់មកវះតាមបណ្តោយអណ្តាតពេលនោះអាចឃើញគ្រាប់អង្ករបើសិនជាមាន។

**គ.ពិនិត្យបេះដូង ៖** ក្រោយពីបកស្រោមបេះដូងខាងក្រៅចេញគេពិនិត្យរកគ្រាប់អង្ករ ពីលើផ្ទៃខាងក្រៅក្នុងករណីដែលបានពិនិត្យរបៀបនេះមិនបានជួបប្រទះចុងអង្ករទេ គេត្រូវបន្តវះតាមបណ្តោយពីលើមកក្រោម ។

**ឃ.ពិនិត្យសន្ទះទ្រូង ៖** សន្ទះទ្រូងត្រូវបានដាក់នៅលើតុ គេស្ទាបដោយដៃ គេបកស្រោមស្ងួត និងស្រទាប់ប្រអប់ពោះចេញ ហើយគេវះមើលជាច្រើនឆ្នូត ក្រោយពីបានពិនិត្យមើលដោយល្អិតល្អន់លើចំនុចសំខាន់ៗ ដែលត្រូវពិនិត្យចប់សព្វគ្រប់ហើយមានករណីខ្លះដែលត្រូវអនុវត្តដូចតទៅ ៖

- **ករណីទី១ ៖** បើគ្មានជួបប្រទះចុងអង្ករណាមួយទេគឺគ្មានប្រយោជន៍អ្វីបន្តទៅពិនិត្យផ្ទាំងសាច់ទេហើយ ផ្ទាំងសាច់ត្រូវបានប្រកាសថាគ្មានជម្ងឺនេះទេ ។
- **ករណីទី២ ៖**គ្រាប់ចុងអង្ករមួយគ្រាប់រឺច្រើនគ្រាប់ត្រូវបានរកឃើញលើចំនុចសំខាន់ៗដែលបានរៀបរាប់ខាងលើនេះចាំបាច់ត្រូវបន្តពិនិត្យក្នុងប្រព័ន្ធសាច់ដុំទៀត។ ថង់ចុងអង្កររបស់សត្វគោ.ក្របី តែងតែជួបប្រទះនៅក្នុងជាលិកាសន្ធាន នៅចន្លោះសាច់ដុំច្រើនជាងនៅក្នុងសាច់ដុំចន្លោះឆ្អឹងជំនី សាច់ដុំប្រអប់ទ្រូង សាច់ដុំស្មា និងសាច់ដុំក។
- មានករណីលើកលែងជាពិសេស គឺមិនដែលជួបប្រទះចុងអង្ករនៅក្នុងថ្លើម ផាលក្រលៀនស្ងួត ទោះបីជាការរាតត្បាតមានភាពខ្លាំងក្លាយ៉ាងណាក៏ដោយ។

**ង.វិធានការ ៖** មានច្រើនករណីដែលត្រូវយកចិត្តទុកដាក់ ៖

- បើសិនជួបចុងអង្គរដែលថយកំលាំងទៅជាចុងអង្គរស្ងួត ចង់មានចុងអង្គរងាប់អាស្រ័យទៅតាមទំហំនៃការរាតត្បាត និងលក្ខណៈគួរឱ្យខ្ពើមនៃសាច់ការរើបអូសត្រូវអនុវត្តជាភាគ។
- នៅពេលមានគ្រាប់អង្គរ១គ្រាប់រឺច្រើនគ្រាប់នៅរស់នៅក្នុងគ្រឿងក្នុង និងសំណល់ថ្លាល់ បេះដូង អណ្តាត សន្ទះទ្រូង បំពង់ក ប៉ុន្តែគ្មានមួយគ្រាប់ណានៅក្នុងផ្ទាំងសាច់ៗ នោះត្រូវបានអនុញ្ញាតឱ្យយកទៅលក់ រឺហូបចុកបាន ប៉ុន្តែគ្រឿងក្នុងត្រូវរើបអូស ប៉ុន្តែមានវិធានការណ៍សមស្រប ។
- បើសិនណាមានចុងអង្គររស់ច្រើនកុះកក្នុងផ្ទាំងសាច់ត្រូវអនុវត្តការរើបអូសទាំងអស់ ។
- ករណីដែលមានចុងអង្គរតិចបានន័យថា មានចុងអង្គរចំនួន១គ្រាប់/ ដុំៗ គេត្រូវអនុញ្ញាតឱ្យយកទៅស្ងោររយៈពេល ២ម៉ោង ឬអនុញ្ញាតឱ្យធ្វើការបង្កកក្នុងសីតុណ្ហភាព០អង្សាសេក្នុងរយៈពេល១០ថ្ងៃ។ ការសំលាប់មេរោគដោយបង្កកល្អជាងស្ងោរ ព្រោះសាច់មិនបានកាត់ជាដុំហើយសាច់ធានាគុណភាពក្នុងការលក់ ដូរទៀតផង។

## ៥.សាច់គួរឱ្យខ្ពើម

និយាយឱ្យចំ គឺសាច់ដែលបានមកពីសត្វដែលមានជម្ងឺទាំងអស់ គឺសុទ្ធតែជាសាច់គួរឱ្យខ្ពើមបណ្តាលមកពីពណ៌ និងក្លិនរបស់វាដែលមិនធម្មតា។

**៥.១ ដុំពក ៖** ការរកឃើញដុំពកនៅក្នុងគ្រឿងក្នុង រឺនៅលើផ្ទាំងសាច់វាផ្តល់នូវទិដ្ឋភាពមួយដែលបន្ថយគុណភាពនៃកន្លែងដែលកើតរាតត្បាតនោះ។ ដុំពក គឺជាការរីកធំយ៉ាងខ្លាំងនៃបណ្តាកូនកណ្តុរមានពេលខ្លះវាមានទំហំប៉ុនកដៃមានពណ៌ប្រផេះ ទន់ជ្រាយ ផ្ទាំងសាច់ដែលមានដុំពកពាសពេញធ្វើឱ្យមានការខ្ពើមដល់ការហូបចុក ។

### ៥.២ ពណ៌សាច់

**ក.សាច់ពណ៌លឿង ៖** សត្វកើតជម្ងឺលឿងធ្វើឱ្យសាច់មានពណ៌លឿង ដោយវាទទួលជាតិលឿងពីទឹកប្រម៉ាត់ដែលវាបណ្តាល មកពីការរាតត្បាតនៃពួកបរាសិត តាមរយៈផ្លូវឈាម។ ឡផេតៀសធិរៀសេ រឺដោយជាតិពុល រឺដោយករណីផ្សេងៗ ទៀតដែលបណ្តាលឱ្យថ្លើមរងរបួស ហើយធ្វើឱ្យស្ទះបំពង់ ប្រម៉ាត់ ផាលរីកធំ។ លក្ខណៈពិសេសគឺខ្លាញ់សាច់ ជាលិកាក្រោមស្បែក ឆ្អឹងស្តោត សរសៃពួរបេះដូង តំរងនោម ថ្លើមសុទ្ធតែមានពណ៌លឿងទាំងអស់ សាច់មានចំហាយក្លិនស្អុយជួនកាលមានជាតិល្វីង តាមធម្មតាកន្លែងណានៅ ជិតសរសៃឈាមកន្លែងនោះច្រើនលឿងជាងគេ។

**ខ.ដៅធិខៀនាតហៀសេ ៖** ចំពោះជ្រូកមានពណ៌លឿងនៅត្រង់ខ្លាញ់តែប៉ុណ្ណោះហេតុដែលបណ្តាលឱ្យមានពណ៌លឿងនៅលើខ្លាញ់នេះ គឺដោយជ្រូកចាស់ ដោយស៊ីចំណីដូចជាចករឹកំប្លោក

ភាពខុសគ្នាជម្ងឺលឿង និងខ្លាញ់លឿង៖

- **ជម្ងឺលឿង ៖** មានភាពលឿងលើស្បែក និងខ្លាញ់
- **ខ្លាញ់លឿង ៖** មាននៅតែលើខ្លាញ់ទេ រីឯស្បែកមានសំបុរធម្មតាប៉ុន្តែការកត់សំគាល់នេះពុំទាន់បានត្រឹមត្រូវទេត្រូវតែធ្វើការវិភាគទើបច្បាស់លាស់។

**គ.សំរេច**

- បើខ្លាញ់លឿងអាចអនុញ្ញាតឱ្យយកទៅបរិភោគបាន ប៉ុន្តែបើលក់ដូរវិញតំលៃសេដ្ឋកិច្ចត្រូវចាត់ ទុកជាថ្នាក់លេខ២
- បើសិនសាច់លឿងត្រូវចាប់ និងកំទេចចោលឱ្យអស់។

**៥.៣ សាច់ពណ៌បៃតង**

សាច់មានពណ៌បៃតងដោយមូលហេតុ ៖

- ដោយការរាតត្បាតរបស់ពួក បរាសិត
- ដោយសារផលវិបាកនៃជម្ងឺលឿង
- ដោយប្រើថ្នាំ
- ដោយកូនកណ្តុរទទួលមេរោគ
- ដោយសារការចេញឈាមតាមមុខរបួស

**<u>សំរេច</u>**

- លើផ្ទាំងសាច់មានពណ៌បៃតងដោយជម្ងឺលឿងរឺដោយប្រើថ្នាំ ទរិពនេបពលេ៉ ត្រូវកំទេចចោលទាំងអស់
- បើផ្ទាំងសាច់មានពណ៌បៃតងដោយអន្លើៗយើងត្រូវកាត់កន្លែងនោះចោលក្រៅពីនោះអាចអនុញ្ញាត ឱ្យយកទៅប្រើប្រាស់បាន
- បើផ្ទាំងសាច់គ្មានពណ៌បៃតងទេតែកូនកណ្តុរមានពណ៌បៃតងសាច់ត្រូវរឹបអូស និងកំទេចចោល។

**៥.៤ សាច់ពណ៌ត្នោត ៖** គេអាចប្រទះឃើញពណ៌ត្នោតនៅលើជាលិកាសន្ធាន លើផ្នែកស្រទាប់ប្រអប់ពោះ ស្រទាប់នៃឆ្អឹងវែង ខួរឆ្អឹង។ បច្ចុប្បន្ននេះ គេរកមូលហេតុដែលធ្វើឱ្យសាច់មានពណ៌ត្នោតមិនទាន់ឃើញនៅឡើយទេ គេគ្រាន់តែសង្ស័យប្រហែលវាទទួលជាតិពណ៌ត្នោតពី កៀធិហិលុិ នាដខឿយដេ ដេ ធរេ។

**<u>សំរេច</u>**

- ផ្ទាំងសាច់នៅល្អយើងគ្រាន់តែកាត់កន្លែងពណ៌ត្នោតចេញបានហើយ
- ក្នុងករណីផ្ទាំងសាច់មានពណ៌ត្នោតផង និងថយគុណភាពផងគឺត្រូវរឹបអូស និងបំផ្លាញចោល

**៥.៦ សាច់មានពណ៌ខ្មៅ ៖** សាច់មានពណ៌ខ្មៅ ហើយមានសារជាតិមេឡាមីន កន្លែងខ្មៅមានដុំពកដែលមានទំហំប៉ុនពងមាន់គេអាចប្រទះឃើញនៅលើស្មា ជុំវិញគូថ និងលើថ្លើម ចំណុចខ្មៅតូចៗ

ច្រើនមានពាសពេញលើផ្ទាំងសាច់លើគ្រឿងក្នុងសំរេចត្រូវរឹបអូសបំផ្លាញចោលទាំងស្រុង។

**៥.៧ សាច់មានពន្លឺផ្លេកៗ ៖** នៅពេលយើងកាត់សាច់យើងឃើញពណ៌លឿងផ្លេកៗ (ដូចមុខនាឡិកាពេលយប់) ការចេញពន្លឺអាច ឃើញនៅលើជាលិកាសន្ធានគេចាត់ទុកថាវាមាននូវមីក្រុប ដែល

បណ្តាលឱ្យមានរោគដូចជា ៖

- ពាចិលៀសេ ឡូម៉ិនៀសិស (លុយមីណូស៊ីស)
- ◌្យ◌ិ នៅ◌ៀ ផហៀសផហៀរសិស (ស៊ីអាណូផូស្ព័រស៊ីស )
- ងៅនេ ផហៀស ផហៀរសិស (អាជែន ផូស្ព័រស៊ីស )

ក្នុងករណីសាច់មិនពុលទេប៉ុន្តែបាត់បង់គុណភាពហេតុនេះត្រូវស្ងោរ។

**៥.៨ សាច់ធំក្លិន ៖** គេអាចចែកក្លិនជាពួកដូចតទៅ ៖

- ក្លិន (ប័រ) គឺជាក្លិនដូចប័រមានតិចតួចចំពោះគោក្របី ដែលអាចងាប់នៅជម្ងឺបូសខ្យល់
- ក្លិន ៖ ក្លរ៉ូហ្វម សាច់សត្វគ្រុន .
- ក្លិន ៖ អាសេតូន សាច់សត្វកើតជម្ងឺអាសេតូន កើតជម្ងឺ ឱបា◌េតែ (ទឹកនោមផ្អែម រឺ ប្រៃ)
- ក្លិនលាមកៈ គេអាចសង្កេតឃើញជួនកាលនៅផ្ទាំងសាច់ស្អាតល្អ មូលហេតុបណ្តាលមកពីការវះពោះមានការយឺតយ៉ាវ ប៉ុន្តែជាទូទៅច្រើនលើកមានក្នុងករណីដែលមានជម្ងឺក្នុងបំពង់រំលាយអាហារជាពិសេស គឺជម្ងឺហើមពោះស្រួចស្រាវ។ ក្នុងករណីហើមពោះ ផ្ទាំងសាច់និងគ្រឿងក្នុងត្រូវរឹបអូសហើយហាមមិនឱ្យយកទៅបរិភោគ
- ក្លិនថ្នាំៈ គឺជាបច្ច័យនៃការផ្តល់ថ្នាំគ្រប់ប្រភេទនៅពេលព្យាបាល។ រួមមានក្លិនអាម៉ូញាក់ អេទែ អាលកុល។ល។ តាមច្បាប់ គឺត្រូវរឹបអូសទាំងអស់ ដោយមូលហេតុម៉្យាងសត្វមានជម្ងឺម៉្យាងទៀត ដោយសារការជ្រួតជ្រាបនៃជាតិគីមីពាសពេញផ្ទាំងសាច់
- ក្លិនពីប្រភពចំណីអាហារ ភាគច្រើនមានក្លិនពិសេស និងក្រអូបមានជ្រាបយ៉ាងខ្លាំងទៅក្នុងជាលិកា បើសិនសត្វស៊ីបានគ្រប់គ្រាន់។
- ក្លិនមានរោគ ៖ ក្លិនមួយត្រូវបានឱ្យសញ្ញាដូចក្លិនទឹកនោមចំពោះអាយុច្រើន រឺមកពីការជ្រៀបទឹកនោម ចូលទៅក្នុងស្រទាប់ប្រអប់ពោះដោយសារការដាច់ធ្លាយប្លោកនោមបំពង់ទឹកនោមក្នុងករណីនេះត្រូវរឹប អូសទាំងស្រុង
- ក្លិនភេទ ៖ គេតែងជួបប្រទៈនៅលើសត្វឈ្មោល នូវក្លិនសារ(មិនអាចទ្រាំបាន) ដែលមានប្រភពពីទឹកនោមជាពិសេសជ្រូក។ ជារួមសាច់ទាំងនេះត្រូវកំចាត់ចោលដោយសារវាមានក្លិនមិនល្អ ដែលមិនអាច បរិភោគបាន។

**៥.៩ សាច់ស្អុយរលួយ ៖** សាច់ដែលស្អុយរលួយខ្លាំងត្រូវតែរឹបអូស។ អាកាសធាតុក្តៅហើយសើម គឺជាមូលហេតុដែលអាចធ្វើឱ្យសាច់ឆាប់ស្អុយរលួយ។ ការពិឃាដនៅពេលសត្វជិតស្លាប់ការវះពោះមានការយឺតយ៉ាវ ការបង្ហូរឈាមមិនអស់ និងការលាងផ្ទាំងសាច់មិនស្អាត។ ការស្អុយរលួយមានពីលក្ខណៈ

**ក.ការស្អុយរលួយគ្រឿងក្នុង**

- សួតជាំខ្មៅមានស្នាមពណ៌បៃតងពេលយើងស្ទាបឮសូរព្រួកៗ
- ថ្លើមខ្មៅស្អិតហើយស្រួយ ផាលព្រោកៗ

- ក្រលៀនឡើងពណ៌បៃតងគេកាត់មើលឃើញដូចពណ៌ដីក្លិនអាក្រក់
- ពោះវៀនពណ៌ត្នោត រឺបៃតងក្រម៉ៅ
- ខួរដូចបាយពុះពណ៌ស ប្រផេះ (មានពពុះ) គេអាចយកម្រាមដៃចុចទៅក្នុងរន្ធភ្នែក គ្រាប់ភ្នែកឡើងស្អិត ពេលដកដៃមកវិញវានូវជាប់ក្លិនស្អុយជានិច្ច។

**ខ.ការស្អុយរលួយផ្ទាំងសាច់ ៖** គេធ្វើការស្រាវជ្រាវរកការស្អុយរលួយជាដំបូងនៅត្រង់ក្រលៀនពណ៌បៃតង ដែលជាសញ្ញាងាយស្រួលពិនិត្យបន្ទាប់មកគេវះ ដើម្បីរកក្លិនមុនគេ នៅផ្នែកខាងក្នុងនៃសាច់ភ្លៅជាបន្តទៀត នៅលើមុខដំបៅមានហូរឈាមជាពិសេសនៅខាងមុខ និងក្រោមស្មារ ឧស្ម័នស្អុយចូលនៅក្នុងជាលិការសន្ធានឮសូរប្រោក ពេលគេធូតរឺកាត់ និងកាំបិត។

**គ.សំរេច ៖** រឹបអូសវត្ថុធាតុដែលស្អុយរលួយយ៉ាងតឹងរឹងបំផុត ព្រោះខ្លាចក្រែងសាច់នោះវាបណ្តាលអោយពុល។ ចំពោះគ្រឿងក្នុងត្រូវរឹបអូសទាំងអស់។ ចំពោះផ្ទាំងសាច់កាត់ចោលកន្លែងណាដែលស្អុយរលួយ។

**៥.១០ សាច់ខ្វះគុណភាព ៖** សាច់ខ្វះគុណភាពគឺជាសាច់ដែលខ្វះសារជាតិរួមមាន ៖

- សាច់កូនរឺសាច់បានមកពីកូនមិនទាន់កើត រឺកើតមកងាប់ វិធានការត្រូវរឹបអូសទាំងអស់
- សាច់ក្មេងពេក ៖ គឺជាសាច់បានមកពីសត្វ ដែលពិឃាដក្នុងអាយុក្មេងពេក រឺមុនអាយុកំណត់ សាច់សត្វក្មេងពេកដែលការលូតលាស់មិនទាន់គ្រប់គ្រាន់ត្រូវចាត់ទុកថា ជាសាច់មិនស្អាតសំរាប់ការបរិភោគ។

**៥.១១ សាច់គ្រុន ៖** គឺជាសាច់បានមកពីសត្វនៅពេលកំពុងមានជម្ងឺ វិធានការអនុវត្តន៍មាន ៖

- ពេលដឹងជាក់ច្បាស់ថា (ជាសាច់គ្រុនត្រូវតែរឹបអូសទាំងអស់)
- ក្នុងករណីសង្ស័យត្រូវភ្ជួរផ្ទាំងសាច់ទុកក្នុងរយៈពេល ២៤ ម៉ោង។

**៥.១២ សាច់បាក់កំលាំង ៖** គឺជាសាច់បានមកពីសត្វដែលបំពេញពលកម្មខ្លាំងពេកហើយមានរយៈពេលយូរទៀតផង ចំណុច៣ដែលទាក់ទាញអារម្មណ៍ចំពោះការពិនិត្យមាន ៖

- ទិដ្ឋភាពទូទៅសាច់មានពណ៌ក្រហមឆេះ ដួនកាលទៅជាពណ៌ត្នោត
- ឆ្អឹងមានពណ៌ខ្មៅពិសេស
- ជាលិការខ្លាញ់ "ខាងក្នុង និងខាងក្រៅ "ជាំឈាមពណ៌ផ្កាឈូក និងមានសរសៃឈាមពណ៌ខ្មៅ។

**សំរេច ៖** សាច់សត្វបាក់កំលាំងអាចចាត់ទុកថាជាសាច់ពុល និងចាត់ទុកថា ជាសាច់មិនស្អាតសំរាប់ការបរិភោគ។

# ជំពូកទី៦ ការពិនិត្យសាច់មាន់.ទា ស៊ុត និងត្រី

## ១.ការពិនិត្យសាច់មាន់.ទា

ការពិនិត្យសាច់មាន់ និងទា ដំបូងពិនិត្យទៅលើផ្នែកទ្រូង ផ្នែកខាងក្រោយ (ម្ពុំគូថ) ផ្នែកកនៅត្រង់មុខរបួសនៃការចាក់ក គល់ស្លាប និងនៅត្រង់ផ្នែកភ្លៅ។ ការរើបអូសសំខាន់ចំពោះសាច់មាន់ និងទា គឺការស្អុយរលួយ។ នៅពេលសាកសពដែលមិនទាន់បោចរោមនៅឡើយនោះ គឺយើងត្រូវយកដៃទៅវែកស្លាបមើលស្លាប។ បើសិនយើងពិនិត្យឃើញផ្នែកទ្រូងឡើងហើម ហើយការដកស្លាបមានភាពងាយពេកនោះ និងស្បែកផុយ ទាំងនេះ គឺបណ្តាលមកពីសាច់មានភាពហើមយ៉ាងខ្លាំង។

ចំពោះសត្វដែលបានបោចស្លាបរួចហើយការពិនិត្យមើលមានភាពងាយស្រួលជាងសត្វមិនទាន់បោចស្លាបរួច ហើយពិនិត្យមើលផ្នែកទ្រូង ដោយវែកដៃចំពោះសត្វដែលយកគ្រឿងក្នុងចេញរួចហើយការពិនិត្យ នេះសំខាន់យើងត្រូវមើលសភាពសាច់ និងការធំក្លិនផ្សេងៗ។

បើសាច់សត្វឡើងហើមនោះ ស្បែកឡើងស្លាំង ហើយមានធំខ្លិនមិនល្អ ទៀតដូចជាធំខ្លិនឈ្មួលនៃស៊ុល ភ្ជរី ។

## ២.ការពិនិត្យស៊ុត

ជាទូទៅគេពិនិត្យឃើញថា ការលក់ដូរនៅតាមទីផ្សារសព្វថ្ងៃនេះភាគច្រើន គឺស៊ុតមាន់ និងទា នៅពេលយើងគោះស៊ុតដាក់ទៅលើចាន ឃើញថា ផ្នែកលឿងនៅមូល ចំពោះផ្នែកសនៅស្អិតល្អ ហើយរុំពទ្ធ័នៅជុំវិញផ្នែកលឿងយ៉ាងជិតស្និតល្អ បើសិនជាស៊ុតណាមានសភាពយូរ ហើយយើងឃើញមានផ្នែកសរលាយ មិនស្អិត ហើយចំណែកផ្នែកលឿងវិញ រលាយរៀបទៅនឹងបាតចាន។ ចំពោះការពិនិត្យចង់ដឹងមានពីយ៉ាងគឺ ៖

**២.១ ស៊ុតកកូន ៖** ចំពោះស៊ុតកកូនមិនបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីដល់ការបរិភោគឡើយ ប៉ុន្តែស៊ុតដែលកកូន (មានអំប្រីយ៉ុងចាប់ពីអាយុ៦ថ្ងៃឡើទៅ) សភាពទាំងនេះ គឺជាការមួយមិនសមរម្យលើការលក់ដូរ និងការធ្វើពានិជ្ជកម្មឡើយ។

**២.២ ស៊ុតស្អុយរលួយ ៖** ស៊ុតដែលស្អុយរលួយ (បណ្តាលមកពីបែក និងចូលខ្យល់) ចំពោះស៊ុតនេះ កាលណាយើងគោះវាឱ្យបែកវា និងបណ្តាលឱ្យមានក្លិនមិនល្អ ដូច្នេះមិនអនុញ្ញាតឱ្យបរិភោគ និងមិនអនុញ្ញាតឱ្យយកទៅលក់ដូរឡើយ។ ក្នុងករណីនេះ បើចង់ពិនិត្យឱ្យបានច្បាស់លាស់គេត្រូវឆ្លុះមើលកាលណាស៊ុតមានកកូនគេឃើញមានចំនុចខ្មៅប៉ុនគ្រាប់ពោត និងមានសរសៃឈាមឆ្មារៗនៅជុំវិញចំណុចខ្មៅនោះ រីឯស៊ុតស្អុយគេឃើញចំណុចខ្មៅជាសពាសពេញនៅក្នុងស៊ុតនោះ។

ការបាន់ស្មានកំរិតអាយុនៃស៊ុត គឺផ្នែកខ្លុបខ្យល់មាន ៖

- ខ្លុបខ្យល់ ២មម ស៊ុតថ្មី
- ខ្លុបខ្យល់ ១០ មម រយៈពេល ៨ ថ្ងៃ
- ខ្លុបខ្យល់ ១៨ មម រយៈពេល ១៥ ថ្ងៃ

របៀបម្យ៉ាងទៀតដែលបញ្ជាក់ថាស៊ុតថ្មី ស៊ុតយូរ ស៊ុតចាស់ គេយកទៅដាក់ក្នុងធុងដែលមាន

ល្បាយអំបិល១២% គឺថាស៊ុតថ្មីលិចទៅបាតក្រោម ស៊ុតចាស់អណ្តែតមកលើផ្ទៃទឹក។

## ៣.ការពិនិត្យត្រី

**៣.១ សភាពត្រីស្រស់ ៖** ត្រីស្រស់មានសភាពដូចតទៅ ៖

- មិនមានក្លិនអាក្រក់ទេ
- ទិដ្ឋភាពភ្លឺផ្លេក
- ទោះត្រីស្លាប់ហើយក៏សាច់មិនជ្រាយដែរ
- ស្រកានៅភ្លឺល្អហើយជាប់យ៉ាងមាំទៅ និងស្បែក
- សភាពភ្នែកនៅភ្លឺថ្លាល្អ
- ស្រកីមានពណ៌ក្រហមរឺផ្កាឈូក នៅមានក្លិនល្អនៅឡើយ

**៣.២ ការពិនិត្យរួមមាន ៖**

- ក្លិន
- ភ្នែក
- ស្រកី
- សភាពទូទៅស្រស់រឺបាក់សាច់

**៣.៣ សភាពត្រីបាក់សាច់មានដូចតទៅ ៖**

- ក្លិន ៖ ក្លិនធ្លាប់ធ្លួលយ៉ាងខ្លាំងជាពិសេសនៅលើស្រកី មាត់ ផ្នែកពោះ
- ភ្នែក ៖ ចាប់ផ្តើមពីស្រអាប់ភ្នែកឡើងល្អក់ ហើយចូលជ្រៅទៅក្នុងផ្នែកនៃក្បាល ពណ៌ស្រអាប់រឺ ប្រផេះ
- ស្រកី ៖ ស្រកីឡើងស្ងួតពណ៌ស្លាំង ខ្មៅជាំ និងមានក្លិនធ្លាបទៀតផង

**៣.៤ សភាពទូទៅ**

- សាច់ជ្រាយហើមបើកាលណាគេយកម្រាមដៃទៅចុចឃើញថាឡើងស្ពោត។
- ចំពោះត្រីមានសភាពដូចខាងលើនេះត្រូវហាមឃាត់ និងរឹបអូសទាំងស្រុង។

# ជំពូកទី៧ ការពិនិត្យស្បែក និងផលិតផលសាច់កែច្នៃ

## ១.ការពិនិត្យស្បែក និងការរៀបចំទុកដាក់ស្បែក

ការពិនិតស្បែក គឺដើម្បីស្វែងរកស្បែកដែលមានគុណភាព និងការយល់ដឹងអំពីការរៀបចំទុកដាក់ស្បែកឱ្យបានល្អ។

**១.១ ការពិនិត្យស្បែក ៖** ស្បែកដែលមានប្រភពចេញពីតំបន់ត្រូពិចមិនសូវល្អដូចជា៖

- ការបោះត្រាក្ដៅនៅលើស្បែកត្រង់កន្ទៀតភ្លម ខ្នង និងត្រង់ឆ្អឹងជំនី
- ច្រើនមានកន្ទួលផ្សេងៗ ដូចជាបណ្ដាលមកពីស្លាកស្នាមសត្វល្អិតទិចរីខាំ
- ការពិឃាដនៅកន្លែងមិនស្អាតបណ្ដាលឱ្យក្រខ្វក់ដោយមានដីលាយជាមួយឈាម
- ស្លាកស្នាមបណ្ដាលមកពីមុតរបួសដោយធ្នូត ដំបៅដោយសារបន្លា និងវត្ថុមុតស្រួចផ្សេងៗ
- មិនបានលាងសំអាតឱ្យបានត្រឹមត្រូវ
- ដោយសារការហាលដោយកំដៅព្រះអាទិត្យខ្លាំងពេកធ្វើឱ្យស្បែកផ្នែកមានរោមដែលហាលផ្ទាល់នឹងដីបណ្ដាលឱ្យកន្លែងដែលនៅសើមដក់ដីឡើងក្រាំង។

ចំហាយកំដៅដែលក្ដៅនោះ ធ្វើឱ្យស្បែកដែលក្រាស់មានការឡើងមេ នៅផ្នែកខាងក្នុងធ្វើឱ្យស្បែកឡើងប៉ោងខាងក្នុង ហើយចំពោះស្បែកស្ដើងមានសភាពចង់ឆ្អិន ដែលជាហេតុធ្វើឱ្យរោមអាចជ្រុះយ៉ាងងាយបំផុត។ ចំពោះស្បែកមិនទាន់ស្ងួតធ្វើឱ្យមានភាពរលួយបណ្ដាលឱ្យស្បែកមានប្រហោងដោយអន្លើៗ កាលណាយើងហាលយូរថ្ងៃពេកធ្វើឱ្យស្បែកខ្លោចហើយស្រួយ។

**១.២ ការរៀបចំទុកដាក់ស្បែក ៖** ចំពោះការបត់ដោយសង្កត់ខ្លាំងពេកធ្វើឱ្យស្បែករហែកត្រង់កន្លែងយើងបោះត្រាក្ដៅ ក្រោយពីរយើងសំលាប់ស្បែកនោះហើយមក។ ការបញ្ចូលទុកដាក់ វេចខ្ចប់ខ្លាំងពេកមិនបានត្រឹមត្រូវ រឺមិនបានល្អបណ្ដាលឱ្យខូចគុណភាព ហេតុដូច្នេះហើយបើចង់ឱ្យស្បែកមានគុណភាពល្អត្រូវអនុវត្តតាមបទបញ្ជារ និងវិធានការដូចតទៅ ៖

- ការប្រឡាក់ស្បែកឱ្យបានល្អ
- ការបោះត្រាក្ដៅធ្វើនៅលើគោក្របី លើចំណុចតែមួយគត់ គឺនៅលើក្បាល (គឺត្រង់ថ្ពាល់រឺកំភ្លៀង) រឺនៅលើភ្លៅផ្នែកខាងក្នុង។
- ការពិឃាដត្រូវតែអនុវត្តនៅទីកន្លែងណាដែលស្អាតល្អ កន្លែងនោះត្រូវចាក់ស៊ីម៉ងត៍ រឺតែប្រសើរ ធ្វើយ៉ាងនេះមានភាពងាយស្រួលក្នុងការលាងសំអាតនៅពេលពិឃាដកុំផ្ដួលសត្វខ្លាំងពេក ដែលជាហេតុនាំឱ្យមានរបួស និងមានស្លាកស្នាមមិនល្អនៅលើស្បែក។

ការប្រឡាក់ស្បែក រឺការបកស្បែកគេត្រូវសន្ទឹងស្បែកដូចខាងក្រោម ៖

**ក.គេដាក់សត្វផ្ងារ ៖** គេសន្ទឹងជើងទាំង ៤ រួចគេវះស្បែកជាបន្ទាត់ត្រង់ចាប់ពីចង្កាមកទល់ត្រង់គល់កន្ទុយ ឱ្យចំត្រង់ក្រសាលគូថ រួចគេវះស្បែកជើងមុខ និងជើងក្រោយបន្ទាប់មកទើបគេកាត់ត្រឹមកជើង។ ចំពោះការវះកាត់ទាំងនោះត្រូវប្រើ និងកាំបិតមុតដើម្បីធ្វើឱ្យស្នាមវះបានត្រង់ និងឱ្យបានច្បាស់លាស់ត្រឹមត្រូវជៀសវាងការវះកាត់ក្រចេតក្រចត។ ចំពោះទីសត្តឃាដធំៗគេបកស្បែកដោយម៉ាស៊ីន។

ចំពោះសត្វទំពារអៀងតូចតាចវិញគេប្រើកាំបិតរួចគោះ និងញញួរបន្តិចម្តងៗហើយទើបគេពន្លាត់តែមង្គ ម្យ៉ាងទៀតគេបញ្ចូលខ្យល់ហើយវះពន្លាត់ស្បែកក៏បាន ។

- ការជៀរខ្លាញ់ និងសាច់ជាប់ស្បែកចេញក្រោយពីពន្លាត់រួចគេសំអាតស្បែកក្រៅចេញកុំឱ្យជាប់ដីហើយជៀរខ្លាញ់ និងយកសាច់ជាប់ស្បែកឱ្យអស់។
- ការកាត់របស់មិនសំខាន់ចេញដូចជា ស្បែកដោះ ស្បែកកជើង និងកាត់ស្បែកជង្គង់ចេញ
- ត្រូវលាងទឹកខាងក្នុងនៃស្បែកដើម្បីកុំឱ្យមានប្រឡាក់ ឈាម លាមក ដី...។ល។
- ក្រោយពីសំអាតត្រូវព្យួរឱ្យស្រស់ទឹក។

**ខ.ការរៀបចំទុកដាក់ស្បែកឱ្យបានល្អ ៖** គេអាចហាលស្បែកឱ្យបានស្ងួត រឺប្រឡាក់ទុក (អំបិល) ត្រូវបាញ់ថ្នាំកុំឱ្យសត្វល្អិតស៊ីដែលនាំឱ្យស្រទាប់ស្បែកខាងក្រៅខូចខាត រឺអាចមានដង្កូវ និងសត្វល្អិតផ្សេងៗវាបំផ្លាញ ។

**គ.ការហាល ៖** ការហាលត្រូវធ្វើជាបន្ទាន់នៅក្រោយពេលពន្លាត់រួច កាលហាលសំងួតដោយកំដៅព្រះអាទិត្យត្រូវហាមដាច់ខាត (មិនជាការល្អទេ) ដែលអាចធ្វើឱ្យស្បែកជ្រីញជ្រួញ ស្បែកបាក់។ ការហាលត្រូវធ្វើនៅក្នុងម្លប់(នៅក្នុងរោងរឺក្រោមដើមឈើដែលមានខ្យល់អាកាសចេញចូលបានល្អ) ស្បែកចៀម និងពពែត្រូវព្យួរលាតសន្ធឹង។ ចំណែកស្បែកគោក្របី ត្រូវពាក់លើឈើរឺឬស្សីដែលមានកំពស់ ១,៥០ម ពីដី ហើយបែរទៅរកចលនាខ្យល់ដើម្បីឱ្យឆាប់ស្ងួត និងស្រស់ទឹក ចំណែកនៅខាងចុងទាំងអស់ត្រូវចងខ្សែរទាញសន្ធឹងឱ្យបានតឹង។

**ឃ.ការប្រឡាក់អំបិល ៖** ការប្រឡាក់ត្រូវធ្វើចំពោះតែស្បែកណានៅថ្មី រឺនៅស្រស់នៅឡើយ គេប្រើអំបិលដោយលាយជាមួយ ណាផហតាលិនេ គេសន្ធឹងស្បែកដោយឱ្យផ្នែកខាងរោមនៅជាប់នឹងដីហើយគេយកអំបិលទៅពោយឱ្យសព្វក្នុងកំរិត ១/៣ នៃទម្ងន់ស្បែក។

ឧទាហរណ៍ ៖ ស្បែកទម្ងន់៩០គីឡូក្រាម គេប្រើអំបិល ៣០គីឡូក្រាម ក្រោយមកគេផ្អាប់ ៥-៦ ថ្ងៃហើយទើបគេសំរកទឹកចេញ (ទឹកនោះមានលាយឈាមតិចៗផង) ការធ្វើរបៀបនេះគេហៅថា ការប្រឡាក់ស្បែកគោស្រស់។

ង.**ការបាញ់ថ្នាំកុំឱ្យសត្វស៊ី ៖** ដើម្បីទុកដាក់ស្បែកឱ្យបានល្អ និងបានយូរក្រោយពីសំងួតមកនោះគេត្រូវប្រើថ្នាំគីមីដើម្បីកុំឱ្យសត្វល្អិតស៊ីឬបំផ្លាញដូច្នេះគេត្រូវប្រើ

| | |
|---|---|
| - H.C.H ( Hex Chlorocyclo Hexane ) | 600g |
| - Acid Boricua | 400g |
| - Tale | 9g |

## ២.ការត្រួតពិនិត្យផលិតផលកែច្នៃ

ជាទូទៅការពិនិត្យផលិតផលកែច្នៃ គឺដើម្បីការពារនូវការលក់ដូរផលិតផលណា ដែលហួសកំណត់ រឺយៈពេលប្រើប្រាស់ និងភាពមិនប្រក្រតីនៃការវេចខ្ចប់ហើយ នឹងការទុកដាក់របស់អ្នកលក់។

## ២.១ ការពិនិត្យផលិតផលកែច្នៃដាក់ក្នុងប្រអប់ឬកំប៉ុង

**ក.ការពិនិត្យប្រអប់ឬកំប៉ុងច្រេះស៊ី ៖** គឺច្រើនតែប្រអប់ឬកំប៉ុងណាដែលទុកដាក់នៅកន្លែងសើម ចំពោះប្រអប់ឬកំប៉ុងច្រេះស៊ី វាធ្វើឱ្យខូចផលិតផលនៅក្នុងនោះដូចនេះ ត្រូវហាមឃាត់ដាត់ខាត មិនឱ្យយកទៅបរិភោគ។

**ខ.ការពិនិត្យប្រអប់ឬកំប៉ុងពៀចប៉ច ៖** គឺបណ្តាលមកពីការប៉ះទង្គិចយ៉ាងខ្លាំងក្នុងការលើកដាក់ដោយគ្មានការប្រុងប្រយ័ត្នភាគច្រើនមានពៀចប៉ចនៅលើមុខដំណរីតាមគំរបប្រអប់ឬកំប៉ុង។

**គ.ការពិនិត្យប្រអប់ឬកំប៉ុងប៉ោង ៖** ភាគច្រើន គឺប៉ោងនៅគំរបប្រអប់ឬកំប៉ុង ចំពោះប្រអប់ឬកំប៉ុងណាប៉ោងក្នុងកំរិតស្រាលរឺប៉ោងបន្តិចបន្តួចវាមិនបណ្តាលឱ្យខូចនូវគុណភាពផលិតផលនោះទេ។

**ឃ.ការពិនិត្យប្រអប់ឬកំប៉ុងផ្លុះធ្លាយ ៖** គឺប្រអប់ឬកំប៉ុងណាដែលមានគំរបផ្លុះធ្លាយ រឺតួប្រអប់ឬកំប៉ុងផ្លុះធ្លាយដូចនេះ កាលណាគេសង្កត់ខ្លាំងធ្វើឱ្យប្រអប់ឬកំប៉ុងបែកផ្លុះ និងខូចខាត។ ប្រអប់ឬកំប៉ុងប៉ោងទាំងនេះ បើសិនជាយើងសង្កត់វា និងបែកធ្លាយយើងឃើញមានឧស្ម័នដែលបណ្តាលមកពី ងរមេ មិចរៀប ដែលវាស៊ីផលិតផលនៅក្នុងនោះ។ ចំពោះប្រអប់ឬកំប៉ុងប៉ោងទាំងនោះបើយើងចោះវាៗ និងផ្ទុះយ៉ាងខ្លាំងហើយមានក្លិនអាក្រក់ទៀតផង ផលិតផលនៅក្នុងប្រអប់ឬកំប៉ុងរលួយស្អុយមានពណ៌ក្រម៉ៅ រឺប្រែផះ ផលិតផលទាំងនេះមិនអាចយកមកបរិភោគបានឡើយ ម៉្យាងទៀតវាបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកហូបចុក ដូច្នេះត្រូវរឹបអូសទាំងអស់ និងត្រូវកំទេចចោលដោយចោះម្តងមួយៗហើយយកកប់ចោលឱ្យជ្រៅនៅក្នុងរណ្តៅ។

## ២.២ការពិនិត្យសាច់ឆ្អើរ សាច់ងៀត សាច់ក្រក

ផលិតផលណាដែលជូរ ផ្អូម រលួយ ត្រូវតែរឹបអូស និងកំទេចចោលជាដាច់ខាត ផលិតផលទាំងនោះ វាមានសារជាតុខាប់អន្ទិលនៅរុំព័ទ្ធជុំវិញ ទន់ជ្រាយ មានពណ៌ប្រផះហើយធំក្លិនមិនល្អ។ ការចាប់អារម្មណ៍ក្នុងការពិនិត្យសាច់ឆ្អើរ ត្រូវយកចិត្តទុកដាក់ពិនិត្យនៅសាច់ដុំហ៊ុំព័ទ្ធនៅជុំវិញឆ្អឹង។

# ជំពូកទី៨ មូលហេតុនៃការរឹបអូសសាច់

## ១.និយមន័យ

ការរឹបអូស គឺជាវិធានការមួយ សម្រាប់វិនិច្ឆ័យទៅលើម្ហូបអាហារដែលមាន គ្រោះថ្នាក់សម្រាប់ការបរិភោគ ដោយសំដៅប្រើប្រាស់នូវវិធានការរដ្ឋបាលដកហូតចេញមិនឱ្យបរិភោគ ដើម្បីជាប្រយោជន៍សាធារណៈ និងធានានូវសុខុមាលភាពរបស់ប្រជាពលរដ្ឋអ្នកបរិភោគ។ ផលិតផលមិនស្អាតល្អសម្រាប់ការបរិភោគ គឺមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈឬជួនកាល គ្មានគ្រោះថ្នាក់ដល់អ្នកបរិភោគមែន ប៉ុន្តែសមាសភាពគីមីដែលមានតំលៃជីវជាតិ គឺសឹងតែគ្មានសោះ។

**១.១ របៀបរឹបអូស ៖** ការអនុវត្តនៃការរឹបអូសរួមមាន ៖

**ក.ការប្រកាសសំរេចការរឹបអូស ៖** របៀបប្រកាសនៃការរឹបអូសមាន ៖

- ត្រូវប្រកាសការរឹបអូសនៅចំពោះមុខម្ចាស់ផលិតផល ឬក៏តំណាង
- ត្រូវប្រកាសការរឹបអូសដោយបញ្ជាក់ច្បាស់លាស់នូវផលិតផលរឹបអូស សរីរាង្គ ចំណែកនៃផ្ទាំងសាច់ ប្រអប់កំប៉ុង
- ត្រូវបញ្ជាក់ពីមូលហេតុគ្រប់គ្រាន់ត្រឹមត្រូវដើម្បីឱ្យម្ចាស់ទំនិញបានយល់ដឹង។
- ការរឹបអូសមិនអាចប្រែប្រួលបានឬមិនអាចយកវិញបាន អាស្រ័យហេតុនេះ ភ្នាក់ងារត្រួតពិនិត្យត្រូវអនុវត្តអោយបានហ្មត់ចត់ និងមិនត្រូវមើលស្រាលលើកិច្ចការនេះ ហើយត្រូវរិះគិតពិចារណាឱ្យបានត្រឹមត្រូវ។

**ខ.ការដកហូតផលិតផលរឹបអូស ៖** ការដកហូតផលិតផលរឹមអូស គឺមាន២ករណី សម្រាប់សាច់ពិឃាដសម្រាប់លក់៖

- ការរឹបអូសជាចំណែក ៖ គឺសំដៅទៅលើចំណែកណាមួយនៃផ្ទាំងសាច់ ឬនៅលើគ្រឿងបន្ទាប់បន្សំណាមួយ ឬទាំងអស់ ឬទៅលើសំណល់។
- ការរឹបអូសទាំងស្រុង ៖ គឺសំដៅទៅលើផ្ទាំងសាច់ទាំង៤ចំណែក និងគ្រឿងបន្ទាប់បន្សំ។

**គ.ការបំប្លែង និងការបំផ្លាញផលិតផលរឹបអូស ៖** ផលិតផលរឹបអូស ត្រូវតែដកហូតពីម្ចាស់ទំនិញឱ្យបានឆាប់រហ័ស ហើយបំប្លែងឱ្យបានឆាប់បំផុត។ ការបំប្លែងមានគោលបំណងធ្វើឱ្យផលិតផលក្លាយទៅជារបស់គួរឱ្យខ្ពើមរអើម ជាហេតុធ្វើឱ្យអ្នកបរិភោគ លែងបរិភោគនូវផលិតផលទាំងនោះ។

ចំពោះសាច់និយាយរួម គឺផលិតផលសត្វស្លាបឬផលិតផលសមុទ្រ ការបំប្លែងឬបំផ្លាញអាចអនុវត្តន៍ដូចតទៅ ដោយចាក់ប្រេងកាត ទឹកក្រេស៊ីល (លាយទឹក៥%) ប្រេងម៉ាស៊ីនដែលគេបង្ហូរចេញពីម៉ាស៊ីន ឬដោយលាយចាក់ខ្សាច់ពីលើ។ ក្រោយពីការបំប្លែង គេត្រូវយកផលិតផលដែលរឹបអូសទៅកប់ក្នុងដី។ ករណីសត្វកើតជំងឺឈាមខ្មៅត្រូវកប់ទៅក្នុងរណ្តៅដែលមានជំរៅយ៉ាងតិចបំផុត១,៥ ម៉ែត្រ ហើយរោយកំបោរពីលើ។ នៅទីសត្តឃាតទំនើប គេត្រូវដុតសាច់ដែលរឹបអូសនៅចង្រ្កាន ឬឡដោយប្រើឧស្ម័ន ឬម៉ាហ្សុត ដោយជៀសវាងការបញ្ចេញក្លិនអាក្រក់។ ចំពោះម្ហូបកំប៉ុងរឹបអូស គេត្រូវចាក់រំលាយ ហើយយកទៅកប់ក្នុងរណ្តៅ។

## ២.ការបែងចែកនៃការរឹបអូសសាច់

គេបែងចែកការរឹបអូសសាច់ជាពីរប្រភេទគឺ

**ក.ការរឹបអូសបណ្ដាប្រភេទសាច់ទី១**

- សាច់សត្វងាប់
- សាច់សត្វងាប់ដោយគ្រោះថ្នាក់
- សាច់សត្វមានកើតជំងឺឆ្លងរាតត្បាត
- សាច់សត្វកើតជំងឺរបេង

**ខ.ការរឹបអូសបណ្ដាប្រភេទសាច់ទី២**

- សាច់ស្អុយរលួយ ពុល មានបារ៉ាស៊ីត
- សាច់ខ្វះគុណភាព ៖ សាច់កកឈាម សាច់ជាំឈាម បាក់កំលាំងគ្រុន សាច់កើតជំងឺរាំរ៉ៃ( សត្វហើម )មានបារ៉ាស៊ីត សត្វស្គមពេក សាច់គួរអោយខ្ពើមរអើម។ មូលហេតុច្បាស់លាស់ជាក់ស្ដែងនៃការរឹបអូសប្រភេទសាច់ ដែលមានចែងក្នុងច្បាប។

## ៣.ការពិនិត្យបណ្ដាប្រភេទសាច់ទី ១

**៣.១ សាច់សត្វងាប់ ៖** គឺជាសាច់បានមកពីសត្វងាប់មុន ឬនៅពេលពិឃាតសាច់សត្វងាប់នូវជំងឺណាមួយ ដែលមិនអាចលក់ដូរ ឬហូបបាន។

- រោគសញ្ញា៖ ផ្អែកទៅលើការពិនិត្យមុនពេលពីឃាដ គេត្រូវឃ្លាំមើលជាអចិន្ត្រៃយ៍ជាប់រហូត តើគេសំគាល់សាច់យ៉ាងដូចម្ដេចខ្លះ ?
- ពិនិត្យពីចំងាយ ៖ ទិដ្ឋភាពអាក្រក់ ស្រក់ឈាម ផ្ទាំងសាច់រធេញរធូញ ពណ៌ក្រហមក្រម៉ៅ មានចេញឈាមក្រោមស្បែក (ដោយសរសៃឈាមតូចៗមានចេញឈាម)។
- **សំរេច ៖** រឹបអូសចាំបាច់។
  - ករណីមានសញ្ញាជាក់ស្ដែង ត្រូវរឹបអូសភ្លាមៗ
  - ករណីសង្ស័យ៖ ព្យួរទុកក្នុងរយៈពេលពី១២-២៤ម៉ោង សាច់សត្វងាប់ធាប់ស្អុយរលួយ។

**៣.២ សាច់សត្វងាប់ដោយគ្រោះថ្នាក់ ៖** គឺជាសាច់ ដែលបានមកពីការវះកាត់សត្វទទួលគ្រោះថ្នាក់ ឬងាប់មុនការជួយអន្តរាគមន៍របស់មនុស្ស។ គ្រោះថ្នាក់ដោយមានដំណើរចុកចាប់បណ្ដាលមកពីមុខរបួសយ៉ាងខ្លាំងក្លា ឬបណ្ដាលមកពីដប់ដង្ហើមដោយលង់ទឹកឬដោយប៉ះទង្គិចឬមានហូរ និងធ្លាក់ឈាមខាងក្នុងនៅពេលធ្វើអន្តរាគមន៍វះកាត់ សាច់ទាំងនេះអាចហូបបានលុះត្រាតែគ្រោះថ្នាក់នេះ មិនទាក់ទងទៅនឹងជំងឺ និងការសំរក់ឈាមឬការពន្លាត់ស្បែកត្រូវធ្វើភ្លាមៗបន្ទាប់ពីសត្វងាប់។

- ❖ **លក្ខណៈត្រួតពិនិត្យ ៖** គេត្រូវស្រាវជ្រាវរកបើសិនជាមានសភាពជំងឺកើតមុនគ្រោះថ្នាក់
- ជានានូវការសំរក់ឈាមឬការបង្ហូរឈាមឱ្យបានអស់បើមិនដូច្នេះត្រូវរឹបអូសទាំងអស់
- ទាមទារវះយកគ្រឿងក្នុងចេញឱ្យបានឆាប់រហ័សបើមិនដូច្នេះទេគឺត្រូវរឹបអូសទាំងអស់
- បើសិនគ្មានស្លាកស្នាមអ្វីទេត្រូវព្យួរទុក២៤ម៉ោង ធ្វើការពិនិត្យបាក់តេរីសាស្ត្រសាច់ជុំ។

**៣.៣ សាច់កើតជំងឺឆ្លង ៖** គឺជាសាច់សត្វកើតជំងឺឆ្លងដូចជា ៖ ប៉េស្ត បូសខ្យល់ កញ្ជ្រិល ជំងឺឆ្កួត ដែលងាប់មុន ឬនៅពេលពិឃាដហើយនោះ មិនមែនជាសាច់ល្អសម្រាប់ហូបទេ។

**៣.៤ សាច់សត្វកើតជំងឺរបេង ៖** គឺជាជំងឺឆ្លងទាំងសត្វស្រុក និងមនុស្សគ្រប់ប្រភេទ ដែលបណ្តាលមកពីមេរោគ យំចៀបាចតរមុិ។

## ៤.ការពិនិត្យបណ្តាប្រភេទសាច់ទី ២

**៤.១ សាច់មានបរាសិត ៖** គឺជាសាច់បានមកពីសត្វ មានបរាសិតនៅក្នុងខ្លួនរបស់វា។ ការចាំបាច់ក្នុងការធ្វើរោគវិនិច្ឆ័យនៃជំងឺឆ្លងបរាសិត គឺយើងត្រូវដឹងឱ្យច្បាស់នូវប្រភេទ បរាសិតនីមួយៗ ដែលបណ្តាលអោយឆ្លងទៅមនុស្ស។

**៤.២ សាច់គួរអោយខ្ពើមរអើម ៖** គឺជាសាច់ដែលបណ្តាលមកពីពណ៌ និងក្លិនរបស់វាមិនធម្មតា ដូចជា ដុំពក សាច់ពណ៌លឿង សាច់ពណ៌បៃតង សាច់ពណ៌ខ្មៅ (គឺបណ្តាលមកពីជាតិ ផឹងមនេតមលោមិនេ ) សាច់មានពន្លឺផ្លេកៗ គឺបណ្តាលមកពីមេរោគ ពាចចិលលុស លុមិនៀចិស។

**៤.៣ សាច់ធុំក្លិន ៖** គេអាចចែកក្លិនដូចជា ក្លិនបីរ អាសេតូន ក្លិនលាមក ក្លិនថ្នាំ ភេទ។

**៤.៤ សាច់ស្អុយរលួយ ៖** សាច់ដែលស្អុយរលួយខ្លាំង ត្រូវតែរឹបអូសទាំងអស់។
ការស្អុយរលួយមានលក្ខណៈពីរយ៉ាងគឺ

- ការស្អុយរលួយគ្រឿងក្នុង ៖ ដូចជាសួតជាំខ្មៅមានពណ៌បៃតង ថ្លើមខ្មៅស្វិតហើយស្រួយ ផាលផុយហើមព្រួកៗ តំរងនោមឡើងពណ៌បៃតង ពោះវៀនពណ៌ត្នោត ឬបៃតងក្រម៉ៅ ចំពោះខួរឡើងបែកពពុះ មានពណ៌ប្រផេះ។
- ការស្អុយរលួយផ្ទាំងសាច់ ៖ យើងស្រាវជ្រាវរកកន្លែងស្អុយរលួយ ជាដំបូងនៅត្រង់ក្រលៀន ពណ៌បៃតង ដែលជាសញ្ញាងាយឱ្យពិនិត្យ និងធ្វើការវះកាត់។ ចំពោះឧស្ម័នស្អុយរលួយឆ្លងចូល ទៅក្នុងជាលិកាសន្ទានពេលនោះបើសិនជាយើងធូតឬកាត់នឹងកាំបិតលឺសូរប្រោកៗ។

❖ **សំរេច ៖** ត្រូវរឹបអូសនូវវត្ថុដែលស្អុយរលួយយ៉ាងតឹងរឹង ដើម្បីយកទៅបំផ្លាញចោលប៉ុន្តែចំពោះផ្ទាំងសាច់ គេច្រើនតែកាត់ចោលកន្លែងដែលស្អុយរលួយ។

**៤.៥ សាច់ខ្វះគុណភាព ៖** គឺជាសាច់ដែលខ្វះសារជាតិដូចជា ៖

- សាច់កូនគោ ដែលបានមកពីកូនមិនទាន់កើត ឬកើតមកងាប់
- សាច់ក្មេងពេក ឬជាសាច់ដែលបានមកពីសត្វដែលត្រូវពិឃាដមិនទាន់គ្រប់អាយុកំណត់
- សាច់សត្វគ្រុន ៖ គឺសាច់សត្វមានជំងឺ ដែលពិឃាត។

**៤.៦ សាច់កំពុងមានជំងឺ** បើដឹងថាសាច់គ្រុន ត្រូវរឹបអូសទាំងអស់ ករណីសង្ស័យត្រូវព្យួរសាច់ទុករយៈពេល១២ - ២៤ ម៉ោង ពេលនោះលក្ខណៈពិសេស នឹងលេចចេញ។

# ជំពូកទី៩ សាច់មានសារៈសំខាន់សំរាប់ធ្វើចំណី

## ១.សេចក្តីផ្តើម

សាច់ គឺជាផលិតផលដ៏មានតំលៃរបស់ម្ហូបអាហារនៃមនុស្ស។ នុតរិតិនៀ នៅក្នុងសាច់មាន គ្រប់សារធាតុចិញ្ចឹមចាំបាច់ ដែលសរីរាង្គរបស់មនុស្សត្រូវការ។ សាច់ គឺជាផ្នែកទាំងអស់របស់ផ្ទាំងសាច់ លើកលែងតែរោមឬស្បែក ក្បាល និងសរីរៈខាងក្នុង។ សាច់ គឺជាបណ្តុំនៃជាលិកាសមាស (ចៀមផៀនុដ តិសសុ ចៀមផលខេ) ដែលរួមមានជាលិកាសាច់ដុំ (មុសចុលារ តិសសុ) ខ្លាញ់ (ថាត) ឆ្អឹង (បៀនេ) បំពង់សរសៃឈាម (បលៀដៀ វសេសលេ) បំពង់ លយមផហាតិច វសេសលេ និងសរសៃប្រសាទ(នរវេ)។ ផ្នែកដែលមានតំលៃសំខាន់បំផុតរបស់សាច់ គឺជាលិកា សាច់ដុំ។ ដូចនេះសាច់មានសមាសភាពជាច្រើនដូចជា ៖

- សមាសធាតុសរីរាង្គ (រៀងានិច ចៀមផៀនុដ )
- អាស៊ីតខ្លាញ់ (ថាតតយ ចាជិ )
- អ៊ីត្រាតកាបូ (ចារបៀហយដរាតេ )
- ប្រូតេអ៊ីន (ផរៀតេនិ )
- អំបិលរ៉ែ (មិនរោល សាលត )
- អំបិលសរីរាង្គ (រៀងានិច សាលត )
- អង់ស៊ីម (នេបយមេ )
- អ័រម៉ូន (រៀៈមៀនេ )
- ទឹក ( ៈ៧០ ) វៀផហៀលៀងយ ថៀ មតោ

## ២.សមាសធាតុក្នុងសាច់សាច់

នៅក្នុងសាច់ គឺមានជាលិកាសំខាន់ៗដូចតទៅ ៖

- ជាលិកាសាច់ដុំ (មុសចុលារ តិសសុ ) ៥០ - ៦៥ %
- ជាលិកាសន្ទាន (ចៀននចេតិវេ តិសសុ ) ១០ - ១៦ %
- ជាលិកាខ្លាញ់ (ដាធិសៀ តិសសុ ) ៥ - ៣០ %
- ជាលិកាឆ្អឹង (សៀសៀសុ តិសសុ ) ៥ - ៣២ %

តាមការសិក្សាបានបង្ហាញឱ្យដឹងថា សមាមាត្រនៃជាលិការបស់សាច់ គឺវាអាស្រ័យទៅ នឹងប្រភេទសត្វ (សផចេិសេ ) ភេទ (សខេ ) ពូជ (បរេដេ ) អាយុ (ងា )...។

**២.១ ជាលិកាសាច់ដុំ** (មុសចុលារ តិសសុ) ៖ ជាលិការសាច់ដុំ គឺជាផ្នែកដ៏សំខាន់របស់សត្វ វាមានតំលៃអាហារូបត្ថម្ភយ៉ាងខ្ពស់នៅក្នុងម្ហូបអាហាររបស់មនុស្ស។ **ខែ**ផ្ទាំងសាច់របស់ពូជគោយក សាច់ មានជាលិកាសាច់ដុំច្រើនជាងពូជគោ ផ្សេងៗទៀត។ ធាតុដ៏សំខាន់របស់ជាលិកាសាច់ដុំ គឺផ្សំ ឡើងពី មុសចុលារ ញិលាមនេតនៃសាច់ដុំ ដែលបានបង្កើតឡើងនូវសាច់ដុំ (មុសចលេ)។ នៅពេល

មានជីវិត សាច់ដុំរបស់សត្វដែលធ្វើការតិច ដូចជា ៖ សាច់ដុំចង្កេះ (លុមបា មុសចលេ) សាច់ដុំចំឡ្បក (លៀនិ មុសចលេ)។ ហេតុដូចនេះ នាំអោយសាច់ដុំទាំងនេះវាងាយក្នុងការចំអិន (សាច់ផុយល្អ ) តែចំពោះសាច់ដុំដែលនៅផ្នែកពោះ ភ្លៅ កដែលធ្វើការជាចាំបាច់ គឺពិបាកក្នុងការចំអិន (ស្វិត )។

**២.២ ជាលិកាសន្ទាន** ៖ បរិមាណរបស់ជាលិកានេះ នៅក្នុងសាច់ដុំវាសមាមាត្រទៅនឹងប្រភេទ អាយុ និងភាពជាត់។ នៅក្នុងសាច់សត្វចាស់ ជាលិកាសន្ទានមានច្រើនជាងសត្វដែលមានវ័យក្មេង។

**២.៣ ជាលិកាខ្លាញ់** ៖ បរិមាណរបស់ជាលិកាខ្លាញ់ដែលមាននៅក្នុងសាច់ គឺវាសមាមាត្រទៅនឹងប្រភេទសត្វ អាយុ និង fatness។

២.៤ ជាលិកាឆ្អឹង ៖ ទំងន់ទូទៅរបស់ឆ្អឹង ដែលគេគិតជាមធ្យមប្រហែលពី ៥ - ៣២%។

- ចំពោះផ្ទាំងសាច់គោ ឆ្អឹងមានប្រហែល ២០%។
- ចំពោះចៀម ឆ្អឹងមានប្រហែល ៨ - ១៧%។
- ចំពោះជ្រូក ឆ្អឹងមានប្រហែល ៥ - ៩%។

# ជំពូកទី១០ វិធីរក្សាសាច់ Meat Preserving Method

## ១.សេចក្តីផ្តើម

គោលបំណងជាសារវន្តក្នុងការរក្សាទុកសាច់ឱ្យបានយូរ គឺការបង្កើនរយៈពេលនៃការរក្ស ទុកសាច់ (meat storing) និងអាចទប់ស្កាត់ការបន្តពូជរបស់ microorganism បាននៅក្នុងសាច់ ដោយមានអនាម័យ បច្ចុប្បន្ននេះគេអនុវត្តនូវរបៀបបីសំខាន់ៗក្នុងការរក្សាសាច់ ៖

## ២.ការថែរក្សាផលិតផលតាមរបៀបសីតុណ្ហភាព

គេអនុវត្តវិធីនេះដើម្បីបន្ថយនូវចលនាគីមីជីវៈនៅក្នុងសាច់ ទប់ស្កាត់ការកើតមីក្រូប និងបរាសិត ហើយវិធីនេះ រក្សានូវទំរង់ខាងក្រៅរបស់សាច់ និងរស់ជាតិ។

**២.១ ការរក្សាសាច់នៅក្រោមសីតុណ្ហភាពទាប ៖** (Meat storing under low temperature) : គេអនុវត្តន៍វិធីនេះ គឺដើម្បីបន្ថយនូវចលនការគីមីរបស់សាច់ (biochemical process) និងទប់ស្កាត់នៃការកើត microorganism។ វិធីនេះរក្សាបាននូវទំរង់ខាងក្រៅ របស់សាច់ រសជាតិ...។ ការរក្សាសាច់នៅក្រោមសីតុណ្ហភាពទាបនេះ គេអនុវត្តតាមពីររបៀបគឺ ៖

**ក.cooling meat** (ធ្វើឱ្យត្រជាក់សាច់) ចំណុចសំខាន់នៃការធ្វើឱ្យត្រជាក់សាច់ គឺផ្ទាំងសាច់ដែលគេដាក់នៅក្នុងបន្ទប់ក្លាស្សេបាត់បង់នូវកំដៅរបស់វា ហើយបន្ទាប់មកសាច់ចុះត្រជាក់រហូតដល់ សីតុណ្ហភាពបរិយាកាស (environment temperature) ១៦អង្សាសេ។ ជាលទ្ធផលរបស់វិធីនេះ គឺនៅលើផ្ទៃរបស់សាច់មានកើតលើងនូវក្រម៉(crust)។ ហើយដែលអាចការពារនូវការជ្រៀតចូលរបស់ពួកមីក្រូសារពាង្គកាយ។

**ខ.ការធ្វើសាច់ឱ្យកក ឬបង្កក (freezing meat)** ៖ គឺជាការធ្វើសាច់ឱ្យកកក្រោមឥទ្ធិពលនៃសីតុណ្ហភាពដ៏ទាប ហើយទឹកដែលនៅក្នុងសាច់ក្លាយជាទឹកកកជាលទ្ធផល គឺពពួកមីក្រូសារពាង្គកាយមិនអាចជ្រៀតចូលបានក្នុងសាច់ ឯពពួកបរាសិតមួយចំនួនអាចស្លាប់។ ការធ្វើសាច់សត្វស្លាប់ឱ្យត្រជាក់ បង្កក ជំរើស ការវេចខ្ចប់ និងការដឹកជញ្ជូនសាច់ត្រូវរក្សាទុកក្នុងបន្ទប់ត្រជាក់ក្នុងសីតុណ្ហភាពពី ០-១ អង្សាសេ ដែលមានសំណើមប្រហែល៩៥% សីតុណ្ហភាពនៃសាច់ទ្រូងមិនលើសពី២៥ អង្សាសេកំណត់ថាសាច់ត្រជាក់ តែសីតុណ្ហភាព០-៤ អង្សាសេកំណត់ថាត្រជាក់កករឹង។ ដើម្បីបង្កកយើងត្រូវប្រើរយៈពេល២៤ម៉ោង។ សាច់ត្រជាក់រឺបង្កកទាក់ទង ទៅនឹងភាពធំធាត់និងគុណភាពរបស់សាច់ដែលយើងបែងចែកជាប្រភេទទី១ និងទី២។ យើងបោះត្រាលើ សាច់ប្រភេទទី១ ដោយពណ៌ កូលាបនៅជើងសត្វ និងប្រភេទទី២ ពណ៌បៃតងនៅជើង បន្ទាប់មកយើងត្រូវថ្លឹង សាច់សត្វនិងវេចខ្ចប់រួចដាក់ក្នុងឡាំង។ ក្នុងករណីចាំបាច់ដែលយើងត្រូវរក្សាសាច់ឱ្យលើសពី៥ថ្ងៃយើងត្រូវបង្កកវានៅក្នុងកន្លែងត្រជាក់នៃទូទឹកកកក្នុងសីតុណ្ហភាព-៦អង្សាសេ។ សាច់ដែលដាក់ក្នុងឡាំង ហើយត្រូវថែរក្សាក្នុងកន្លែងស្តុកត្រូវមានសីតុណ្ហភាព១០អង្សាសេ និងសំណើម៨៥-៩០%។ ចំណែកឡាំងដែល យើងដាក់សាច់តាម

ប្រភេទនិមួយៗត្រូវបិទផ្លាកសញ្ញាប្លាស្ទិចដែលមាន បញ្ជាក់ប្រភេទសត្វ និងប្រភេទសាច់ ទំងន់ពិតនិងការបរិច្ឆេទផលិត។ ចំណែកដឹកជញ្ជូននាំផលិតផលនោះ ក៏ត្រូវធ្វើឡើងតាមក្បួនអនាម័យបសុពេទ្យ ដោយគិតគូរសីតុណ្ហភាព រយៈពេលដឹកជញ្ជូន ក្រៅពីនេះត្រូវគិតគូរដល់រយៈពេលសំលាប់សត្វផងដែរ ហាមឃាត់ដឹកសាច់ជាមួយវត្ថុធាតុដើមផ្សេងៗ រឺជាមួយសត្វរស់ដែល ធ្វើអោយខូចគុណភាពសាច់។ សាច់បង្កកដឹកតាមរថភ្លើងមិនត្រូវមានសីតុណ្ហភាពលើសពី-៦អង្សារសេទេ ឯសាច់ត្រជាក់ក្នុងសីតុណ្ហភាពពី០-៤អង្សារសេ បើដឹកតាមឡានត្រូវមានសីតុណ្ហភាព-១០-៦អង្សារសេ ក្នុងសីតុណ្ហភាពបរិយាកាសខាងក្រៅ៣០អង្សារសេ។ ការរៀបចំសាច់ ជារចាសសេ នៅក្នុងបន្ទប់ត្រជាក់សីតុណ្ហភាពនៃសាច់ជារចាសសេ ជាភាពអនុគ្រោះដល់ការរាលដាលយ៉ាងឆាប់រហ័សនៃពពួកមីក្រុប ការធ្វើឱ្យសាច់ត្រជាក់គឺជាការទប់ស្កាត់ការលូតលាស់នៃពពួកមីក្រុប តែមិនអាចសំលាប់ពួកវាបានទេ ភាពត្រជាក់មិនមែនជាវិធីសំលាប់មេរោគទេ ផ្ទុយទៅវិញការបង្កកសាច់អាចសំលាប់ពពួកបរាសិតមួយចំនួនខ្លះតែប៉ុណ្ណោះ។

**ខ.១ តារាងនៃការធ្វើសាច់ឱ្យត្រជាក់យឺត**

- សីតុណ្ហភាព ២ទៅ៤ អង្សារសេ
- សំណើម ៨០%
- ល្បឿនខ្យល់ ០,២ទៅ៤ ម៉ែត្រក្នុង១ វិនាទី
- ការបាត់បង់ទំងន់ ៥%
- រយៈពេល ៣៦ទៅ៧២ ម៉ោង

**ខ.២ តារាងធ្វើសាច់ឱ្យត្រជាក់លឿន**

- សីតុណ្ហភាព - ៨ ទៅ - ១ អង្សារសេ
- សំណើម ៩០ % ទៅ ៩៥ %
- ល្បឿនខ្យល់ ០.៥ ទៅ ៣ ម៉ែត្រក្នុង ១ វិនាទី
- ការបាត់បង់ទំងន់ ១,៣ ទៅ ១,៨ %
- រយៈពេល ២ ទៅ ៣ ម៉ោង

**ខ.៣ តារាងកន្លែងបង្កកសាច់ ០ អង្សារសេ**

- សីតុណ្ហភាព - ៣៦ទៅ-៤០ អង្សារសេ
- សំណើម ៩៥ % ទៅ១០០ %
- ល្បឿនខ្យល់ ៣ទៅ៦ ម៉ែត្រក្នុង វិនាទី
- ការបាត់បង់ទំងន់ ១ - ៣ %
- រយៈពេល ៣ ថ្ងៃ

**ខ.៤ តារាងកន្លែងស្តុកសាច់អោយត្រជាក់**

- សីតុណ្ហភាព ០ ទៅ ១ អង្សារសេ
- សំណើម ៨៥ % ទៅ ៩០ %

- ល្បឿនខ្យល់ ០,២ ម៉ែត្រ/១វិនាទី
- ការបាត់បង់ទំងន់ ៥ %
- រយៈពេល ២-៣ អាទិត្យ

**ខ.៥ តារាងកន្លែងស្តុកសាច់ធ្វើអោយកក**

- សីតុណ្ហភាព - ១៨ អង្សារសេ
- សំណើម ៩០ %
- ល្បឿនខ្យល់ ច្រើនដងក្នុងមួយម៉ោង
- ការបាត់បង់ទំងន់ ១ - ៣ %
- រយៈពេល ៦ ខែ

**២.២ ការរក្សាសាច់នៅក្រោមសីតុណ្ហភាពខ្ពស់ ៖** (Meat storing under high tempera ture) : ជាវិធីមួយក្នុងចំនោមវិធីទាំងឡាយនៃការថែរក្សាសាច់ក្នុងការបំរើផលិតកម្មសាច់កំប៉ុងដែលគេចាំបាច់ត្រូវប្រើសីតុណ្ហភាព១២០ទៅ១៣០អង្សារសេក្នុងរយៈពេលជាច្រើននាទី។ ក្រោមឥទ្ធិពលនៃវិធីនេះ គេអាចដាក់សាច់ក្នុងកំប៉ុងធ្វើពីលោហៈដែលមានគំរបបិទយ៉ាងជិត។ គោលបំណងនៃវិធីនេះ គឺដើម្បីសំលាប់មេរោគ និងចំអិនសាច់ដាក់កំប៉ុងដែលគេអាចរក្សាទុកក្នុងបន្ទប់ពិសេសមួយក្នុងរយៈពេលបានជាង២ឆ្នាំ។

## ៣. ការថែរក្សាតាមរបៀបគីមី Chemical method imstoring meat

ការថែរក្សាសាចើតាមរបៀបគីមី គឺជាវិធីបុរាណមួយក្នុងការរក្សាសាច់ដោយប្រើអំបិល ដើម្បីប្រលាក់សាច់គេប្រើអំបិលសូដ្យូមក្លរួ (អំបិលយើងហូប) ក្នុងការប្រលាក់នេះ មានវិធីពីរយ៉ាង ៖

**៣.១ប្រលាក់ដោយប្រើអំបិលស្ងួត ៖** គេដាក់សាច់ក្នុងចានបន្ទាប់មកដាក់អំបិលឱ្យបាន១០% នៃទំងន់សាច់ហើយយើងចាប់ច្របាច់សាច់ និងអំបិលដើម្បីឱ្យបានស្មើសាច់គ្នា។

**៣.២ វិធីប្រលាក់ដោយប្រើទឹកអំបិល ៖** ដាក់សាច់ក្នុងចានហើយចាក់សូលុយស្យុងទឹកអំបិលចូលទៅក្នុងចានសាច់ដោយដាក់ត្រាំវា ទឹកអំបិលនេះប្រើបានតែម្តងទេ។

**៤.Physical method :**

**ក.sublimate drying** (វិធីរំហួតដោយចំហុយ)ចំណុចសំខាន់របស់វិធីនេះ គឺសាច់គេដាក់ហាលក្នុងបន្ទប់គ្មានខ្យល់(សុញ្ញាកាស)។ សាច់នេះអាចរក្សាបានជាច្រើនឆ្នាំនៅក្រោមសីតុណ្ហភាពរបស់បន្ទប់។

**ខ.ultraviolet irradiation** (វិធីបាញ់កាំរស្មី) ៖ វិធីនេះ សាច់ទទួលរងនូវកាំរស្មី ultraviolet ហើយសាច់អាចរក្សាបានរយៈពេលជាច្រើនឆ្នាំ។

**គ.ionizing irradiation** (វិធីបាញ់អ៊ីយ៉ុង) ៖ គឺជាការបាញ់អ៊ីយ៉ុងរបស់អង្គធាតុវិទ្យុសកម្ម ក្នុងកំរិតកំណត់មួយទៅលើសាច់។ ពេលនោះសាច់អាចរក្សាបានជាច្រើនឆ្នាំ។

# ជំពូកទី១១ កំរិតគុណភាពរបស់សាច់សត្វ

Determination of Animal Meat

## ១.សេចក្តីផ្តើម

ការកំណត់សាច់របស់សត្វ គឺផ្អែកទៅលើការកំណត់ពិនិត្យ ៖

1.condition of cutting place

2.degree of draining of blood from carcass

3.presence of hypostasis

4.reaction on perosidase

## ២.condition of cutting place

ចំពោះសាច់សត្វដែលមានសុខភាពល្អកន្លែងកាត់មិនរាបស្មើឡើយ គឺរធេញរធូញ (rough)។ ចំពោះសាច់សត្វមានជំងឺ ឬសាច់សត្វដែលខ្វះគុណភាពវិញ កន្លែងដែលកាត់គឺរាបស្មើ(wen) ឈាមនឹងងាយរលាយចូលគ្នាជាមួយទឹក(blood easily mix water)។

## ៣.degree of draining of blood from carcass

ចំពោះសាច់សត្វកើតជំងឺ កំរិតនៃការបង្ហូរឈាមមិនបានល្អ បំពង់បង្ហូរ (**សរសៃឈាម**) តែងតែមានឈាម និងគេតែងតែឃើញឈាមនៅលើស្រោមសួត។ តែចំពោះសាច់សត្វជ្រូក គេសង្កេតនៅលើផ្ទាំងសាច់ដែលពេលនោះផ្ទាំងសាច់មានពណ៌ក្រហមជាំ។ ចំពោះសាច់របស់សត្វដែលមានសុខភាពល្អ គឺការបង្ហូរឈាមចេញពីផ្ទាំងសាច់បានល្អ ហើយសាច់មានពណ៌ផ្កាឈូក (pink or rose colour) ឬក្រហមភ្លឺ (light red) ហើយនិងនៅក្នុងសរសៃឈាមគ្មានឈាមកកឡើយ។

## ៤.presence of hypostasis

គឺជាការប្រមូលផ្តុំឈាមនៅផ្នែកខាងក្រោមនៃសរីរៈរបស់សរីរាង្គនីមួយៗ ចំពោះផលិតផលសាច់សត្វ ដែលបានមកពីសត្វដែលមានសុខភាពល្អ (គ្មាន hypostasis) ហើយ hypostasis នេះវាមានតែចំពោះសាច់មានជំងឺ។

## ៥.reaction on perosidase

គឺជាអង់ស៊ីមមួយដែលជួយផ្តាច់យកអាតូម $O_2$ពី$H_2O_2$ (អ៊ីដ្រូសែនពីរុកស៊ីត Hydrogen peroxide)។ ដើម្បីអនុវត្តវិធីនេះគេត្រូវមាន indicator bensidine ។

ចំណាំ ៖ ប្រសិនបើនៅក្នុងសាច់មាន perosidase គឺ indicator ប្រែពណ៌ តែបើនៅក្នុងសាច់គ្មាន perosidase វិញ indicator មិនប្រែពណ៌ឡើយ។

technic in determination គេចាក់សារធាតុ extract ចំនួន3ml ចូលទៅក្នុងបំពង់ test (test tube)បន្ទាប់មកគេបន្តក់ bensidine ចំនួន៥តំណក់ និង១%នៃសូលុយស្យុង $H_2O_2$ ចំនួន២

តំណក់។ ចំពោះ extract ដែលបានមកពីសត្វមានសុខភាពល្អ គឺ indicator អោយពណ៌បៃតងខៀវ (blue green) ដែលប៉ុន្មាន

នាទីក្រោយមកក្លាយទៅជាពណ៌ត្នោត (brown)។

ចំពោះ extract ដែលបានមកពីសត្វឈឺ indicator មិនអោយពណ៌ឡើយ។ ដូច្នេះចំពោះសាច់ដែលបានមកពីសត្វឈឺ គ្មាន enzyme perosidase ឡើយ។

Ex: គេយកសាច់សត្វចំនួន 1g បន្ទាប់មកគេចាក់ទឹកសុទ្ធចំនួន 40ml ហើយទុកក្នុងរយៈពេល15mn។ បន្ទាប់មកគេយកវាទៅច្រោះ ហើយសារធាតុដែលបានមកពីការច្រោះនោះ ហៅថា extract ។

# ជំពូកទី១២ ច្បាប់ស្តីពី សុខភាពសត្វ និងផលិតកម្មសត្វ
## (ជំពូកទី ៤ ជំងឺសត្វ)

## ១.ផ្នែកទី ១ ជំងឺវិញ្ញត្តិ និងការទប់ស្កាត់

### ១.១ មាត្រា ៩

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិចេញសេចក្តីប្រកាសជំងឺសត្វណាមួយ ជាជំងឺវិញ្ញត្តិ តាមសំណើររបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវរក្សាបញ្ជីឈ្មោះជំងឺវិញ្ញត្តិដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

### ១.២ មាត្រា ១០

ប្រជាពលរដ្ឋគ្រប់រូបដែលបានដឹង បានឃើញ ឬសង្ស័យថាសត្វបានឆ្លងជំងឺ ឈឺ ឬស្លាប់ដោយជំងឺវិញ្ញត្តិ ឬជំងឺផ្សេងទៀត មានករណីយកិច្ចផ្តល់ព័ត៌មានដល់ភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត។

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់សត្វ ដែលបានដឹង បានឃើញ ឬសង្ស័យថាសត្វបានឆ្លងជំងឺ ឈឺឬស្លាប់ដោយសារជំងឺវិញ្ញត្តិ ឬជំងឺផ្សេងទៀត មានកាតព្វកិច្ចផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីមានសមត្ថកិច្ច ឬអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលក្នុងមូលដ្ឋានសាមី។

### ១.៣ មាត្រា ១១

សត្វដែលបានឆ្លងជំងឺវិញ្ញត្តិ ត្រូវបានហាមឃាត់ការលក់ដូរ ការលែងចោល ការធ្វើចរាចរណ៍ ការបោះបង់ចោល ការពិឃាតដើម្បីយកផលិតផលធ្វើជាអាហារលក់ដូរ កែច្នៃ ឬចែកចាយដល់សាធារណៈជន។ ករណីសត្វឬផលិតផលសត្វដែលសង្ស័យថាបានឆ្លងជំងឺវិញ្ញត្តិ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល អាចអនុញ្ញាតឲ្យធ្វើចរាចរណ៍បានក្នុងគោលបំណងទប់ស្កាត់ និងលុបបំបាត់ការរីករាលដាលនៃជំងឺសត្វ តាមគោលការណ៍ណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដោយអនុលោមតាមវិធានការបសុព្យាបាល។

### ១.៤ មាត្រា ១២

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវសម្រេចលើវិធានការអនាម័យដើម្បីបង្ការ ការឆ្លងរាលដាលជំងឺវិញ្ញត្តិដូចខាងក្រោម៖

- ហាមឃាត់ ឬដាក់កំហិតលើការធ្វើចរាចរណ៍សត្វ ផលិតផលសត្វ ឧបករណ៍ សម្ភារបរិក្ខារ ឬមធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ ដែលអាចជាប្រភពចម្លងមេរោគមកក្នុង ឬទៅក្រៅទីកន្លែងចិញ្ចឹម ឬទីកន្លែងប្រមូលផ្តុំសត្វដទៃទៀត។
- ចាត់វិធានការអនាម័យនៅទីកន្លែងចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ឧបករណ៍ សម្ភារ ឬមធ្យោបាយដឹក

ជញ្ជូនសត្វ និងផលិតផលសត្វ និងទីកន្លែងផ្សេងទៀតដែលសត្វ និងផលិតផលសត្វឬទំនិញអាចបង្កហានិភ័យនៃការឆ្លងរាលដាលជំងឺវិញ្ញត្តិ។

### ១.៥ មាត្រា ១៣

ផ្អែកលើសំណើរប់សអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺវិញ្ញត្តិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសដូចខាងក្រោម៖

- ការកំណត់កន្លែងឆ្លងជំងឺសត្វ
- ការកំណត់តំបន់ឆ្លងជំងឺសត្វ
- ការកំណត់តំបន់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ជាតំបន់ត្រួតពិនិត្យ ឬតំបន់ទប់ស្កាត់ជំងឺ
- ការកំណត់តំបន់ណាមួយ ឬទីតាំងជីវសុវត្ថិភាពណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាតំបន់គ្មានជំងឺ។

### ១.៦ មាត្រា ១៤

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវចាត់វិធានការអនាម័យនៅតាមកន្លែងឆ្លងជំងឺ និងតំបន់ទប់ស្កាត់ជំងឺ ដើម្បីបង្ការ និងការឆ្លងរាលដាលជំងឺវិញ្ញត្តិ ដូចខាងក្រោម៖

- ដាក់កំហិតលើការចរាចរណ៍សត្វ ផលិតផលសត្វ ឧបករណ៍ សម្ភារប្រើប្រាស់ និងមធ្យោបាយដឹកជញ្ជូនពាក់ព័ន្ធដែលអាចធ្វើឲ្យជំងឺឆ្លងរាលដាល។
- ហាមឃាត់នូវរបៀបផ្តល់ចំណី និងទឹកដល់សត្វដែលអាចឲ្យជំងឺឆ្លងរាលដាល។
- ដាក់ឲ្យនៅដាច់ដោយឡែក សង្កេត បំបែក ឬធ្វើចត្តាឡីស័កសត្វឆ្លងជំងឺ ឬតំបន់ត្រួតពិនិត្យជំងឺ
- អង្កេតអេពីដេមីសាស្ត្រ
- អនុវត្តយន្តការសម្រាប់អត្តសញ្ញាណកម្មសត្វនៅក្នុងតំបន់ឆ្លងជំងឺ ឬតំបន់ត្រួតពិនិត្យជំងឺ
- អនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មសត្វ
- យកទៅធ្វើតេស្តវត្ថុវិភាគពីសត្វ ផលិតផលសត្វ ឧបករណ៍ ឬសម្ភារប្រើប្រាស់ពាក់ព័ន្ធដទៃទៀតដែលអាចចម្លងជំងឺ។
- បង្ការជំងឺសត្វ និងការព្យាបាលសត្វ
- សម្អាត និងសម្លាប់មេរោគនៅតាមទីកន្លែងសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ឧបករណ៍ សម្ភារ និងមធ្យោបាយដឹកជញ្ជូន
- កម្ទេចចោលសត្វដែលឆ្លងជំងឺវិញ្ញត្តិ ឬសត្វដែលសង្ស័យមានជំងឺវិញ្ញត្តិដោយប្រើវិធីមិនឃោរឃៅ
- ឃាត់ទុក បំផ្លាញចោល ឬធ្វើប្រព្រឹត្តកម្មតាមវិធានការបសុព្យាបាលចំពោះសាកសពសត្វ ផលិតផលសត្វ ឧបករណ៍ និងសម្ភារដទៃទៀតដែឡចាត់ទុកថាបានឆ្លង ឬប៉ះពាល់មេរោគ។
- ចាត់វិធានការអនាម័យដទៃផ្សេងទៀតតាមការចាំបាច់។ វិធានការអនាមន័យត្រូវធ្វើការវិភាគរកហានិភ័យដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ត្រូវធ្វើជាលាយលក្ខន៍អក្សរ និងត្រូវបោះពុម្ព

ផ្សាយជាសាធារណៈ។ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យបាល ត្រូវជូនដល់អ្នកពាក់ព័ន្ធដើម្បីធានាតម្លាភាព។

### ១.៧ មាត្រា ១៥

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើផែនការសកម្មភាព និងផែនការត្រៀមបម្រុងសម្រាប់ទប់ស្កាត់ និងលុបបំបាត់ជំងឺវិញ្ញត្តិ ដើម្បីបង្ការការរីករាលដាលជំងឺវិញ្ញត្តិតាមសំណើអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

### ១.៨ មាត្រា ១៦

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវស្នើសុំការសហការពីស្ថាប័នសាធារណៈ ឬផ្នែកឯកជន ដើម្បីបង្ការ និងទប់ស្កាត់ជំងឺវិញ្ញត្តិក្នុងករណីចាំបាច់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវស្នើសុំសហការពីក្រសួងសុខាភិបាល ដើម្បីរៀបចំកម្មវិធីនីតិវិធី និងសេចក្តីណែនាំសម្រាប់បង្ការ និងទប់ស្កាត់ជំងឺស៊ូណូស។

## ២. ផ្នែកទី២ ភាពអាសន្ននៃជំងឺសត្វ

### ២.១ មាត្រា ១៧

ដោយមានការឯកភាពពីនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្តីពីការដាក់ភាពអាសន្ននៃជំងឺសត្វ និងចេញប្រកាសស្តីពីការរំលាយភាពអាសន្ននៃជំងឺសត្វតាមសំណើររបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

### ២.២ មាត្រា ១៨

ភាពអាសន្ននៃជំងឺសត្វ ត្រូវមានមូលនិធិសម្រាប់ដំណើរការ។ មូលនិធិសម្រាប់ភាពអាសន្ននៃជំងឺសត្វមានប្រភពមកពី៖

- ថវិកាជាតិដាក់ញ្ចប់ដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ហិរញ្ញប្បទានដែលបានមកពីដៃគូអភិវឌ្ឍ
- ប្រភពផ្សេងទៀត។

ការបង្កើតមូលនិធិសម្រាប់ភាពអាសន្ននៃជំងឺសត្វ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ៣. ជំពូកទី៨ សត្តឃាតដ្ឋាន និងអនាម័យ

### ៣.១ មាត្រា ៥០

រូបវន្តបុគ្គល នីតិបុគ្គលដែលបង្កើតសត្តឃាតដ្ឋាន ឬទីកន្លែងកែច្នៃបឋមផលិតផលសត្វត្រូវតែមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវចុះបញ្ជីសត្តឃាតដ្ឋាន និង/ឬ ទីកន្លែងកែច្នៃបឋមផលិតផលសត្វនោះ ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ។

### ៣.២ មាត្រា ៥១

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់សត្តឃាតដ្ឋាន ធ្វើអាជីវកម្មពិឃាតសត្វ ឬកាន់កាប់ទី

កន្លែងកែច្នៃបឋមផលិតផលសត្វ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដូចខាងក្រោម៖

- ត្រូវសាងសង់សត្តឃាតដ្ឋានតាមបទដ្ឋានបច្ចេកទេស
- ត្រូវមានលិខិតអនុញ្ញាត និងត្រូវអនុវត្តតាមនីតិវិធីសត្តឃាតដ្ឋាន ពិឃាតសត្វ ឬបង្កើតទីកន្លែងកែច្នៃបឋមផលិតផលសត្វ ព្រមទាំងអនុវត្តតាមលក្ខណៈវិនិច្ឆ័យសម្រាប់និយោជិត និងប្រតិបត្តិករសត្តឃាតដ្ឋាន ឬប្រតិបត្តិករទីកន្លែងកែច្នៃបឋមផលិតផលសត្វ
- ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់ប្រតិបត្តិការកែច្នៃបឋមផលិតផលសត្វ ការរក្សា ផលិតផលសត្វស្ដីពី សុខុមាលភាពសត្វ អនាម័យ និងការការពារបរិស្ថាន
- ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់ប្រតិបត្តិការកែច្នៃបឋមផលិតផលសត្វ ការរក្សាទុកប្រព្រឹត្តកម្ម ការកម្ទេចចោលកាកសំណល់ និងការចែកចាយសាច់។
- ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសផ្សេងទៀតដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.៣ មាត្រា ៥២

ការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតផលសត្វ ត្រូវកំណត់ដោយអនុក្រឹត្យ។

### ៣.៤ មាត្រា ៥៣

សាច់ ផលិតផលសត្វ ឬផលិតផលសាច់ ដែលត្រូវបានត្រួតពិនិត្យអនាម័យ ត្រូវអនុលោមតាមបមាណីយសាច់ បមាណីយអនាម័យសាច់ ផលិតផលសត្វ ឬផលិតផលសាច់ និងបមាណីយសំណល់សារជាតុគីមី ជីវសាស្ត្រ និងវត្ថុមានសារជាតុវិទ្យុសកម្មក្នុងសាច់ ផលិតផលសត្វ ឬផលិតផលសាច់ទាំងនោះ។ បមាណីយសាច់ បមាណីយអនាម័យសាច់ ផលិតផលសត្វ ឬផលិតផលសាច់ និងបមាណីយសំណល់សារជាតុគីមី ជីវសាស្ត្រ និងវត្ថុមានសារជាតុវិទ្យុសកម្មក្នុងសាច់ ផលិតផលសត្វ ឬផលិតផលសាច់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៣.៥ មាត្រា ៥៤

ចំពោះរាល់សត្វដែលនាំមកដល់សត្តឃាតដ្ឋានសម្រាប់ត្រៀមពិឃាតត្រូវ៖

- មានវិញ្ញាបនបត្របសុព្យាបាល ឯកសារបញ្ជាក់អត្តសញ្ញាណសត្វ និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលត្រូវពិនិត្យ
- រក្សាសត្វទុកនៅកន្លែងបង្ខាំងសត្វក្នុងបរិវេណសត្តឃាតដ្ឋានក្នុងរយៈពេល ១២ (ដប់ពីរ) ទៅ ២៤ (ម្ភៃបួន) ម៉ោងមុនពេលពិឃាត
- ពិនិត្យសុខភាពសត្វ។

### ៣.៦ មាត្រា ៥៥

រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលចេញពីសត្តឃាតដ្ឋានត្រូវអូសត្រា ឬបោះត្រាឬបិទស្លាកបសុព្យាបាលសម្គាល់ដោយមន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល

មានសមត្ថកិច្ចទទួលខុសត្រូវសត្តឃាតដ្ឋាន។ រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់កែច្នៃនៅទីកន្លែងកែច្នៃបឋមគ្រប់ប្រភេទ ត្រូវមានស្នាមត្រា ឬមានស្លាកបសុព្យាបាលសម្គាល់។ ការបង្កើត និងការប្រើប្រាស់ត្រា ឬស្លាកបសុព្យាបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៣.៧ មាត្រា ៥៦

រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលដាក់តាំងលក់នៅតាមកន្លែងតាំងលក់ ឬនៅទីកន្លែងកែច្នៃបឋមគ្រប់ប្រភេទត្រូវមានស្នាមត្រា ឬស្លាកបសុព្យាបាលសម្គាល់។

### ៣.៨ មាត្រា ៥៧

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសន្និធិ តាំងលក់ កែច្នៃ និងដឹកជញ្ជូនរាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដើម្បីធ្វើអាជីវកម្មត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។ បទដ្ឋានបច្ចេកទេសបសុព្យាបាលក្នុងការធ្វើសន្និធិ ការតាំងលក់ ការកែច្នៃ និងការដឹកជញ្ជូនសាច់ និងផលិតផលសត្វ ដើម្បីធ្វើអាជីវកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៤. ជំពូកទី ៩ ចរាចរណ៍សត្វ និងផលិតផលសត្វ

### ៤.១ មាត្រា ៥៨

ចរាចរណ៍សត្វ និងផលិតផលសត្វ ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិញ្ញាបនបត្របសុព្យាបាល និងការអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។ ចំពោះចរាចរណ៍សត្វ និងផលិតផលសត្វក្នុងផ្ទៃប្រទេសមិនតម្រូវឲ្យមានលិខិតអនុញ្ញាតទេ ប៉ុន្តែត្រូវមានវិញ្ញាបនបត្របសុព្យាបាល និងការអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។

### ៤.២ មាត្រា ៥៩

ការនាំចូល ការនាំចេញ និងការនាំឆ្លងកាត់សត្វ និងផលិតផលសត្វ ត្រូវឆ្លងការត្រួតពិនិត្យអនាម័យ និងវិធានការបសុព្យាបាលរបស់មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចប្រចាំការនៅកន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន ដែលកំណត់ដោយរាជរដ្ឋាភិបាល។

### ៤.៣ មាត្រា ៦០

ចំពោះការនាំចូលសត្វ ឬផលិតផលសត្វ ត្រូវមានវិញ្ញាបនបត្របសុព្យាបាល ដែលចេញដោយអាជ្ញាធរមាន សមត្ថកិច្ចរបស់ប្រទេសនាំចេញ និងគោរពតាមបទដ្ឋានបច្ចេកទេសនៃព្រះរាជាណាចក្រកម្ពុជា។

### ៤.៤ មាត្រា ៦១

ចំពោះការនាំចេញសត្វ ឬផលិតផលសត្វ ត្រូវមានវិញ្ញាបនបត្របសុព្យាបាល ដែលចេញដោយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវគោរពតាមបទដ្ឋានបច្ចេកទេសនៃប្រទេសនាំចូល។

### ៤.៥ មាត្រា ៦២

ចំពោះការនាំឆ្លងកាត់សត្វ ឬផលិតផលសត្វត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។

### ៤.៦ មាត្រា ៦៣

ក្នុងករណីមានហានិភ័យ រាលចរាចរណ៍សត្វ ឬផលិតផលសត្វ ត្រូវបានដាក់ និងដកកំហិត ឬត្រូវហាមឃាត់ដោយផ្អែកលើមូលដ្ឋាននៃការវិភាគហានិភ័យ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការជូនដំណឹងអំពីការដាក់ និងដកកំហិត ឬការហាមឃាត់ខាងលើនេះ។

### ៤.៧ មាត្រា ៦៤

នីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះផលិផលស៊ុត និងផលិតផលទឹកដោះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ៥. ជំពូកទី១០ ស្ថានីយចត្តាឡីស័ក និងផលិតផលសត្វ

### ៥.១ មាត្រា ៦៥

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់ទីតាំងសម្រាប់បង្កើតស្ថានីយ៍ចត្តាឡីស័កសត្វ និងផលិតផលសត្វ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

### ៥.២ មាត្រា ៦៦

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចគ្រប់គ្រង និងផ្តល់សេវាកម្មក្នុងការអនុវត្តវិធានការបសុព្យាបាលចំពោះស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ។

### ៥.៣ មាត្រា ៦៧

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ បានតែត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវចុះបញ្ជីស្ថានីយចត្តាឡីស័កនោះ ព្រមទាំងត្រូវអនុវត្តតាមការតម្រូវបទដ្ឋានបច្ចេកទេស ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ក្រោមការត្រួតពិនិត្យរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

នីតិវិធី និងការតម្រូវបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៦.ជំពូកទី ១១ សុខុមាលភាពសត្វ

### ៦.១ មាត្រា ៦៨

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលកាន់កាប់សត្វសម្រាប់គ្រប់គោលដៅបំណងលើកលែងលក្ខណៈប្រពៃណីនិងលក្ខណៈគ្រួសារ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វដូចខាងក្រោម៖

- ការកម្រិតទម្ងន់ផ្ទុកសម្រាប់សត្វពលកម្ម និងការដឹកជញ្ជូនសត្វ
- ការពិឃាតសត្វ
- ការរៀបចំសាងសង់ទ្រុង ឬក្រោល
- ការចិញ្ចឹម និងការប្រើប្រាស់សត្វសម្រាប់មន្ទីរពិសោធន៍សត្វ សម្រាប់ពលកម្ម និងសត្វសម្រាប់គោលបំណងដ៏ទៃទៀត
- ការហាមឃាត់ការប្រើប្រាស់ឱសថសណ្តំ ឬធ្វើឲ្យសត្វសន្លប់ ឬការធ្វើទារុណកម្មផ្សេងទៀតក្នុងពេលដឹកជញ្ជូនដើម្បីធ្វើពាណិជ្ជកម្ម ឬដើម្បីធ្វើម្ហូបអាហារ។
- បទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងសុខុមាលភាពសត្វផ្សេងទៀត។

### ៦.២ មាត្រា ៦៩

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវ៖

- ជំរុញសកម្មភាពអប់រំ និងផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់អំពើទារុណលើសត្វ និងការលើកកម្ពស់ការអនុវត្តឲ្យស្របតាមបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ
- តាមដានត្រួតពិនិត្យលើការអនុវត្តបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ និងចាត់វិធានការចំពោះអំពើទារុណលើសត្វ
- សម្របសម្រួល និងចាត់ចែងដើម្បីចាប់ឃាត់ទុកសត្វ ដែលរងទារុណកម្ម ឬរងគ្រោះថ្នាក់។ ក្នុងករណីចាំបាច់ ត្រូវធ្វើការចាក់ថ្នាំការពារ ព្យាបាល ឬថែទាំរក្សាទុកសត្វ ដែលការចំណាយជាបន្ទុករបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាម្ចាស់ ឬអ្នកកាន់កាប់សត្វ។ ករណីអត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់សត្វមិនត្រូវបានស្គាល់ រាល់ការចំណាយជាបន្ទុករបស់រដ្ឋ។

## ៧.ជំពូកទី១២ ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្ម

### ៧.១ មាត្រា ៧០

ការបង្កើតទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំសត្វ និងទីកន្លែងអាជីវកម្មសត្វ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវគោរពតាមបទដ្ឋានបច្ចេកទេសដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ។ ចំពោះទីកន្លែងព្យាបាលសត្វ ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ ដែលជាសមាជិក គណៈបសុពេទ្យ។

### ៧.២ មាត្រា ៧១

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចត្រួតពិនិត្យ និងផ្តល់សេវាកម្មក្នុងការអនុវត្តវិធានការបសុព្យាបាល ចំពោះទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៧.៣ មាត្រា ៧២

នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋ

មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៨.ជំពូកទី ១៣ វិជ្ជាជីវៈបសុព្យាបាល (ផ្នែកទី ១ គណៈបសុពេទ្យ)

### ៨.១ មាត្រា ៧៣

ត្រូវបង្កើតគណៈបសុពេទ្យ ដើម្បីលើកកម្ពស់ការចូលរួមរបស់បសុពេទ្យ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈបសុព្យាបាលស្របតាមក្រមសីលធម៌វិជ្ជាជីវៈបសុព្យាបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ផ្នែកទី ២ អ្នកបច្ចេកទេសបសុពេទ្យ និងភ្នាក់ងារបសុពេទ្យ

### ៨.២ មាត្រា ៧៤

អ្នកបច្ចេកទេសបសុពេទ្យ និងភ្នាក់ងារបសុពេទ្យអាចប្រកបវិជ្ជាជីវៈបសុព្យាបាលបានលុះត្រាតែមានបសុពេទ្យម្នាក់ ដែលទទួលស្គាល់ដោយគណៈបសុពេទ្យជាអ្នកទទួលខុសត្រូវ។

## ផ្នែកទី ៣ ភ្នាក់ងារសុខភាពសត្វភូមិ

### ៨.៣ មាត្រា ៧៥

ភ្នាក់ងារសុខភាពសត្វភូមិត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាយន្តការកម្រិតមូលដ្ឋានក្នុងគោលបំណងឲ្យមានការរួមចំណែកបំពេញបន្ថែមតម្រូវការ និងការលើកកម្ពស់គុណភាពសេវាកម្មក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅមូលដ្ឋាន។

### ៨.៤ មាត្រា ៧៦

ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបានជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋានសាមីដើម្បីមកទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៨.៥ មាត្រា ៧៧

ភ្នាក់ងារសុខភាពសត្វភូមិមិនមែនជាភ្នាក់ងារក្របខ័ណ្ឌរដ្ឋទេ ប៉ុន្តែជាភ្នាក់ងារស្ម័គ្រចិត្តជំនួយបម្រើសេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ។ ភ្នាក់ងារសុខភាពសត្វភូមិ អាចប្រកបវិជ្ជាជីវៈបសុព្យាបាលបានលុះត្រាតែមានបសុពេទ្យម្នាក់ ជាអ្នកទទួលខុសត្រូវ។

### ៨.៦ មាត្រា ៧៨

ការជ្រើសរើស ការបណ្តុះបណ្តាល ការគ្រប់គ្រងឲ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៩.ជំពូកទី ១៦ ការចុះបញ្ជី

### ៩.១ មាត្រា ៨៦

រាល់ការចុះបញ្ជី ត្រូវឆ្លើយតបក្នុងរយៈពេល១ (មួយ) ខែ បន្ទាប់ពីទទួលពាក្យស្នើសុំ ដែលបានបំពេញ និងភ្ជាប់ឯកសារគ្រប់គ្រាន់នៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

### ៩.២ មាត្រា ៨៧

នីតិវិធីនៃការចុះបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១០.ជំពូកទី ១៧ ភារកិច្ចអ្នកកាន់លិខិតអនុញ្ញាត

### ១០.១ មាត្រា ៨៨

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្ម ឬធ្វើសេវាកម្មគ្រប់រូបភាពដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ មានកាតព្វកិច្ចដូចខាងក្រោមៈ

- ត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រសម្រាប់ប្រតិបត្តិការដែលពាក់ព័ន្ធនៅក្នុងគ្រឹះស្ថាន ឬទីកន្លែងអាជីវកម្មរបស់ខ្លួន។
- ត្រូវរាយការណ៍ ឬផ្តល់ព័ត៌មានជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចក្នុង មូលដ្ឋានសាមីអំពីគ្រោះថ្នាក់ ឬផលប៉ះពាល់ដែលបង្ករដោយសត្វ ផលិតផលសត្វ ចំណីសត្វ និងបសុឱសថ គ្រប់ប្រភេទ
- ត្រូវប្រកាសអំពីប្រភេទ យថាប្រភេទ បរិមាណសត្វ និងផលិតផលសត្វ ដែលធ្វើអាជីវកម្ម ឬធ្វើសេវាកម្ម និងបសុឱសថ ឬចំណីសត្វគ្រប់ប្រភេទដែលធ្វើអាជីវកម្ម ពាណិជ្ជកម្ម ផលិត ឬធ្វើការលាយផ្សំ និងត្រូវមានកំណត់ត្រាព័ត៌មានចុះក្នុងសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ
- ត្រូវរក្សាស្ថានភាពអនាម័យទៅទីកន្លែងផលិតកម្ម និងអាជីវកម្ម
- ត្រូវនាំសត្វមកពិនិត្យនៅតាមទីតាំងដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសត្វ និងវិញ្ញាបនបត្របសុព្យាបាល
- ក្នុងករណីដែលមិនបានបំពេញតាមតម្រូវការបេមាណីយ ឬតាមបទដ្ឋានបច្ចេកទេស ដែលបានកំណត់ ឬមានហានិភ័យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ត្រូវប្រមូលនាំយកសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វមករក្សាទុក ដើម្បីទប់ស្កាត់ហានិភ័យតាមការចាំបាច់ និងទទួលខុសត្រូវលើការចំណាយទាំងនោះ
- បំពេញកាតព្វកិច្ចផ្សេងទៀត ដែលមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវកំណត់គម្រូសៀវភៅកំណត់ត្រសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ។

### ១០.២ មាត្រា ៨៩

ការបោះពុម្ពផ្សាយឬការផ្សាយពាណិជ្ជកម្មអំពីពូជសត្វ សត្វ ផលិតផលសត្វ បសុឱសថឬចំណីសត្វ ត្រូវមានខ្លឹមសារស្របនឹងខ្លឹមសារដែលបានចុះបញ្ជី ឬស្របនឹងបច្ចេកទេសជាក់លាក់ ហើយមានសង្គតិភាពទៅនឹងទិន្នន័យព័ត៌មានបច្ចេកទេសរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

### ១០.៣ មាត្រា ៩០

គ្រឹះស្ថាននាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មីនូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំចំណីសត្វ ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ ដែលជាសមាជិកគណៈបសុពេទ្យ។ អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំលក់រាយចំណីសត្វ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំវិជ្ជាជីវៈ ដែលជាលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតស្របច្បាប់នេះ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈដល់អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំរាយបសុឱសថ ចំណីសត្វ សត្វ ផលិតផលសត្វ។

### ១០.៤ មាត្រា ៩១

បសុឱសថ ចំណីសត្វ វត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំបសុឱសថ ឬចំណីសត្វដែលអនុញ្ញាតឲ្យនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី អាចមានសុពលភាពផ្គត់ផ្គង់ ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ ដែលជាសមាជិកគណៈបសុពេទ្យ។ សម្រាប់គ្រឹះស្ថានផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថត្រូវមានបន្ថែមបសុឱសថការី ឬឱសថការីទទួលខុសត្រូវម្នាក់ ឬច្រើននាក់ដែលបានបំពេញតាមនីតិវិធីច្បាប់ជាធរមាន។

អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំលក់រាយបសុឱសថ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំវិជ្ជាជីវៈ ជាលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ។

### ១០.៥ មាត្រា ៩២

បសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមសម្រាប់ការលាយផ្សំ បសុឱសថ ឬចំណីសត្វដែលអនុញ្ញាតឲ្យនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី អាចមានសុពលភាពផ្គត់ផ្គង់ ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាតែបានធ្វើប្រតិវេទន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការត្រួតពិនិត្យដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ។

នីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ១០.៦ មាត្រា ៩៣

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ វិភាគ សាកល្បង ការទទួលស្គាល់នៅក្នុងគ្រប់សកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ឬធ្វើសេវាកម្មពាក់ព័ន្ធនឹងសត្វ និងផលិតផលបសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ មានកាតព្វកិច្ចបង់កម្រៃសេវាកម្ម។ កម្រៃសេវាកម្មតាមប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១១.ជំពូកទី ១៨ ការត្រួតពិនិត្យអនាម័យ

### ១១.១ មាត្រា ៩៤

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវធ្វើការត្រួតពិនិត្យអនាម័យដូចខាងក្រោម៖

- កន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល
- ស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ
- ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
- ទីកន្លែងព្យាបាលសត្វ ផ្សារសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ
- មធ្យោបាយដឹកជញ្ជូនសត្វ ផលិតផលសត្វ ផលិតផលសាច់ បសុឱសថ ចំណីសត្វ ឧបករណ៍ និងសម្ភារបរិក្ខារបសុព្យាបាល
- គ្រឹះស្ថានអាជីវកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម និងទីកន្លែងផ្សេងទៀតដែលរូបជាតុសេនេទិកសត្វ ចំណីសត្វ និងបសុឱសថ ត្រូវបានរក្សាទុក ឬលក់ចែកចាយ
- កន្លែងតាំងលក់ផលិតផលសត្វ និងផលិតផលសាច់ និងទីកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានហានិភ័យឬសង្ស័យមានហានិភ័យបណ្តាលមកពីការឆ្លងរាលដាលជំងឺសត្វ ដោយសហការជាមួយអង្គភាពនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ

### ១១.២ មាត្រា ៩៥

ម្ចាស់ ឬអ្នកកាន់កាប់សត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចដើម្បីសម្រួលការត្រួតពិនិត្យអនាម័យ និងការអនុវត្តវិធានការបសុព្យាបាល។

ចំណាយលើការអនុវត្តវិធានការបសុព្យាបាលដូចជា វិធានការទុកព្យបាល ចាក់ថ្នាំការពាររំងាប់មេរោគ ឃាត់ទុក ថែរក្សា ឬបំផ្លាញចោលជាដើម ជាបន្ទុករបស់ម្ចាស់ ឬអ្នកកាន់កាប់។ ក្នុងករណីមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់ការចំណាយជាបន្ទុករបស់រដ្ឋ។

### ១១.២ មាត្រា ៩៦

នីតិវិធីនៃការត្រួតពិនិត្យអនាម័យបសុព្យាបាល ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១២.ជំពូកទី ១៩ អធិការកិច្ច

### ១២.១ មាត្រា ៩៧

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់គុណវុឌ្ឍិ និងតែងតាំងមន្ត្រីអធិការកិច្ច សុខភាពសត្វ និងផលិតកម្មសត្វ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដើម្បីបំពេញភារកិច្ច និងទទួលខុសត្រូវចំពោះគ្រប់សកម្មភាពពាក់ព័ន្ធក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

ក្នុងករណីសង្ស័យមានភាពមិនប្រក្រតី ឬសង្ស័យថាមានបទល្មើសពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ សុខុមាលភាពសត្វ បសុឱសថ និងចំណីសត្វ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះនៅក្នុងដែនសមត្ថកិច្ចសាមី ដើម្បីបង្ការ ទប់ស្កាត់ លុបបំបាត់ហានិភ័យនៃជំងឺសត្វ និងបង្ក្រាបបទល្មើសទៅតាម៖

- កន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល
- ស្ថានីយចត្តាឡីស័ក និងផលិតផលសត្វ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
- ទីកន្លែងព្យាបាលសត្វ ផ្សារសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងកន្លែងតាំងលក់
- គ្រឹះស្ថានអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម ទីកន្លែងតាំងលក់ និងទីកន្លែងផ្សេងទៀតដែលរូបជាតុសេនេទិកសត្វ
- គ្រឹះស្ថានស្រាវជ្រាវ មន្ទីរពិសោធន៍ ស្ថានីយពិសោធន៍
- ទីកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានហានិភ័យ ឬសង្ស័យថាមានហានិភ័យបណ្តាលមកពីការឆ្លងរាលដាលជំងឺសត្វឬសង្ស័យថាមានបទល្មើសពាក់ព័ន្ធនៃច្បាប់នេះ

ក្នុងពេលអនុវត្តមុខការ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានភារកិច្ច និងសិទ្ធិដូចខាងក្រោម៖

- តម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងសត្វ ឬផលិតផលសត្វ ផ្តល់ព័ត៌មាន និងបង្ហាញលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធក្នុងសកម្មភាពរបស់ខ្លួន
- ដកយកសំណាក វត្ថុវិភាគរបស់សត្វ ផលិតផលសត្វ ចំណីសត្វ សារជាតុបន្ថែម បសុឱសថ ឬវត្ថុជាតុដើមនៃផលិតផលទាំងនេះ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងធ្វើការវិភាគភ្នាក់ងារចម្លងជំងឺ ឬធ្វើការវិភាគផ្ទៀងផ្ទាត់បមាណីយដើម
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារដែលពាក់ព័ន្ធ ក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រនោះ ប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាង និងកសាងសំណុំរឿងនៃបទល្មើសស្របតាមនីតិវិធី
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ

## ១២.២ មាត្រា ៩៨

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវមានលិខិតបញ្ជាបេសកកម្ម ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វត្រូវកំណត់ដោយអនុក្រឹត្យ។

## ១២.៣ មាត្រា ៩៩

មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាដល់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១២.៤ មាត្រា ១០០

មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់អង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។ ក្នុងករណីបានជួបប្រទះបទល្មើសជាក់ស្តែង មន្ត្រីនៃអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចដែលនៅជិតបំផុតដើម្បីចាត់ការតាមនីតិវិធី។ ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វនិងផលិតកម្មសត្វ ក្នុងការត្រួតពិនិត្យបទល្មើសត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ១២.៥ មាត្រា ១០១

ការកសាងសំណុំរឿងបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ គំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១២.៦ មាត្រា ១០២

នៅក្នុងដំណើរការអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងករណីមានភស្តុតាងជាក់ស្តែងបញ្ជាក់អំពីការប្រព្រឹត្តល្មើសនឹងច្បាប់នេះ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ មានសិទ្ធិតម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវលើប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងបទល្មើស ផ្អាករាល់សកម្មភាពជាបណ្តោះអាសន្ន។

## ១២.៧ មាត្រា ១០៣

បុគ្គលណាដែលមិនសុខចិត្តនឹងវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ច មានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដើម្បីដោះស្រាយ។ ក្នុងករណីមិនសុខចិត្ត បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃទទួលសេចក្តីសម្រេច។រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។ ក្នុងករណីដែលបុគ្គលនោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បុគ្គល

នោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី។

**១២.៨ មាត្រា ១០៤**

ក្នុងករណីដែលវត្ថុតាងមិនអាចរក្សាទុកបានយូរ ដែលបណ្តាលមកពីភាពស្អុយរលួយ ធ្វើឲ្យបាត់បង់បរិមាណ គុណភាព ហួសពេលកំណត់ប្រើប្រាស់ ពុកផុយ ឬចម្លងមេរោគ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វត្រូវស្នើសុំការសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោល ឬលក់វត្ថុតាងទាំងនោះតាមនីតិវិធីជាធរមាន។ ការចំណាយលើវត្ថុវិភាគនិងសេវាកម្មវិភាគ ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់នេះជាបន្ទុករបស់ម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស។ ក្នុងករណីមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើសរាល់ការចំណាយជាបន្ទុករបស់រដ្ឋ។

## ១៣.ជំពូកទី ២០ ទោសប្បញ្ញត្តិ

**១៣.១ មាត្រា ១០៥**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

**១៣.២ មាត្រា ១០៦**

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូត ឬការព្យួរវិញ្ញាបនបត្រ និងលិខិតអនុញ្ញាតគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដែលមានវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។ ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្មនិងបសុព្យាបាល។

**១៣.៣ មាត្រា ១០៧**

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងមាត្រា ១១០ មាត្រា ១១១ មាត្រា ១១២ និងមាត្រា ១១៣ នៃច្បាប់នេះ។

ការពីន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្តឹងអាជ្ញា។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវចងក្រងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី។ ក្នុងករណីមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ចដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលតាមវិធានការបសុព្យាបាល។

នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**១៣.៤ មាត្រា ១០៨**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬសាលដីការបស់តុលាការ ឬប្រាក់បានមក

ពីការលក់វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលថវិកាជាតិ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្រ្តីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយ ដែលមានចែងក្នុងច្បាប់នេះ។

### ១៣.៥ មាត្រា ១០៩

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតដែលពាក់ព័ន្ធចំពោះបុគ្គលកាន់កាប់សត្វបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- មិនជូនដំណឹងបន្ទាន់មកអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនៅពេលសង្ស័យថាមានសត្វកើតជំងឺឆ្លង ឬមានសត្វស្លាប់ដោយជំងឺវិញ្ញត្តិ។
- ពុំព្រមឆ្លើយសំណួរឬផ្តល់ឯកសារដែលតម្រូវដោយមន្រ្តីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច។
- បដិសេធ ឬមិនបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វ និងការប្រមូលវត្ថុវិភាគសម្រាប់ធ្វើការវិភាគ។
- មិនអនុវត្តវិធានការអនាម័យសត្វ និងអនាម័យផលិតផលសត្វ ដែលតម្រូវដោយបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។
- ប្រព្រឹត្តអំពើណាមួយដែលបង្កទារុណកម្ម បង្កឲ្យសត្វឈឺចាប់ ឬស្តែងចេញនូវភាពអណោចអធម្ម ផ្ទុយពីបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ។
- ចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មដោយគ្មានអត្តសញ្ញាណសម្គាល់។

### ១៣.៦ មាត្រា ១១០

ត្រូវទទួលពិន័យជាអន្តរការណ៍ជាប្រាក់ ១០០ ០០០ (មួយសែន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. មិនធ្វើអនាម័យសត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់សាច់ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ ទីកន្លែងចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយបសុឱសថ ទីកន្លែងលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយចំណីសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងស្ថានីយ៍ចត្តាឡីស័កសត្វ និងផលិតផលសត្វ។
2. មិនអនុវត្តតាមលក្ខខណ្ឌដែលភ្ជាប់កាតព្វកិច្ចក្នុងការកាន់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រទាំងឡាយ ដែលពាក់ព័ន្ធនឹងសត្វ និងផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងចំណុច ១ ដល់ចំណុច ៥ កថាខណ្ឌទី១ មាត្រា ៨៨ នៃច្បាប់នេះ។
3. មិនអនុវត្តតាមបទប្បញ្ញត្តិហាមឃាត់នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ត្រួតពិនិត្យជំងឺសត្វ ក្នុងការធ្វើចរាចរណ៍សត្វ និងផលិតផលសត្វដែលធ្វើឲ្យរាលដាលជំងឺសត្វ។
4. មិនចូលរួមអនុវត្តវិធានការបសុព្យាបាលទប់ស្កាត់ជំងឺឆ្លងសត្វ នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ទប់ស្កាត់ជំងឺសត្វ តាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម

និងបសុព្យាបាល។

5. មិនចូលរួមអនុវត្តការសម្អាត ការកម្ចាត់មេរោគចំពោះអគារ ឧបករណ៍ សម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូននៅក្នុងតំបន់ឆ្លងជំងឺតាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

## ១៣.៧ មាត្រា ១១១

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ៤ ០០០ ០០០ (បួនលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. លក់ដុំ លក់រាយ បសុឱសថ ឬចំណីសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ។
2. មិនអនុវត្តតាមកាតព្វកិច្ចអ្នកកាន់លិខិតអនុញ្ញាតដូចមានចែងក្នុងចំណុច៦ កថាខណ្ឌទី១ នៃច្បាប់នេះ។
3. គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវក្នុងគ្រឹះស្ថាននាំចូល នាំចេញ ផលិត ឬលាយផ្សំ វេចខ្ចប់ជាថ្មីនូវចំណីសត្វ ដូចមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៩០ នៃច្បាប់នេះ។
4. គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវក្នុងគ្រឹះស្ថានពាណិជ្ជកម្ម ផលិតឬលាយផ្សំ វេចខ្ចប់ជាថ្មីបសុឱសថ ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា៩១ នៃច្បាប់នេះ។
5. គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវ នៅកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មខ្នាតធំ និងខ្នាតមធ្យមដូចមានចែងក្នុងមាត្រា ២៦នៃច្បាប់នេះ។
6. គ្មានបុគ្គលិកបច្ចេកទេសបសុព្យាបាលទទួលខុសត្រូវក្នុងទីកន្លែងព្យាបាលសត្វ ដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់នេះ។
7. មិនធ្វើប្រតិវេទន៍សម្រាប់ការត្រួតពិនិត្យ ចំពោះបសុឱសថ ឬចំណីសត្វដែលនាំចូល នាំចេញ ផលិត ឬលាយផ្សំនៅមុនពេលផ្គត់ផ្គង់ចែកចាយ។
8. ធ្លាប់បានទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ១០៩ នៃច្បាប់នេះ។
9. ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ ហើយនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

## ១៣.៨ មាត្រា ១១២

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ៧ ០០០ ០០០ (ប្រាំពីរលាន) រៀល ចំពោះបុគ្គលណាដែលធ្វើពាណិជ្ជកម្ម និងអាជីវកម្ម ផលិតផលសត្វ បសុឱសថ ចំណីសត្វ ប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. បោះបង់ចោល លែងចោល ពិឃាតយកសាច់ជាអាហារ ដើម្បីយកផលិតផលធ្វើជាអាហារ លក់ដូរ ឬកែច្នៃ ឬចែកចាយដល់សាធារណជន ឬធ្វើចរាចរណ៍សត្វ ឬផលិតផលសត្វដែលមានជំងឺ ឬសង្ស័យថាឆ្លងជំងឺវិញ្ញត្តិ
2. លក់ដុំ លក់រាយនូវសាច់សត្វឬផលិតផលសត្វដែលផ្ទុកសំណល់សារធាតុគីមីលើសកម្រិតបមាណីយ

3. សាងសង់សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់សាច់ មន្ទីរព្យាបាលសត្វ ទីកន្លែងចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយបសុឱសថ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយចំណីសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងស្ថានីយ៍ចត្តាឡីស័ក និងផលិតផលសត្វខុសពីទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាត
4. ធ្វើសន្និធិឬលក់ចែកចាយសត្វឬផលិតផលសត្វដោយគ្មានត្រាឬស្លាកបសុព្យាបាលសម្គាល់
5. មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់បសុឱសថ ឬចំណីសត្វ។
6. មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា៥៧ នៃច្បាប់នេះ
7. មិនអនុវត្តតាមបទដ្ឋានបច្ចេកទេស និងវិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការនៃការផលិតឬការលាយផ្សំបសុឱសថ និងចំណីសត្វ
8. ផ្គត់ផ្គង់ ចែកចាយ ឬដឹកជញ្ជូនចល័តលក់ដោយផ្ទាល់ដល់អ្នកប្រើប្រាស់បសុឱសថ ឬចំណីសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ។
9. លក់ដុំ លក់រាយបសុឱសថ ឬចំណីសត្វខុសការកំណត់ក្នុងលិខិតអនុញ្ញាតនាំចូល។
10. ចិញ្ចឹមសត្វឬបង្កាត់ពូជសសត្វជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាត និងមិនបានចុះកសិដ្ឋានស្របតាមច្បាប់នេះ។
11. នាំចូល នាំចេញ ឬផ្គត់ផ្គង់ចែកចាយសត្វ បង្កាត់ពូជ ឬរូបធាតុសេនេទិកសត្វគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ។
12. ធ្វើពាណិជ្ជកម្មបសុឱសថ ឬចំណីសត្វ ដែលជាផលិតផលមិនអនុវត្តតាមការតម្រូវបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដែលបានកំណត់លើស្លាកសញ្ញាព័ត៌មាន។
13. ធ្វើសេវាកម្មដោយបំពេញមុខងារចាបសុពេទ្យដោយគ្មានការចុះបញ្ជី ឬគ្មានវិញ្ញាបនបត្រទទួលស្គាល់ដោយគណៈបសុពេទ្យ
14. ផ្សាយពាណិជ្ជកម្មស្តីពីបសុឱសថ ឬចំណីសត្វដោយល្មើសនឹងមាត្រា ៨៩ នៃច្បាប់នេះ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ហើយនៅតែប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ទ្វេដង។

### ១៣.៩ មាត្រា ១១៣

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន) រៀល ទៅ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល ចំពោះបុគ្គលណាដែលធ្វើពាណិជ្ជកម្ម និងអាជីវកម្មដោយប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. បង្កើតទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ និងស្ថានីយចត្តាឡីស័កសត្វ និងផលិផលសត្វគ្មានលិខិតអនុញ្ញាត ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។

2. បង្កើតសត្តឃាតដ្ឋាន ធ្វើអាជីវកម្មពិឃាតសត្វ និងបង្កើតទីកន្លែងកែច្នៃបឋមផលិតផលសត្វ គ្មានលិខិតអនុញ្ញាត ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។
3. នាំចូល នាំចេញពូជសត្វ ផលិតពូជសត្វ ឬបង្កើតពូជថ្មីនៃសត្វមិនបានចុះបញ្ជី ឬគ្មានវិញ្ញាបនបត្របញ្ជាក់ពូជសត្វ ឬពូជថ្មីនៃសត្វនោះ។
4. នាំចូល នាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិបសុឱសថ ឬចំណីសត្វដែលគ្មានវិញ្ញាបនបត្របញ្ជាក់បញ្ជិកាឬមិនបានចុះបញ្ជីជាថ្មី ឬគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ។
5. នាំចូល នាំចេញ និងចរាចរបសុឱសថ ឬចំណីសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៧ និងមាត្រា ៤៧ នៃច្បាប់នេះ។
6. នាំចូល នាំឆ្លងកាត់សត្វ ឬផលិតផលសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។
7. នាំចូល នាំចេញសត្វ ឬផលិតផលសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល។
8. នាំចូលសត្វ ឬផលិតផលសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៦០ នៃច្បាប់នេះ។
9. នាំចេញសត្វ ឬផលិតផលសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៦២ នៃច្បាប់នេះ។
10. នាំឆ្លងកាត់សត្វ និងផលិតសត្វក្នុងផ្ទៃប្រទេសដោយមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា ៥៨ នៃច្បាប់នេះ។
11. ចរាចរសត្វ ឬផលិតផលសត្វក្នុងផ្ទៃប្រទេសដោយមិនបានអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា៥៨នៃច្បាប់នេះ។
12. ធ្វើប្រតិបត្តិការមន្ទីរពិសោធន៍ ឬបង្កើតគ្រឹះស្ថានស្រាវជ្រាវឯកជនក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វដោយគ្មានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ហើយនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

### ១៣.១០ មាត្រា ១១៤

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅដល់ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. ក្លែងបន្លំស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរឬប្រើស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ចំពោះបសុឱសថ ឬចំណីសត្វ។
2. ក្លែងបន្លំសំបកវេចខ្ចប់បសុឱសថ ឬចំណីសត្វ។
3. ក្លែងបន្លំឈ្មោះទូទៅ ឬឈ្មោះពាណិជ្ជកម្មបសុឱសថ ឬចំណីសត្វ។

4. ក្លែងបន្លំអត្តសញ្ញាណសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ។
5. ក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជីបសុឱសថ ឬចំណីសត្វ
6. ក្លែងបន្លំប្រភពដើមបសុឱសថ ឬចំណីសត្វ។
7. ក្លែងបន្លំព័ត៌មានទិន្នន័យបមាណីយ និងបទដ្ឋានបច្ចេកទេសសម្រាប់ការចុះបញ្ជីបសុឱសថ ឬចំណីសត្វ។

### ១៣.១១ មាត្រា ១១៥

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ចំពោះបុគ្គលណាដែល ប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

1. ធ្វើពាណិជ្ជកម្មគ្រប់រូបភាពនូវបសុឱសថ ព្រមទាំងវត្ថុធាតុដើម សារធាតុសកម្មសម្រាប់លាយផ្សំបសុឱសថដែលហាមឃាត់ ឬស្ថិតក្នុងបញ្ជីហាមឃាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
2. ធ្វើពាណិជ្ជកម្មគ្រប់រូបភាពនូវចំណីសត្វ ព្រមទាំងវត្ថុធាតុដើម សារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំចំណីសត្វដែលហាមឃាត់ ឬស្ថិតជនៅក្នុងបញ្ជីហាមឃាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
3. ធ្វើពាណិជ្ជកម្ម ផលិត លាយផ្សំបសុឱសថឬចំណីសត្វ ដោយប្រើសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ឬប្រើផលិតផលសារពង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ។
4. ចិញ្ចឹមសត្វដោយល្មើសនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ។
5. នាំចូលដោយចេតនានូវសត្វ ឬផលិតផលសត្វដែលមានជំងឺឆ្លង ឬផ្ទុកមេរោគបង្កជំងឺ ខូចគុណភាព ឬបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ មកក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១៣.១២ មាត្រា ១១៦

ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយខាងក្រោម៖

1. ក្លែងលិខិតអនុញ្ញាត វិញ្ញាបនបត្រ លេខបញ្ជិកា ឬឯកសារបែបបទសម្រាប់គ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ ដូចមានចែងក្នុងច្បាប់នេះ
2. ក្លែងលទ្ធផលវិភាគគុណភាព និងសុវត្ថិភាពបសុឱសថ និងចំណីសត្វ ឬក្លែងលទ្ធផលសាកល្បងជីវប្រសិទ្ធភាពបសុឱសថ ឬប្រសិទ្ធភាពនៃចំណីសត្វ។
3. ក្លែងលទ្ធផលវិផាគ វត្ថុវិភាគ រោគវិនិច្ឆ័យជំងឺសត្វឬក្លែងលទ្ធផលវិភាគគុណភាព សំណល់សារធាតុគីមី និងជីវសាស្ត្រនៅក្នុងសាច់សត្វ និងផលិតផលសត្វ។
4. ក្លែងស្លាកសម្គាល់អត្តសញ្ញាណសត្វ ដែលប្រើសម្រាប់សម្គាល់សត្វ។
5. ក្លែងត្រាឬស្លាកបសុព្យាបាលដែលប្រើសម្គាល់លើផ្ទាំងសាច់សាច់ឬកញ្ចប់ផលិតផលសត្វ។

6. បង្កឧបសគ្គតាមគ្រប់រូបភាពដល់កិច្ចអន្តរាគមន៍ទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វរបស់មន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច ក្នុងពេលបំពេញប្រតិបត្តិការស្របតាមច្បាប់នេះ។
7. គំរាមកំហែង ឬប្រតិកម្មដោយហិង្សាមកលើមន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ឬមន្ត្រីអន្តរាគមន៍មានសមត្ថកិច្ចទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វ ក្នុងពេលបំពេញប្រតិបត្តិការស្របតាមច្បាប់នេះ។
8. មិនព្រមប្រគល់ លាក់បំបាំង បំផ្លាញវត្ថុតាង ឬចាត់ចែងវត្ថុតាងដែលជាកម្មវត្ថុនៃការចាប់យកជាបណ្តោះអាសន្ន ឬត្រូវបានរឹបអូសស្របតាមច្បាប់នេះ។

### ១៣.១៣ មាត្រា ១១៧

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចំពោះបទល្មើសនៃមាត្រា ១១៤ មាត្រា ១១៥ និងមាត្រា ១១៦ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល និងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ១៣.១៤ មាត្រា ១១៨

បុគ្គលដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា ១១៤ មាត្រា ១១៥ មាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ អាចត្រូវបានដកហូត ឬលុបចោលដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនូវវិញ្ញាបនបត្រ និងលិខិតអនុញ្ញាតគ្រប់ប្រភេទពាក់ព័ន្ធ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើឲ្យមានផលប៉ះពាល់ ឬមានគ្រោះថ្នាក់ដល់បរិស្ថានឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ ត្រូវជួសជុលព្យសនកម្មតាមទំហំដែលធ្វើឲ្យប៉ះពាល់។

### ១៣.១៥ មាត្រា ១១៩

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ១១២ មាត្រា ១១៣ ដែលសំណុំរឿងបានបញ្ជូនមកតុលាការ និងបទល្មើសដូចមានក្នុងមាត្រា ១១៤ មាត្រា ១១៥ និងមាត្រា ១១៦ នៃច្បាប់នេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស៖

1. ហាមឃាត់ការប្រកបមុខរបរដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ឬជាស្ថាពរ។
2. រឹបអូសវត្ថុតាងនៃបទល្មើស។
3. បិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។
4. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

### ១៣.១៦ មាត្រា ១២០

មន្ត្រីមានសមត្ថកិច្ចណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរារាំងការអនុវត្តច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ។

## ១៤ ជំពូកទី ២១ អន្តរប្បញ្ញត្តិ

### ១៤.១ មាត្រា ១២១

អនុក្រឹត្យ និងប្រកាសដែលកំពុងមានអនុភាពអនុវត្ត ត្រូវបន្តអនុវត្តត្រឹមទំហំដែលមិនផ្ទុយជាមួយនឹងច្បាប់នេះ រហូតដល់មានអនុក្រឹត្យ និងប្រកាសថ្មីមកជំនួស។

### ១៤.២ មាត្រា ១២២

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតមានសុពលភាពមុនច្បាប់នេះចូលជាធរមាន ហើយនៅសល់សន្និធិ ឬកំពុងតាំងលក់សត្វ ផលិតផលសត្វ រូបធាតុសេនេទិកសត្វ ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមចំណីសត្វ បសុឱសថណា និងវត្ថុធាតុជីវៈបសុព្យាបាលត្រូវបញ្ចប់ការផ្គត់ផ្គង់ចែកចាយបន្តទៀតក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ។

### ១៤.៣ មាត្រា ១២៣

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកំពុងដំណើរការក្រោមអនុញ្ញាតណាមួយដែលមានសុពលភាពនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបំពេញសំណុំបែបបទស្នើសុំការអនុញ្ញាតឡើងវិញ និងស្នើសុំការចុះបញ្ជីជាថ្មី តាមនីតិវិធីដែលកំណត់ដោយច្បាប់នេះ ក្នុងរយៈពេលមិនលើសពី ១ (មួយ) ឆ្នាំ គិតពីចាប់កាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ។

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
## សន្ទានុក្រម

1. កន្លែងឆ្លងជំងឺ សំដៅដល់ទីតាំងណាមួយ ទីកន្លែងណាមួយ អគារ ទីកន្លែងចិញ្ចឹមសត្វមានមេរោគបង្កជំងឺ ឬជឿថាមានមេរោគជំងឺវិញ្ញត្តិដែលត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
2. ការកែច្នៃបឋមផលិតផលសត្វ សំដៅដល់ការបំលែងផលិតផលសត្វតាមរយៈដំណើរការនៃការកែច្នៃមានជាអាទិ៍ ការពិឃាត ការពន្លាត់ស្បែក ការសម្អាត ការហាលសម្ងួត ការឆ្អើរ ការក្លាស្សេ ការបង្កក ការចំហុយ ការអាំង ការដុត ការផ្អាប់ ការកិន ការប្រឡាក់អំបិល ការវេចខ្ចប់ ការរក្សាទុកតាមបច្ចេកទេសចម្អិនផ្សេងៗ។
3. ការកម្ទេចចោល សំដៅដល់ការសម្លាប់ ការបំផ្លាញចោល បំបែកជាបំណែកធ្វើឲ្យបាត់សមត្ថភាពដើមតាមវិធានការបសុព្យាបាល។
4. ការឃ្លាំមើល សំដៅដល់ការប្រមូល និងការវិភាគព័ត៌មានជាលក្ខណៈប្រព័ន្ធទាក់ទងនឹងសុខភាពសត្វ ក្នុងគោលបំណងរកឲ្យឃើញជាមុន ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានឲ្យបានទាន់ពេលវេលា

ដល់អ្នកពាក់ព័ន្ធ សំដៅចាត់វិធានការទប់ស្កាត់ជំងឺសត្វដែលមានឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិ សុវត្ថិភាពម្ហូបអាហារ និងពាណិជ្ជកម្ម។

5. ការដាក់កំហិត សំដៅដល់ការកំណត់លក្ខខណ្ឌការរឹតបន្តឹងចរាចរណ៍សត្វ ផលិតផលសត្វ ឧបករណ៍សម្ភារ និងមធ្យោបាយដឹកជញ្ជូនពាក់ព័ន្ធដ៏ទៃទៀតដើម្បីកុំឲ្យឆ្លងរាលដាល។
6. ការតាមដាន សំដៅដល់ការប្រមូលព័ត៌មាន សង្កេតត្រួតពិនិត្យជាប្រចាំស្ដីពីជំងឺសត្វ ផលិតភាព និងគុណភាពផលិតផលសត្វ បសុឱសថចំណីសត្វ ក្នុងគោលបំណងរកឲ្យឃើញការប្រែប្រួលក្នុងបរិស្ថាន ឬការប្រែប្រួលស្ថានភាពសុខភាពសត្វ។
7. ការត្រួតពិនិត្យអនាម័យបសុព្យាបាល សំដៅដល់ការត្រួតពិនិត្យអនាម័យដោយមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វលើសត្វ ផលិតផលសត្វ បសុឱសថចំណីសត្វដើម្បីកំណត់នូវវត្តមានវត្ថុជីវសាស្ត្រ គីមីសាស្ត្រ រូបសាស្ត្រ ឬជាតុវិទ្យុសកម្មដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ចំពោះសុខភាពសត្វ សុខភាពមនុស្ស និងបរិស្ថាន។
8. ការបោះបង់ចោល សំដៅដល់ការបោះបង់កម្មសិទ្ធិ ឬការជម្លៀសចេញពីបរិវេណកម្មសិទ្ធិទៅកន្លែងទីទៃនូវសត្វរស់ ឬស្លាប់ ផលិតផលសត្វ បសុឱសថចំណីសត្វ ឧបករណ៍ ឬសម្ភារដ៏ទៃទៀត ដោយគ្មានការអនុញ្ញាត ឬដែលមិនអនុវត្តតាមវិធានការបសុព្យាបាល។
9. ការសម្លាប់មេរោគ សំដៅដល់ការអនុវត្តនូវវិធានការនានាក្នុងគោលបំណងកម្ទេចភ្នាក់ងារបង្ករោគ ឬបរាសិតក្រោយពេលលាងសម្អាតដែលអនុវត្តចំពោះកន្លែងមធ្យោបាយដឹកជញ្ជូន និងឧបករណ៍សម្ភារដែលប៉ះពាល់មេរោគដោយផ្ទាល់ ឬដោយប្រយោល។
10. ការអង្កេតអេពីដេមីសាស្ត្រ សំដៅដល់ការកំណត់ប្រភព និងមូលហេតុនៃការផ្ទុះជំងឺព័ត៌មានអំពីបរិស្ថានមេកានិចនៃការចម្លងកំណត់វិសាលភាពនៃការចម្លង និងរៀបចំយុទ្ធវិធីសម្រាប់បង្ការទប់ស្កាត់ និងលុបបំបាត់ជំងឺ។
11. ចត្តាឡីស័ក សំដៅរាល់សកម្មភាពដឹកនាំដោយមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចដើម្បីបង្ខាំងសត្វ ផលិតផលសត្វ ឧបករណ៍ សម្ភារ និងមធ្យោបាយដឹកជញ្ជូនដែលប៉ះពាល់សត្វ ឬផលិតផលសត្វ ដើម្បីត្រួតពិនិត្យអនាម័យបង្ការ និងទប់ស្កាត់ជំងឺ។
12. ចរាចរណ៍សត្វ សំដៅដល់បន្លាស់ទីសត្វពីទីកន្លែងមួយទៅកន្លែងមួយទៀតតាមគ្រប់រូបភាព។
13. ចំណីសត្វ សំដៅដល់វត្ថុធាតុទាំងអស់រួមមានវត្ថុធាតុដើម សារធាតុបន្ថែម និងសារធាតុលាយផ្សំដ៏ទៃទៀត (សមាសភាគតែមួយ ឬច្រើនមុខ) ដែលកែច្នៃ ពាក់កណ្ដាលច្នៃ ឬមិនទាន់កែច្នៃក្នុងគោលបំណងយកមកប្រើប្រាស់ជាចំណីសត្វ។
14. ជំងឺវិញ្ញត្តិ សំដៅទៅដល់ជំងឺឆ្លង ដែលមានចែងក្នុងបញ្ជីឈ្មោះជំងឺសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយអនុលោមតាមបទប្បញ្ញត្តិជាតិ។ ជំងឺនេះមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស សត្វឬបរិស្ថានឬមានសក្ដានុពលបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមឬពាណិជ្ជកម្ម។
15. ជំងឺស៊ូណូស សំដៅដល់បណ្ដាប្រភេទជំងឺដែលឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ។
16. តំបន់គ្មានជំងឺ សំដៅដល់តំបន់ដែលគ្មានវត្តមានជំងឺដោយអនុលោមតាមការតម្រូវសម្រាប់ស្ថាន

ភាព (គ្មានជំងឺ) ដែលបានកំណត់នៅក្នុងក្រមរបស់អង្គការសុខភាពពិភពលោក ឬនៅក្នុងតំបន់និងនៅតាមព្រំប្រទល់នៃតំបន់នោះមានមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចត្រួតពិនិត្យសត្វ ផលិតផលសត្វ និងមធ្យោបាយដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព។

17. តំបន់ទប់ស្កាត់ជំងឺ សំដៅដល់ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តវិធានការអនាម័យក្នុងគោលបំណងទប់ស្កាត់ជំងឺ និងសម្រួលពាណិជ្ជកម្ម។ តំបន់ទប់ស្កាត់ជំងឺរួមមានដែលហាមឃាត់ដែនទប់ស្កាត់តំបន់មានជំងឺឆ្លងរាលដាលតំបន់ទ្រនាប់និងឃ្លាំមើល។
18. ទប់ស្កាត់ សំដៅដល់សកម្មភាពបង្ការ និងរារាំងជំងឺក្នុងគោលបំណងកាត់បន្ថយអត្រាឈឺ និងស្លាប់របស់សត្វព្រមទាំងរារាំងការឆ្លងរីករាលដាលជំងឺដល់សត្វ មនុស្ស និងប៉ះពាល់ដល់បរិស្ថាន។
19. ទីកន្លែង សំដៅដល់គ្រឹះស្ថាន ឬទីធ្លាបរិវេណដោយរាប់បញ្ចូលទាំងអគារសម្ភារ និងឧបករណ៍បំពាក់ដែលប្រើប្រាស់សម្រាប់គោលបំណងរួមដាក់លាក់។
20. ទីកន្លែងប្រមូលផ្តុំរក្សាសត្វ សំដៅដល់ទីកន្លែងបំប៉នសត្វ បង្ខឹកសត្វ ទីកន្លែងសំណាក់សត្វ របើសសត្វ ទីកន្លែងស្តុកសត្វ និងទីកន្លែងប្រមូលផ្តុំសត្វសម្រាប់គោលបំណងផ្សេងទៀត។
21. ទីកន្លែងព្យាបាលសត្វ សំដៅដល់មន្ទីរពេទ្យសត្វ គ្លីនិកសត្វ និងបន្ទប់ព្យាបាលសត្វ។
22. ទីកន្លែងអាជីវកម្មសត្វ សំដៅដល់ទីកន្លែងទិញលក់សត្វ ផ្សារសត្វ និងទីកន្លែងធ្វើអាជីវកម្មផ្សេងទៀត។
23. ទីតាំងជីវសុវត្ថិភាព សំដៅដល់ទីកន្លែងមួយឬច្រើនដែលចិញ្ចឹមសត្វស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងជីវសុវត្ថិភាពរួមមួយដោយមានស្ថានភាពសុខភាពជាក់លាក់ទៅនឹងជំងឺមួយឬច្រើនដែលទាមទារការប្រើប្រាស់ឃ្លាំមើលការទប់ស្កាត់ និងវិធានជីវសុវត្ថិភាពដែលមានប្រយោជន៍សម្រាប់ពាណិជ្ជកម្ម។
24. បសុពេទ្យ សំដៅដល់នីតិជនដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វកម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងដែលមានការទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសទ។
25. បមាណីយ សំដៅដល់ប្រព័ន្ធបទបញ្ញាអប្បបរមាគំរូដែលជាការតម្រូវសម្រាប់អនុវត្តនៅក្នុងប្រតិបត្តិការដែលពាក់ព័ន្ធផលិតកម្ម សុខភាពសត្វ ជាពិសេសចំណីសត្វ សារធាតុបន្ថែម ឬបសុឱសថគ្រប់ប្រភេទ ដើម្បីឆ្លើយតបចំពោះការធានាប្រសិទ្ធភាព និងសុវត្ថិភាព ដូចមានចែងក្នុងច្បាប់នេះ។
26. បសុឱសថ សំដៅដល់សារធាតុមួយមុខ ឬបន្សំសារធាតុច្រើនមុខដែលមានប្រភពពីសារធាតុជាតិគីមី ជីវផលិតផលជាតិ អតិសុខុមប្រាណ រុក្ខជាតិដែលផលិតលាយផ្សំឡើងដើម្បីប្រើប្រាស់សម្រាប់សត្វ៖ ក្នុងការបង្ការឬព្យាបាលជំងឺ ស្រាវជ្រាវវេជ្ជសាស្ត្រឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ កែប្រែ ឬទ្រទ្រង់មុខងារនៃសរីរាង្គ។
27. ត្រូវបានចាត់ទុកជាបសុឱសថដែលរួមមានសេរ៉ូមឬវ៉ាក់សាំងសត្វ ឈាម ឬផលិតផលដែលបានមកពីឈាមសត្វ
28. ឱសថបុរាណ ផលិតផលដែលផ្សំឡើងដោយមានជាតិពុល ដែលមានក្នុងបញ្ជីកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

29. ផលិតផលដែលមានដើមកំណើតពីសត្វ សំដៅទៅដល់៖ ផលិតផលមានដើមកំណើតពីសត្វសម្រាប់មនុស្សបរិភោគដែលរួមមានសាច់សត្វស្រស់ផលិតផលសាច់ ស៊ើឡាទីនស៊ុត ផលិតផលស៊ុត ទឹកដោះ ផលិតផលទឹកដោះ និងទឹកឃ្មុំ
30. ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើប្រាស់ក្នុងកសិកម្ម និងឧស្សាហកម្ម
31. ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើប្រាស់ក្នុងការផលិតឱសថឬវះកាត់ដែលរួមមានសរីរាង្គសត្វជាលិកា និងសារជាតុរាវសរីរាង្គដែលត្រូវបានប្រើប្រាស់ក្នុងការផលិតឱសថឬសម្ភារវះកាត់
32. ផលិតផលមានដើមកំណើតពីសត្វប្រើប្រាស់សម្រាប់ការផលិត លាយផ្សំចំណីសត្វដែលមានជាអាទិ៍ ម្សៅសាច់ ម្សៅថ្លើម ម្សៅឆ្អឹង ម្សៅឈាម ម្សៅត្រី ម្សៅរោមសត្វ ខ្លាញ់សត្វ ផលិតផលទឹកដោះ។
33. ផលិតផលសត្វ សំដៅដល់ផ្នាំងសាច់ ឬផ្នែកណាមួយនៃផ្នាំងសាច់ផលិតផលមានដើមកំណើតពីសត្វ វត្ថុជាតុសេនេទិកសត្វ វត្ថុជាតុរោគសាស្ត្រសត្វ លាមកសត្វ និងទឹកមូត្រ។
34. ផលិតផលសាច់ សំដៅដល់សាច់ដែលត្រូវបានធ្វើប្រព្រឹត្តកម្មដោយបម្លែងលក្ខណៈសរីរៈ លក្ខណៈរូប និងលក្ខណៈគីមីសរីរៈរបស់វា។
35. ភាពអាសន្ននៃជំងឺសត្វ សំដៅដល់វត្តមាននៃការផ្ទុះ ឬអាចផ្ទុះជំងឺវិញ្ញត្តិ។
36. ភ្នាក់ងារបសុពេទ្យ សំដៅដល់នីតិជនដែលមានសញ្ញាបត្រកម្រិតបឋមផ្នែកផលិតកម្មសត្វ និងបសុព្យាបាល ឬសញ្ញាបត្រសមមូល។
37. មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ សំដៅដល់បសុពេទ្យរបស់រដ្ឋដែលត្រូវបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តការត្រួតពិនិត្យអនាម័យបសុព្យាបាល អនុវត្តវិធានការអនាម័យ ទប់ស្កាត់ អង្កេតតាមដានធ្វើរបាយការណ៍លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងការងារពាក់ព័ន្ធផ្សេងទៀត។
38. មន្ទីរព្យាបាលសត្វ សំដៅដល់មន្ទីរពេទ្យសត្វ និងកន្លែងពិនិត្យព្យាបាលសត្វគ្រប់ខ្នាតរបស់រដ្ឋនិងឯកជន។
39. រេអាក់ទីហ្វ សំដៅដល់សារជាតុដែលធ្វើប្រតិកម្មដោយផ្ទាល់ ឬធ្វើប្រតិកម្មចម្លង សម្រាប់ប្រើប្រាស់ក្នុងការធ្វើតេស្ត វិភាគ និងធ្វើរោគវិនិច្ឆ័យនៅក្នុងមន្ទីរពិសោធន៍។
40. វត្ថុជាតុរោគសាស្ត្រ សំដៅដល់ផ្នែកណាមួយ ឬទាំងមូលនៃជាលិកា ឬសរីរាង្គដែលមាននៅលើសត្វរស់ ឬសត្វស្លាប់ និងដែលមានបម្រែបម្រួលខុសប្រក្រតីទាំងលក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវៈហើយសង្ស័យថាមានមេរោគមានភ្នាក់ងារចម្លងជំងឺឆ្លង ឬជំងឺប៉ារ៉ាស៊ីត។
41. វត្ថុជាតុដើម សំដៅដល់ផលិតផលមានប្រភពពីបន្លែរុក្ខជាតិ ឬសត្វស្ថិតក្នុងលក្ខខណ្ឌធម្មជាតិស្រស់ ស្ងួត ផ្អាប់ ឬរក្សាទុកឲ្យបានយូរផលិតផលមានប្រភពពីការកែច្នៃឧស្សាហកម្ម និងសារជាតុសរីរាង្គឬអសរីរាង្គដោយផលិតផលទាំងអស់នេះ សម្រាប់ប្រើប្រាស់ជាចំណីសត្វ។
42. វត្ថុវិភាគ សំដៅដល់សត្វទាំងមូលផ្នែកណាមួយ ឬសរីរាង្គណាមួយរបស់សត្វឈាមសេរ៉ូម ស្លេស្មសំបោរ លាមក ទឹកមូត្រផលិតផលសត្វ ផលិតផលសាច់ បសុឱសថចំណីសត្វ ដែលត្រូវបានយកទៅធ្វើវិភាគ។

43. វិញ្ញាបនបត្របសុព្យាបាល សំដៅដល់លិខិតបញ្ជាក់ជាផ្លូវការ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៃប្រទេសណាមួយដែលពិព័ណ៌នាអំពីតម្រូវការសុខភាពសត្វ ឬសុខភាពសាធារណៈដែលធ្វើចំពោះសត្វ ឬផលិតផលសត្វសម្រាប់ចរាចរណ៍ដោយអនុលោមទៅតាមលក្ខខណ្ឌបទដ្ឋានបច្ចេកទេសរបស់អង្គការសុខភាពពិភពលោក។
44. វិធានការអនាម័យ សំដៅដល់វិធានការដើម្បីការពារសុខភាពសត្វ ឬសុខភាពមនុស្ស ឬបរិស្ថានពីហានិភ័យដែលកើតឡើងដោយសារការនាំចូល ការបង្កើត និងការសាយភាយភ្នាក់ងារជីវសាស្ត្រ គីមីសាស្ត្រ ឬរូបសាស្ត្រ។ វិធានការដោអាទិ៍ ការសង្កេត ការស្រាវជ្រាវ ការដាក់ឲ្យនៅដោយឡែក ចត្តាឡីស័កការបង្ការ និងការព្យាបាល ការសម្អាត ការសម្លាប់ ការកម្ទេចចោលមេរោគ និងសត្វចង្រៃ។
45. សត្តឃាតដ្ឋាន សំដៅដល់ទីកន្លែងសត្វត្រូវបានពិឃាតយកសាច់ ផលិតផលសត្វ ដើម្បីធ្វើអាជីវកម្ម។
46. សត្វ សំដៅដល់ថនិកសត្វ បក្សី ឬឃ្មុំ។
47. សាច់ សំដៅដល់ផ្នែកទាំងអស់របស់សត្វ ដែលអាចបរិភោគបាន។
48. សារជាតុបន្ថែម សំដៅដល់សារជាតុ ដែលត្រូវបានដាក់បន្ថែមទៅក្នុងវត្ថុជាតុដើម ឬចំណីសត្វក្នុងគោលបំណងកែប្រែរសជាតិ ក្លិន រូបរាង ឬលក្ខណៈរូបសាស្ត្រដ៏ទៃទៀត ឬដើម្បីបង្កើនភាពរំលាយអាហារ ការស្រូបយក ឬភាពធន់នឹងការខូចខាត។
49. សារជាតុសកម្ម សំដៅដល់សារជាតុចាំបាច់ចម្បងដែលមាននៅក្នុងបសុឱសថ ឬចំណីសត្វ។
50. សុខភាពសាធារណៈបសុព្យាបាល សំដៅរាល់សកម្មភាពនៅក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វក្នុងគោលបំណងទប់ស្កាត់ និងលុបបំបាត់ជំងឺស៊ូណូស និងការពារសុវត្ថិភាពម្ហូបអាហារ។
51. សុខុមាលភាពសត្វ សំដៅដល់ស្ថានភាព ឬលក្ខខណ្ឌរស់នៅរបស់សត្វដូចជា សត្វមានសុខភាពល្អ ផ្តល់ចំណីអាហារគ្រប់គ្រាន់ រស់នៅមានសុវត្ថិភាព មានជម្រកសមរម្យ ការចិញ្ចឹម ការប្រើប្រាស់ការដឹកជញ្ជូន និងការពិឃាតតាមបែបមនុស្សធម៌។
52. ស្ថានីយចត្តាឡីស័ក សំដៅដល់ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ឬផលិតផលសត្វដែលត្រូវបានរក្សាទុកនៅដាច់ដោយឡែក ដើម្បីចាត់វិធានការបសុព្យាបាលដោយអនុលោមតាមបទដ្ឋានពាណិជ្ជកម្មស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។
53. សុពលភាពផ្គត់ផ្គង់ចែកចាយ សំដៅដល់ការងារក្រោយការចុះបញ្ជី ដែលអនុវត្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតឲ្យធ្វើការនាំចូល ការផលិត ការលាយផ្សំឬការវេចខ្ចប់ជាបសុឱសថឬចំណីសត្វ ដើម្បីទទួលបាននូវសិទ្ធិធ្វើការផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្រោយពេលដែលលទ្ធផលវិភាគលើវត្ថុវិភាគ ដែលត្រូវបានមន្ត្រីអធិការកិច្ចមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រា ដើម្បីផ្ទៀងផ្ទាត់ឡើងវិញនូវបមាណីយ និងលក្ខខណ្ឌបទដ្ឋានបច្ចេកទេសឃើញថា ពុំមានភាពប្រែប្រួលខុសពីការបញ្ជាក់អះអាងនៅពេលស្នើសុំការចុះបញ្ជីហើយអ្នកកាន់លិខិតអនុញ្ញាតបានអនុវត្តតាមគ្រប់តម្រូវការបមាណីយ និងលក្ខខណ្ឌបទដ្ឋានបច្ចេកទេសដែលកំណត់ដោយច្បាប់នេះ។
54. ស្លាកសញ្ញាព័ត៌មាន សំដៅដល់ស្លាកសញ្ញាដែលសរសេរបោះពុម្ព ឬជាក្រាហ្វិកមានឈ្មោះពាណិជ្ជ

សញ្ញា សមាសធាតុ របៀបប្រើប្រាស់ កាលបរិច្ឆេទ ។ល។ សម្រាប់ភ្ជាប់ទៅនឹងផលិតផលសត្វ ផលិតផលសាច់ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់ការផលិតនិងការលាយផ្សំបសុឱសថ ចំណីសត្វ សារធាតុសកម្ម ឬសមាសធាតុបសុឱសថ នៅលើសំបកវេចខ្ចប់ផ្នែកខាងក្នុង ឬខាងក្រៅ ដូចជាដប សំបកកំប៉ុង អំពូល បាវ ថង់ ប្រអប់ ។ល។

55. អត្តសញ្ញាណកម្មសត្វ សំដៅដល់ការប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីកំណត់អត្តសញ្ញាណសត្វ ដើម្បីផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រង់ស្ថិតិសត្វ ចរាចរណ៍សត្វ ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការធ្វើពាណិជ្ជកម្មសត្វ ការត្រួតពិនិត្យអនាម័យសត្វ ការទប់ស្កាត់ជំងឺឆ្លងរាលដាល និងការសម្គាល់សិទ្ធិសត្វ។

56. អធិការកិច្ច សំដៅដល់ការចុះត្រួតពិនិត្យ ចាត់វិធានការបច្ចេកទេស និងវិធានការច្បាប់លើសកម្មភាព និងទីកន្លែងចិញ្ចឹមសត្វ ទីកន្លែងបង្កាត់ពូជសត្វ មន្ទីរព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លេងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃផលិតផលសត្វ ទីកន្លែងប្រមូលផ្តុំ ឬលក់ផលិតផលសត្វ ទីកន្លែងផលិតលាយផ្សំ ឬលក់ចំណីសត្វ និងទីកន្លែងផលិតលាយផ្សំ ឬលក់បសុឱសថ ឬទីកន្លែងដ៏ទៃទៀតដែលពាក់ព័ន្ធវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

57. អាជីវកម្មសត្វ សំដៅដល់ការទិញ លក់ ដូរ ដឹកជញ្ជូន និងពិឃាតសត្វ។ អ្នកបច្ចេកទេសបសុពេទ្យ សំដៅដល់នីតិជនដែលមានសញ្ញាបត្រ បរិញ្ញាបត្រងបច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្មបែបវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ ឬសញ្ញាបត្រមធ្យមផ្នែកផលិតកម្ម និងបសុព្យាបា ឬសញ្ញាបត្រសមមូល។